សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economicques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីក្រុមហ៊ុន
# មហាជនទទួលខុសត្រូវមានកម្រិត

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ កញ្ញា **ឥត្ត សុនី**

កញ្ញា **សុក ស្រីនាង**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គីមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្ដីថ្លែងអំណរគុណ

បន្ទាប់ពីបានសិក្សានៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល០៤ (បួន) ឆ្នាំកន្លងមក ពួកយើងទាំងពីរនាក់ ក៏ទទួលបានសិទ្ធិនៅក្នុងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែង ពួកយើងជឿជាក់យ៉ាងមុតមាំថាប្រសិនបើគ្មានការរួមចំណែកពីកត្តាខាងក្រៅទេ ពួកយើងក៏មិនបានទទួលភាគជោគជ័យ និងមានថ្ងៃនេះដែរ។

ដូច្នេះនាងខ្ញុំ ភ័ក្ត សុនី និងកញ្ញា សុក ស្រីនាង ដែលជានិស្សិតបង់ថ្លៃជំនាន់ទី២០ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្នុងឆ្នាំសិក្សា២០១៩-២០២០ សូមសំដែងនូវការគោរពដឹងគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតដល់ ៖

- ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលទ្រង់គង់ជាម្លប់ដល់កូនចៅគ្រប់ជំនាន់។
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំធ្វើយ៉ាងណាដឹកនាំមាតុភូមិកម្ពុជាឆ្ពោះទៅកាន់កោះសន្តិភាពមួយ ដែលមានការរីកចម្រើនលើគ្រប់វិស័យ។
- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ និង គណៈគ្រប់គ្រងទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានរៀបចំកម្មវិធីសិក្សាដ៏មានប្រសិទ្ធភាពនិងផ្ដល់ចំណេះដឹងដល់បណ្ដានិស្សិតទាំងឡាយ ព្រមទាំងលោក/លោកស្រី សាស្ត្រាចារ្យ ព្រឹទ្ធបុរស លោកគ្រូ និងអ្នកគ្រូទាំងអស់ ដែលបានយកចិត្តទុកដាក់បង្រៀន និងចែកចាយចំណេះដឹងដល់បណ្ដានិស្សិតឱ្យក្លាយជាធនធានមនុស្សនៅក្នុងសង្គម។
- លោកឪពុក និងអ្នកម្ដាយ ដែលបានផ្ដល់កំណើត និងខិតខំព្យាយាមលះបង់គ្រប់យ៉ាងដើម្បកូននិងបង្រៀនកូនឱ្យក្លាយជាមនុស្សមានតម្លៃនៅក្នុងសង្គម។

ជាពិសេសនោះ ពួកយើងទាំងពីរនាក់ សូមសំដែងគាវរកិច្ចគោរពអរគុណយ៉ាងជ្រាលជ្រៅដោយមិនអាចខ្វះបាន ចំពោះសាស្ត្រាចារ្យ **ហ៊ីង គីមឡេង** សាស្ត្រចារ្យនីតិពាណិជ្ជកម្មនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំពួកយើងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទសារណាមួយនេះ។

ជាចុងក្រោយ ពួកយើងទាំងពីរនាក់សូមលើកម្រាមដៃដប់ គោរពជូនពរឱ្យអ្នកទាំងអស់គ្នាជួបប្រទះតែពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

នាពេលបច្ចុប្បន្ននេះការធ្វើអាជីវកម្ម និងការគ្រប់គ្រងអាជីវកម្មជាលក្ខណៈក្រុមហ៊ុនមានការពេញនិយមជាខ្លាំងនៅទូទាំងពិភពលោកដោយក្នុងនោះប្រទេសកម្ពុជា ក៏ទទួលរងនូវឥទ្ធិពលនៃវិស័យនេះផងដែរ។ ស្របពេលជាមួយនឹងវត្តមានរបស់ក្រុមហ៊ុនផ្សេងៗ និងធនាគារមួយចំនួនធំដែលបានកើតមាននៅប្រទេសកម្ពុជា។ ប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយដែលមានការរីកចម្រើនខ្លាំងលើការបណ្ដាក់ទុនលើវិស័យធនាគារ និងក្រុមហ៊ុនផ្សេងៗជាពិសេសក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺមានការរីកចម្រើនយ៉ាងខ្លាំង។ នៅក្នុងនោះផងដែរ ការចុះបញ្ជីពាណិជ្ជកម្ម ពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ហើយដោយសារការធ្វើកិច្ចសហប្រតិបត្តិការឥតឈប់ឈររបស់ធនាគារ និងក្រុមហ៊ុនផ្សេងៗនៅកម្ពុជាប្រទេសកម្ពុជាបានបង្កើតនូវច្បាប់ផ្សេងៗជាច្រើន ដើម្បីធ្វើការគ្រប់គ្រងលើវិស័យនេះ។ ជាពិសេសច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ហើយនៅឆ្នាំ១៩៩៩ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មទៅលើមាត្រាមួយចំនួន ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ក្នុងគោលបំណងធ្វើការកំណត់ទ្រង់ទ្រាយក្រុមហ៊ុនដែលបានធ្វើប្រតិបត្តិការ និងធ្វើពាណិជ្ជកិច្ចនៅទូទាំងប្រទេសកម្ពុជា។ លើសពីនេះទៅទៀតក៏មានប្រកាស និងសារាចរណែនាំរបស់ក្រសួងពាក់ព័ន្ធផងដែរ ដូចជាប្រកាស និងសារាចរណែនាំរបស់ក្រសួងពាណិជ្ជកម្មជាដើម។

ដោយសារមើលឃើញពីច្បាប់ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម និងក្រុមហ៊ុនដែលទទួលបានជោគជ័យនៅក្នុងវិស័យនេះ និងមានការជួយជ្រោមជ្រែងពីសំណាក់លោកសាស្ត្រាចារ្យ **ហ៊ីង គីមឡេង** ដែលជាសាស្ត្រាចារ្យជំនាញនីតិពាណិជ្ជកម្ម នោះទើបនាងខ្ញុំ **ភ័ក្ត សុនី** និង**កញ្ញា សុក ស្រីនាង** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២០ ក្នុងឆ្នាំសិក្សា២០១៩-២០២០ បានសម្រេចចិត្តធ្វើការស្រាវជ្រាវលើមុខវិជ្ជានីតិពាណិជ្ជកម្មនេះ ក្រោមប្រធានបទមួយដែលទាក់ទងនឹង ការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......................................................................................................................១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការចុះបញ្ជីពាណិជ្ជកម្ម**

**១.១. និយមន័យ** ......................................................................................................................៣

**១.២. មូលហេតុដែលនាំឱ្យមានការចុះបញ្ជីពាណិជ្ជកម្ម** .........................................................................៤

**១.៣. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្ម**.......................................................................................៤

១.៣.១. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជារូបវន្តបុគ្គល.......................................៤

១.៣.២. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជានីតិបុគ្គល..........................................៥

១.៣.៣. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជានីតិបុគ្គលបរទេស.................................៥

**២.១. ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**.......................................................................៦

២.១.១. លក្ខខណ្ឌគ្រឹះ..................................................................................................................៦

២.១.១.១.ការព្រមព្រៀងរបស់សមាជិកហ៊ុន.. ....................................................................................៦

២.១.១.២.សមត្ថភាពរបស់សមាជិកហ៊ុន.............................................................................................៧

២.១.១.៣. កម្មវត្ថុនៃការបង្កើតក្រុមហ៊ុន...........................................................................................៧

២.១.២. លក្ខខណ្ឌទម្រង់ និងការផ្សព្វផ្សាយជាសាធារណៈ.................................................................... ៧

២.១.២.១. លិខិតជាលាយលក្ខណ៍អក្សរ ..........................................................................................៨

២.១.២.២.ការចុះហត្ថលេខាលើលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន...........................................៨

២.១.២.៣.ការផ្សព្វផ្សាយក្នុងសារព័ត៌មាន...........................................................................................៩

២.១.២.៤.ការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម......................................................................................៩

២.១.២.៥. ការចុះបញ្ជីពាណិជ្ជកម្ម......................................................................................................១០

២.១.៣. ខ្លឹមសារលក្ខន្តិកៈរបស់ក្រុមហ៊ុន .................................................................................................... ១១

២.១.៣.១. ទ្រង់ទ្រាយក្រុមហ៊ុន......................................................................................................... ១១

២.១.៣.២. នាមករណ៍ក្រុមហ៊ុន ......................................................................................................... ១១

២.១.៣.៣. ចិរវេលាក្រុមហ៊ុន.............................................................................................................. ១១

២.១.៣.៤. សញ្ជាតិរបស់ក្រុមហ៊ុន...................................................................................................... ១១

២.១.៣.៥. កម្មវត្ថុ ...............................................................................................................................១២

២.១.៣.៦. ទីស្នាក់ការក្រុមហ៊ុន ......................................................................................................... ១១

២.១.៣.៧. ដើមទុនរបស់ក្រុមហ៊ុន.......................................................................................................១២

២.១.៣.៨. ភាគហ៊ុន ...........................................................................................................................១៣

**២.២. ការគ្រប់គ្រង និងការដឹកនាំរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**........១៣

២.២.១. មហាសន្និបាតរបស់ម្ចាស់ហ៊ុន ...........................................................................................................១៣

២.២.១.១. ការកោះប្រជុំមហាសន្និបាតរបស់ម្ចាស់ហ៊ុន.......................................................................... ១៤

២.២.១.២. កូរ៉ុម និងសេចក្ដីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុន ........................................................ ១៥

**២.២.២. ការគ្រប់គ្រងក្រុមហ៊ុន និងការត្រួតពិនិត្យក្រុមហ៊ុន**.......................................... ១៥

២.២.២.១. ក្រុមប្រឹក្សាភិបាល............................................................................................................. ១៥

ក. សមាសភាពក្រុមប្រឹក្សាភិបាល.................................................................................................. ១៥

ខ.មុខងាររបស់ក្រុមប្រឹក្សាភិបាល ................................................................................................. ១៦

គ. ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាល ..................................................................................... ១៦

២.២.២.២. អភិបាល ........................................................................................................................... ១៦

ក. ការតែងតាំងអភិបាល.................................................................................................................. ១៦

ខ. តួនាទីរបស់អភិបាល.....................................................................................................................១៧

គ. ការបញ្ចប់តួនាទីរបស់អភិបាល......................................................................................................១៧

២.២.២.៣. អគ្គនាយក..........................................................................................................................១៧

**២.៣ .ការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ..........................................................១៧

២.៣.១. ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជី.............................................................................. ១៨

២.៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ......................................................................................២០

## ជំពូកទី៣

## នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

**៣.១. ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា** ..................................................................................២២

៣.១.១. ការចុះបញ្ជីបង្កើត ..........................................................................................................២២

៣.១.២. ការចុះបញ្ជីកែប្រែ ..........................................................................................................២៤

៣.១.៣.ការចុះបញ្ជីរំលាយ ..........................................................................................................២៦

**៣.២. ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**.......................................................................២៨

៣.២.១. ការចុះបញ្ជីបង្កើត...........................................................................................................២៩

៣.២.២. ការចុះបញ្ជីកែប្រែ........................................................................................................... ៣៣

**៣.៣. អានុភាពនៃការចុះបញ្ជីពាណិជ្ជកម្ម** ................................................................................៣៩

៣.៣.១. ចំពោះការចុះបញ្ជីបង្កើត ..............................................................................................៣៩

៣.៣.២. ចំពោះការចុះបញ្ជីកែប្រែ ...............................................................................................៣៩

៣.៣.៣. ចំពោះការចុះបញ្ជីរំលាយក្រុមហ៊ុន.................................................................................. ៤០

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**.........................................................................................៤១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សេដ្ឋកិច្ចនៅលើសាកលលោកនេះកំពុងអភិវឌ្ឍទៅមុខឥតឈប់ឈរ ដែលធ្វើឱ្យមានការប្រកួតប្រជែងយ៉ាងខ្លាំងនៅលើទីផ្សារពិភពលោក។ សេដ្ឋកិច្ចរបស់ប្រទេសនីមួយៗអាចរីកចម្រើនទៅមុខបាន គឺដោយសារការចូលរួមពីវិស័យឯកជន។

ព្រះរាជាណាចក្រកម្ពុជាក៏មិនខុសពីបណ្តាប្រទេសនានាលើពិភពលោកដែរ បន្ទាប់ពីបានងើបឡើងពីសង្គ្រាមដែលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ។ប្រទេសនេះបានធ្វើការអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ដោយសារមានការដឹកនាំដ៏ឈ្លាសវៃពីសំណាក់រាជរដ្ឋាភិបាល បានធ្វើឱ្យកម្ពុជាទទួលបានការអភិវឌ្ឍន៍លើគ្រប់វិស័យជាពិសេសលើវិស័យសេដ្ឋកិច្ចនេះតែម្តង។ ក្រោយពីរាជរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរនូវរបបសេដ្ឋកិច្ចផែនការឱ្យក្លាយជារបបសេដ្ឋកិច្ចទីផ្សារសេរីតាមរយៈនេះ បាននាំឱ្យមានលំហូរចូលរួមយ៉ាងច្រើនពីបណ្តាក្រុមហ៊ុនពាណិជ្ជកម្មមិនថាទាំងក្នុង និងក្រៅប្រទេសបានមកចូលរួមវិនិយោគក្នុងប្រទេសនេះ។

ជាក់ស្តែងក្រោយពីប្រទេសកម្ពុជាបានជាសមាជិកអាស៊ាន និង អង្គការពាណិជ្ជកម្មពិភពលោក (WTO) មកការរត់ប្រណាំងខាងផ្នែកវិស័យសេដ្ឋកិច្ចជាកត្តាចម្បង និង ជះឥទ្ធិពលយ៉ាងធំធេងមកលើកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ។ ការទាក់ទាញវិនិយោគិនមកបណ្តាក់ទុន និងបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម គឺជាចំណុចសំខាន់បំផុតសម្រាប់ការអភិវឌ្ឍន៍នៅកម្ពុជា ហើយវិធីសាស្រ្តដែលរាជរដ្ឋាភិបាលខិតខំទាក់ទាញនូវវិនិយោគិនធំៗ និងកសាងនូវប្រភពថាមពល ផ្លូវថ្នល់និងមូលដ្ឋានច្បាប់ដូចជា ច្បាប់បន្ធូរបន្ថយពន្ធដារ ដើម្បីលើកទឹកចិត្តវិនិយោគិន ព្រមទាំងតាមដាននូវការលំបាករបស់វិនិយោគិន និងជួយស្វែងរកដំណោះស្រាយ។

បច្ចុប្បន្ននេះ ដោយឃើញថាកម្ពុជាមានច្បាប់គោលគ្រប់គ្រងក្នុងវិស័យពាណិជ្ជកម្ម គឺច្បាប់ស្តីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ថែមទាំងច្បាប់មួយចំនួនទៀតដែលទើបតែអនុម័តថ្មី។ ច្បាប់នេះបានចែងអំពីប្រភេទនៃក្រុមហ៊ុនផ្សេងៗជាច្រើនដល់អ្នកវិនិយោគទុន អាចជ្រើសរើសក្នុងការបង្កើតតាមកម្រិតនៃដើមទុនរបស់ខ្លួន។ ដើម្បីអាចបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបាន គឺទាល់តែទៅចុះបញ្ជីពាណិជ្ជកម្មជាមុនសិន។ ជាពិតណាស់ការចុះបញ្ជីពាណិជ្ជកម្មជានីតិវិធីដ៏សំខាន់មួយនៅក្នុងការបង្កើតក្រុមហ៊ុន ដើម្បីឱ្យមានភាពងាយស្រួលដល់អ្នកដែលមានបំណងចង់បើកអាជីវកម្ម ហើយចង់ស្វែងយល់បន្ថែមអំពីនីតិវិធីនោះផងដែរ។ ដូច្នេះហើយទើបយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទ "**ការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**" មកបកស្រាយនៅក្នុងសារណានេះ ។

ដើម្បីឱ្យយល់កាន់តែស៊ីជម្រៅអំពីរបៀបវារៈនៃការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឱ្យកាន់តែច្បាស់លាស់នោះ នៅក្នុងសារណានេះនិងធ្វើការបែងចែកជាបីជំពូកគឺ៖

- **ជំពូកទី១** នឹងធ្វើការបកស្រាយអំពីសញ្ញាណទូទៅនៃការចុះបញ្ជីពាណិជ្ជកម្ម ដោយមានការរៀបរាប់អំពីនិយមន័យនៃការចុះបញ្ជីពាណិជ្ជកម្ម មូលហេតុដែលនាំឱ្យមានការចុះបញ្ជីពាណិជ្ជកម្ម និងលក្ខខណ្ឌដែលនាំឱ្យមានការចុះបញ្ជីពាណិជ្ជកម្ម។

- **ជំពូកទី២** នឹងធ្វើបកស្រាយអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដោយមានការរៀបរាប់អំពីនិយមន័យនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុន ការប្រតិបត្តិការរបស់ក្រុមហ៊ុន ក៏ដូចជាការរំលាយជាដើម។

- **និងជំពូកទី៣** នឹងធ្វើការបកស្រាយអំពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម ដោយមានការរៀបរាប់តាម២របៀប គឺ ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា និងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសនោះ នឹងធ្វើការបកស្រាយអំពីអានុភាពនៃការចុះបញ្ជីបង្កើត កែប្រែ និងការចុះបញ្ជីរំលាយក្រុមហ៊ុនផងដែរ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការចុះបញ្ជីពាណិជ្ជកម្ម

យោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ១៩៩៥ នៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអ្នកចង់បង្កើតអាជីវកម្មដើម្បីស្វែងរកប្រាក់ចំណេញ គេត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មលើអាជីវកម្មនៅក្រសួងពាណិជ្ជកម្ម។

តើហេតុអ្វីបានជារាជរដ្ឋាភិបាល តម្រូវឱ្យធ្វើការចុះបញ្ជីពាណិជ្ជកម្ម? ពីព្រោះការចុះបញ្ជីពាណិជ្ជកម្ម វាពិតជាមានសារៈសំខាន់ណាស់ ដើម្បីបង្ហាញថាអាជីវកម្មមួយជាអាជីវកម្មស្របច្បាប់ និងទទួលបានការការពារដោយច្បាប់នៅពេលមានជម្លោះ ឬក៏បញ្ហាណាមួយដែលកើតឡើងជាយថាហេតុ។

ប៉ុន្តែការចុះបញ្ជីពាណិជ្ជកម្មស្របទៅនឹងស្ថានភាពបច្ចុប្បន្ន គឺធ្វើឡើងដើម្បីធានាឱ្យបាននូវភាពស្របច្បាប់រួមមានឈ្មោះក្រុមហ៊ុន ប្រភេទក្រុមហ៊ុនជា (ឯកកម្មសិទ្ធិ សហកម្មសិទ្ធិ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនបរទេសជាដើម) ផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។

បន្ទាប់ពីបានធ្វើការចុះបញ្ជីពាណិជ្ជកម្មរួចមក អាជីវកម្មនឹងទទួលបានលិខិតបញ្ជាក់ព្រមទាំងទទួលបានការការពារទៀតផង ប្រសិនបើមានការចម្លងឈ្មោះ ឬផលិតផលជាដើម។

## ១.១. និយមន័យ

ការចុះបញ្ជីពាណិជ្ជកម្ម គឺជានីតិវិធីនៃការកត់ត្រាព័ត៌មានរបស់សហគ្រាសពាណិជ្ជកម្មណាមួយក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬជាការដាក់ឈ្មោះអាជីវកម្មក្នុងបញ្ជីក្រុមហ៊ុនរបស់រដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ ហើយការចុះបញ្ជីពាណិជ្ជកម្ម គឺជាលក្ខខណ្ឌមួយយ៉ាងចាំបាច់នៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម។ នៅក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មពុំបានកំណត់និយមន័យនៃពាក្យការចុះបញ្ជីពាណិជ្ជកម្មឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែគ្រាន់តែបញ្ញត្តិថា គ្រប់ក្រុមហ៊ុនពាណិជ្ជកម្មដែលធ្វើពាណិជ្ជកិច្ចនៅកម្ពុជាត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ដោយគ្រាន់តែបញ្ជាក់អំពីការតម្កល់ឯកសារមួយចំនួន ដូចជា ប្រតិវេទន៍លក្ខន្តិកៈក្រុមហ៊ុនជាដើម។

សរុបមកយើងអាចឱ្យនិយមន័យបានថាការចុះបញ្ជីពាណិជ្ជកម្ម គឺជាការដាក់តម្កល់ទុកនូវលក្ខន្តិកៈរបស់ក្រុមហ៊ុនតាមរយៈរូបវន្តបុគ្គលដែលជាសមាជិករបស់ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលក្រុមហ៊ុនបានផ្តល់សិទ្ធិ និងតាមការកំណត់របស់ច្បាប់ផងដែរនៅក្រសួងពាណិជ្ជកម្ម ដើម្បីឱ្យក្រុមហ៊ុននោះក្លាយជានីតិបុគ្គលស្របច្បាប់។ ប្រសិនបើមិនធ្វើការចុះបញ្ជីទេ ក្រុមហ៊ុននឹងត្រូវទទួលរងទណ្ឌកម្ម និងមិនមាននីតិបុគ្គលិកលក្ខណៈដែលច្បាប់ទទួលស្គាល់ និងការពារទេ។

## ១.២. មូលហេតុដែលនាំឱ្យមានការចុះបញ្ជីពាណិជ្ជកម្ម

ការចុះបញ្ជីពាណិជ្ជកម្មមានមូលហេតុជាច្រើនដូចជា ៖

- ដើម្បីពង្រីកអាជីវកម្ម
- បង្កភាពងាយស្រួលក្នុងការទទួលបានហិរញ្ញប្បទាន ៖ ធនាគារ និងវិនិយោគិនមានភាពជឿជាក់ក្នុងការផ្តល់ហិរញ្ញប្បទានចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីជាងក្រុមហ៊ុនដែលមិនបានចុះបញ្ជី
- សិទ្ធិចូលក្នុងទីផ្សារធំៗ៖ ទទួលបានអតិថិជនច្រើន បង្កើតភាពជាដៃគូជាមួយក្រុមហ៊ុនដទៃទៀត
- ទទួលបានការគាំពារផ្លូវច្បាប់ពីស្ថាប័នរដ្ឋ ស្ថាប័នយុត្តាធិការផ្សេងៗ និងស្ថាប័នផ្លូវការផ្សេងៗ
- លក្ខណៈយូរអង្វែងនៃអាជីវកម្ម ពោលគឺមាននិរន្តរភាពយូរអង្វែង
- ដើម្បីងាយស្រួលបន្តវេន បើករណីសមាជិកដទៃដកខ្លួនចេញ ក្រុមហ៊ុននឹងនៅដំណើរការធម្មតា
- ដើម្បីឱ្យអាជីវកម្មមានភាពស្របច្បាប់
- បង្កើនសក្តានុពលនៃការលក់ក្រុមហ៊ុន
- ការការពារឈ្មោះ និងយីហោ
- ដើម្បីការពាទ្រព្យសម្បត្តិផ្សេងទៀតក្នុងករណីក្ស័យធនគឺប៉ះពាល់តែទ្រព្យសម្បត្តិដែលបានចុះបញ្ជីប៉ុណ្ណោះ ដោយអាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុន។

## ១.៣. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្ម

យោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនិងច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលចង់បង្កើតអាជីវកម្មដើម្បីស្វែងរកប្រាក់ចំណេញ គេត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មលើអាជីវកម្មនៅក្រសួងពាណិជ្ជកម្ម។

នៅពេលដែលការចុះបញ្ជីពាណិជ្ជកម្មបានសម្រេចគេនឹងទទួលបានលិខិតបញ្ជាក់ពីការចុះបញ្ជី។ ហើយលក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានបែងចែកជា ៣ គឺ ៖

### ១.៣.១. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជារូបវន្តបុគ្គល

រាល់រូបវន្តបុគ្គលដែលជាពាណិជ្ជករ ត្រូវចុះបញ្ជីពាណិជ្ជកម្មនៅមន្ទីរពាណិជ្ជកម្មខេត្ត/ក្រុង ឬកន្លែងផ្សេងទៀតដែលក្រសួងពាណិជ្ជកម្មបានកំណត់ នៅកន្លែងដែលសាមីជននោះធ្វើពាណិជ្ជកម្មយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ) ថ្ងៃ មុនពេលបើកដំណើរការអាជីវកម្មរបស់ខ្លួន។

ម្យ៉ាងទៀត ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាចធ្វើការស្នើសុំដោយសាមីជននោះ ឬដោយអាណត្តិគាហករបស់គេ ហើយអាណត្តិគាហកត្រូវតែមានលិខិតប្រគល់សិទ្ធិអំណាច ដើម្បីតម្កល់ទុកនៅក្រសួងពាណិជ្ជ

ដែលខ្លួនបានស្នើសុំចុះបញ្ជីនោះ។ មិនតែប៉ុណ្ណោះពាណិជ្ជករត្រូវប្រគល់ប្រតិវេទន៍ដែលមានចុះហត្ថលេខា និងស្នាមម្រាមដៃដល់កន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មចំនួន ២ (ពីរ) ច្បាប់ផងដែរ ។[1]

### ១.៣.២. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជានីតិបុគ្គល

នីតិបុគ្គលដែលបានបង្កើតក្រុមហ៊ុន ធ្វើពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាវិញ បើទោះបីជាបែបបទនៃការបង្កើតនិងចិរវេលាបែបណាក៏ដោយគឺត្រូវតែធ្វើការចុះបញ្ជីពាណិជ្ជកម្មហើយការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃសាមីក្រុមហ៊ុន នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងមុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ១៥ (ដប់ប្រាំ) ថ្ងៃ។

ចំណែកឯអ្នកស្នើសុំចុះបញ្ជី ត្រូវប្រគល់ប្រតិវេទន៍ចំនួន ២ ( ពីរ) ច្បាប់ ព្រមទាំងត្រូវតម្កល់ទុកលក្ខន្តិកៈក្រុមហ៊ុនដល់កន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មផងដែរ ។[2]

### ១.៣.៣. លក្ខខណ្ឌក្នុងការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ពាណិជ្ជករជានីតិបុគ្គលបរទេស

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសទាំងអស់ដែលមានសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការបំពេញទម្រង់ចុះបញ្ជីពាណិជ្ជកម្មតាមមាត្រា ១៧ និង ១៨ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដូចគ្នានឹងពាណិជ្ជករជានីតិបុគ្គលដែរ។[3]

ផ្ទុយទៅវិញករណីដែលពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលមិនបានចុះបញ្ជីពាណិជ្ជកម្ម តាមការបញ្ញត្តិរបស់ក្រសួងពាណិជ្ជកម្មទេ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន៥០,០០០(ប្រាំម៉ឺន)រៀល ទៅ ៥០០,០០០ (ប្រាំសែន) រៀល ។[4]

ចំពោះករណីពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលប្រើឯកសារក្លែងក្លាយនោះ ត្រូវផ្តន្ទាទោសចាប់ពី ១ (មួយ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន) រៀល ដល់ ១០,០០០,០០០ (ដប់លាន) រៀល។[5]

---

[1] មាត្រា ១៤ នៃច្បាប់ស្តីពីសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ,១៩៩៩

[2] មាត្រា ១៧ នៃច្បាប់ស្តីពីសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ,១៩៩៩

[3] មាត្រា ១៩ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ,១៩៩៥

[4] មាត្រា ៤០ នៃច្បាប់ស្តីពីសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ,១៩៩៩

[5] មាត្រា ៤២ នៃច្បាប់ស្តីពីសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ,១៩៩៩

# ជំពូកទី២

# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុន គឺកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលព្រមព្រៀងដាក់រួមគ្នានូវទ្រព្យសម្បត្តិដើម្បីប្រកបរបរអ្វីមួយក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ដូរជាសាធារណៈ។[6] ហើយការទទួលខុសត្រូវចំពោះម្ចាស់បំណុល ម្ចាស់ហ៊ុនមិនទទួលសងបំណុលលើសពីភាគហ៊ុនដែលខ្លួនបានចូលក្នុងក្រុមហ៊ុននោះទេ។ ម្ចាស់ភាគហ៊ុនអាចលក់ ឬផ្ទេរភាគហ៊ុនទៅតតិយជនបាន។ ទោះបីជាយ៉ាងណាគេសង្កេតឃើញថាការបង្កើតក្រុមហ៊ុននេះ គឺកើតចេញពីឆន្ទៈនិងគំនិតផ្តួចផ្តើមរបស់ស្ថាបនិក ឬសមាជិកហ៊ុនដែលមានភាគហ៊ុនច្រើនជាងគេ។

## ២.១.ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវគោរពទៅតាមលក្ខខណ្ឌ ដូចដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនៅជាធរមាន។ ជាពិសេសនោះ កិច្ចសន្យាបង្កើតក្រុមហ៊ុន ត្រូវបានយកជាមូលដ្ឋាននៅក្នុងការបង្កើតក្រុមហ៊ុន ហើយកិច្ចសន្យាប្រភេទនេះ ក៏ដូចជាកិច្ចសន្យាផ្សេងទៀត គឺការបង្កើតកិច្ចសន្យាប្រភេទនេះត្រូវតែគោរពនូវវិធានកិច្ចសន្យា ពោលគឺមានលក្ខខណ្ឌចម្បងពីរដើម្បីឱ្យកិច្ចសន្យានេះមានសុពលភាពត្រឹមត្រូវតាមផ្លូវច្បាប់ គឺលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

### ២.១.១. លក្ខខណ្ឌគ្រឹះ

ដើម្បីសម្រេចលក្ខខណ្ឌគ្រឹះបានជាដំបូងនៃការបង្កើតក្រុមហ៊ុន ត្រូវមានការព្រមព្រៀងពីសមាជិកភាគហ៊ុនដែលមានឆន្ទៈក្នុងការបង្កើត និងសមាជិកដែលចូលរួមត្រូវមានសមត្ថភាពគ្រប់គ្រាន់ ហើយត្រូវមានកម្មវត្ថុនៃការបង្កើតត្រឹមត្រូវស្របទៅតាមច្បាប់កំណត់។

#### ២.១.១.១. ការព្រមព្រៀងរបស់សមាជិកហ៊ុន

ក្រុមហ៊ុនអាចកើតឡើងដោយស្របច្បាប់ ឬត្រូវតាមផ្លូវគតិយុត្ត លុះត្រាតែឈរលើគោលការណ៍នៃការព្រមព្រៀងជាមុនសិន។ ការព្រមព្រៀងជាកត្តាមួយដ៏សំខាន់ណាស់ ព្រោះមុននឹងឈានដល់ការព្រមព្រៀងនេះសមាជិកភាគហ៊ុននីមួយៗត្រូវឆ្លងកាត់ការចរចា និងពិភាក្សានៅចំពោះមុខគ្នាទៅវិញទៅមកស្វែងយល់ពីខ្លឹមសារនៃអត្ថបទ និងបែបបទ ព្រមទាំងក្របខណ្ឌនៃការបង្កើតនីតិបុគ្គលនៃក្រុមហ៊ុននោះ។

[6] មាត្រា ៨៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

ការព្រមព្រៀងត្រូវស្តែងឡើងតាមឆន្ទៈពិតប្រាកដ ដោយសេរីពីសមាជិកទាំងអស់ក្នុងក្រុមហ៊ុន និងត្រូវចៀសផុតពីអធម៌នៃការព្រមព្រៀង ដែលមានដូចជា ការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង អំពើកេងចំណេញហួសហេតុដែលជាហេតុនាំឱ្យមានវិការៈដល់កិច្ចសន្យាព្រមព្រៀងគ្នា។ គ្រប់សាជីវកម្មដែលកំពុងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា សុទ្ធតែត្រូវបង្ហាញឆន្ទៈប្រកបដោយភាពសុចរិតរបស់សមាជិកហ៊ុននីមួយៗទើបក្រុមហ៊ុននោះត្រូវបានច្បាប់ទទួលស្គាល់ និងមានភាពត្រឹមត្រូវពិតប្រាកដទៅតាមគោលការណ៍គ្រឹះនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន។

និយាយជារួមមក សមាជិកភាគហ៊ុនទាំងអស់ត្រូវតែឈរលើគោលការណ៍គ្រឹះមួយ គឺការព្រមព្រៀងរវាងគ្នា និងគ្នាប្រកបដោយឆន្ទៈយ៉ាងពិតប្រាកដ ហើយមិនត្រូវមានវិការៈណាមួយកើតឡើងឡើយ ក្នុងកិច្ចសន្យានៃការព្រមព្រៀង បើពុំដូច្នេះទេក្រុមហ៊ុននឹងពុំអាចដំណើរការធ្វើពាណិជ្ជកិច្ចរបស់ខ្លួនបានឡើយ។

**២.១.១.២. សមត្ថភាពរបស់សមាជិកហ៊ុន**

ក្រុមហ៊ុនដែលកំពុងតែដំណើរការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាសុទ្ធតែមានទម្រង់ផ្សេងៗពីគ្នា ប៉ុន្តែគោលការណ៍គ្រឹះដ៏សំខាន់មួយទៀតរបស់ច្បាប់រាល់សមាជិករបស់ក្រុមហ៊ុនត្រូវតែជាបុគ្គលដែលមានបុគ្គលិកលក្ខណៈសម្បត្តិរឹងមាំ អាចយល់ដឹងនូវព័ត៌មានទូទៅ និងចេះស្វែងយល់នូវកិច្ចការរាក់ជ្រៅ មិនមែនជាបុគ្គលអសមត្ថភាពក្នុងការស្វែងយល់នូវព័ត៌មាន ឬ ការងារនានាឡើយ។

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់នូវរូបវន្តបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមបង្កើតក្រុមហ៊ុន ឬប្រកបពាណិជ្ជកម្ម លុះត្រាតែបុគ្គលនោះមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ លើកលែងតែអនីតិជនទទួលបានអគ្គាធីនភាព។[7] ផ្ទុយមកវិញ ច្បាប់ចាត់ទុករូបវន្តបុគ្គលអសមត្ថភាព ០៣ប្រភេទ ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចប្រកបពាណិជ្ជកម្ម និងបង្កើតក្រុមហ៊ុន គឺអនីតិជន ជននៅក្រោមហិតូបត្ថម្ភ និង ជននៅក្រោមអាណាព្យាបាលទូទៅ។

**២.១.១.៣. កម្មវត្ថុនៃការបង្កើតក្រុមហ៊ុន**

ការបង្កើតក្រុមហ៊ុនត្រូវមានកម្មវត្ថុ ជាចម្បងតែមួយគត់ឆ្ពោះទៅរកការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ហើយត្រូវចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះជាពិសេសកម្មវត្ថុនោះត្រូវតែមានលក្ខណៈស្របទៅនឹងច្បាប់ និងមិនអាចផ្ទុយទៅនឹងទំនៀមទម្លាប់ល្អរបស់ជាតិ សណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍សមាជិកក្រុមហ៊ុនឡើយ។ ឧទាហរណ៍ ចំពោះក្រុមហ៊ុនដែលបង្កើតឡើងក្នុងគោលបំណងជួញដូរមនុស្ស ឬគ្រឿងញៀន គឺមិនត្រូវបានអនុញ្ញាតឡើយ។

**២.១.២. លក្ខខណ្ឌទម្រង់ និងការផ្សព្វផ្សាយជាសាធារណៈ**

[7] មាត្រា ២០ នៃក្រមរដ្ឋប្បវេណី ,២០០៧

បន្ទាប់ពីការសម្រេចបានលក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវតែរៀបចំនូវលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលជាលក្ខខណ្ឌទម្រង់ និងធ្វើការផ្សព្វផ្សាយជាសាធារណៈស្តីពីការបង្កើតក្រុមហ៊ុនដើម្បីឱ្យសាធារណជនបានដឹង។ លក្ខខណ្ឌទម្រង់ជាលក្ខខណ្ឌដែលធ្វើឡើងជាលក្ខន្តិកៈឬ បទបញ្ជាផ្ទៃក្នុងដោយមនការព្រមព្រៀងពីសំណាក់សមាជិកភាគហ៊ុនដោយធ្វើឡើងជាលិខិតជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាលើលិខិតនោះ ដោយសមាជិកទាំងអស់ដើម្បីសម្រេចយកជាផ្លូវការ។

**២.១.២.១. លិខិតជាលាយលក្ខណ៍អក្សរ**

ការសរសេរតាក់តែងឡើងជាលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមួយ គឺជាកិច្ចសន្យាក្រុមហ៊ុនដែលធានានូវវិធាននៃការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមហ៊ុននីមួយៗហើយលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង នោះត្រូវបានចាត់ទុកជាឯកសារលាយលក្ខណ៍អក្សរដែលមានទម្រង់ជា លិខិតយថាភូត ហើយគេតាក់តែងឡើងឱ្យមានលក្ខណៈសមស្របទៅនឹងទ្រង់ទ្រាយរបស់ក្រុមហ៊ុន និងច្បាប់យ៉ាងច្បាស់លាស់។

- លក្ខន្តិកៈ គឺជាឯកសារមូលដ្ឋានដែលត្រូវតម្កល់នៅក្រសួងពាណិជ្ជកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម។
- បទបញ្ជាផ្ទៃក្នុង គឺជាវិធានដាក់កម្រិតដល់អាជីវកម្ម ឬកិច្ចការរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ខ្លួនមិនចាំបាច់មានបទបញ្ជាផ្ទៃក្នុងមួយដែលធ្វើឡើងក្នុងគោលបំណង ដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន។[8]

បទបញ្ជាផ្ទៃក្នុងមិនដូចគ្នានឹងលក្ខន្តិកៈទេដោយសារវាមិនចាំបាច់តម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មឡើយនិងមិនមែនជាឯកសារសាធារណៈនោះទេ។ ជាទូទៅបទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័តដោយអភិបាលក្រុមហ៊ុននៅក្នុងប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។ បទបញ្ជាផ្ទៃក្នុងប្រើប្រាស់សម្រាប់ការណែនាំសម្រាប់ដំណើរការសាជីវកម្មប្រចាំថ្ងៃ និងជួយធានាថាមន្ត្រីគ្រប់គ្រងព្រមទាំងអភិបាល ធ្វើសកម្មភាពស្របតាមច្បាប់ និងបទបញ្ញត្តិស្តីពីវិធានពាណិជ្ជកម្ម។

**២.១.២.២. ការចុះហត្ថលេខាលើលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន**

ការចុះហត្ថលេខាលើលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើម្បីជាសក្ខីភាពមួយដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងការទទួលស្គាល់ជាផ្លូវការរបស់សមាជិកនៃភាគហ៊ុនទាំងអស់ត្រូវមានជាចាំបាច់ក្នុងការចុះហត្ថលេខា ឬហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ។[9]

ការព្រមព្រៀងគ្នារបស់សមាជិក ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ថាបានអាន និងយល់ព្រមព្រមទាំងមានទីកន្លែងកាលបរិច្ឆេទត្រឹមត្រូវទៅលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុននោះ ហើយត្រូវចុះហត្ថលេខានៅចុងក្រោយនៃលក្ខន្តិកៈនោះផងដែរ។

[8] មាត្រា ១០២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

[9] មាត្រា ៩៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

### ២.១.២.៣. ការផ្សព្វផ្សាយក្នុងសារព័ត៌មាន

ការផ្សព្វផ្សាយ គឺជាការចុះផ្សាយសម្រង់លិខិតបង្កើតក្រុមហ៊ុន ឬលក្ខន្តិកៈក្រុមហ៊ុនក្នុងសារព័ត៌មានសាធារណៈដែលស្របច្បាប់។ ការចុះផ្សាយនេះត្រូវធ្វើឡើងដោយស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកណាម្នាក់ដែលក្រុមហ៊ុនបានប្រគល់សិទ្ធិ ឱ្យត្រូវធ្វើពាក្យសុំចុះផ្សាយសេចក្តីប្រកាសស្តីពីការបង្កើតក្រុមហ៊ុនក្នុងសារព័ត៌មានណាមួយដែលរដ្ឋទទួលស្គាល់ពីការចុះផ្សាយនេះ។ ស្ថាបនិក ឬអភិបាលម្នាក់ៗ គឺជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តនូវការផ្សព្វផ្សាយដែលតម្រូវដោយច្បាប់។[10]

នៅក្នុងការផ្សព្វផ្សាយ ត្រូវមានចុះនិទ្ទេសសំខាន់ៗដូចជា ៖

- នាមករណ៍ក្រុមហ៊ុន
- ទ្រង់ទ្រាយក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្មសង្ខេប
- អាសយដ្ឋានទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន
- ចិរវេលានៃក្រុមហ៊ុន
- ចំនួនដើមទុនជាសាច់ប្រាក់
- ចំនួនភាគហ៊ុន
- តម្លៃចារឹកលើប័ណ្ណភាគហ៊ុននីមួយៗ
- បើសិនជាមានភាគទុនជាសាច់ប្រាក់ផង និង ភាគទុនជាវត្ថុផង ត្រូវបញ្ជាក់ ៖
    - ភាគទុនជាសាច់ប្រាក់មានចំនួន.................................
    - ភាគទុនជាវត្ថុគិតតម្លៃជាសាច់ប្រាក់............................
      ( ពិពណ៌នាដោយសង្ខេបអំពីភាគទុនជាវត្ថុនេះ )
    - នាមត្រកូល និងនាមខ្លួន មុខរបរ សញ្ជាតិ អាសយដ្ឋាននៃអភិបាល
    - ទីកន្លែងដែលក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម

ពាក្យសុំចុះផ្សាយសេចក្តីប្រកាសនេះដែលមានបញ្ជាក់ការយល់ព្រមទទួលចុះផ្សាយរបស់សារព័ត៌មាន ត្រូវបានរក្សាទុកយ៉ាងតិចពីរច្បាប់សម្រាប់ភ្ជាប់បំពេញជាមួយសំណុំលិខិតពេលដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម។

### ២.១.២.៤. ការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម

រាល់ទម្រង់លិខិត និងឯកសារទាំងអស់ដែលទាក់ទងទៅនឹងការបង្កើតក្រុមហ៊ុនត្រូវយកទៅតម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ដោយស្ថាបនិកក្រុមហ៊ុននៅពេលដែលដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតបញ្ជាក់មួយជា

[10] មាត្រា ៩០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

សម្គាល់ក្រោយពីបានយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុននិងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ។

**២.១.២.៥. ការចុះបញ្ជីពាណិជ្ជកម្ម**

គ្រប់ក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់ ដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះជាបែបបទនៃការបង្កើត និងចិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។ ជាពិសេសនោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃក្រុមហ៊ុនក្នុងខែនៃការបង្កើតក្រុមហ៊ុន និង ១៥( ដប់ប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម។[11]

អ្នកស្នើសុំចុះឈ្មោះត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួន ២(ពីរ) ច្បាប់មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជននោះ ត្រូវចែងអំពី៖

1) នាមត្រកូល និងនាមខ្លួន និងផ្សេងទៀត របស់សមាជិកក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។
2) ផ្លាកសញ្ញារបស់ក្រុមហ៊ុន ។
3) កម្មវត្ថុនៃក្រុមហ៊ុន ។
4) ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម មានសាខាឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ។
5) នាមនៃសមាជិក ឬតតិយជន ដែលមានការអនុញ្ញាតឱ្យគ្រប់គ្រងចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខា ជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើតនៃអ្នកទាំងនោះ។
6) ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ឬវត្ថុមានតម្លៃដែលផ្តល់ដោយសមាជិកភាគហ៊ុន ។
7) ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើម និងបញ្ចប់ ។
8) ទ្រង់ទ្រាយក្រុមហ៊ុន ។
9) ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជន ដូចមានចែងនៅចំណុចលេខ៥ នៃមាត្រា១៧ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។
10) លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

[11] មាត្រា១៧ កថាខណ្ឌទី២ នៃច្បាប់ស្តីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម,១៩៩៩

11) សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌឡើយ។

## ២.១.៣. ខ្លឹមសារលក្ខន្តិកៈរបស់ក្រុមហ៊ុន

### ២.១.៣.១. ទ្រង់ទ្រាយក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន។

### ២.១.៣.២. នាមករណ៍ក្រុមហ៊ុន

នាមករណ៍ គឺជាឈ្មោះដើម្បីដាក់សម្គាល់ក្រុមហ៊ុន ឬហៅថា យីហោក្រុមហ៊ុន ។ គ្រប់ក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយត្រូវតែមាននាមករណ៍មួយជាដាច់ខាត។ ចំពោះនាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវតែដាក់នូវពាក្យថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬអក្សរកាត់ថា "ម.ក" នៅខាងចុងឬខាងក្រោមនាមករណ៍ក្រុមហ៊ុន។[12] នាមករណ៍របស់ក្រុមហ៊ុនត្រូវតែប្រើជាភាសាខ្មែរនៅផ្នែកខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀត។ នាមករណ៍របស់ក្រុមហ៊ុនជាភាសាខ្មែរ ត្រូវមានសូរសព្ទ័ដូចជាទៅនឹងភាសាដទៃ ហើយការបកប្រែនិយមន័យនៃនាមករណ៍ក្រុមហ៊ុនទៅជាភាសាដទៃផ្សេងទៀត ត្រូវបានហាមឃាត់។[13]

### ២.១.៣.៣. ចិរវេលាក្រុមហ៊ុន

ចិរវេលារបស់ក្រុមហ៊ុន គឺជាដែនកំណត់អាយុមួយរបស់ក្រុមហ៊ុនទៅតាមលក្ខខណ្ឌគតិយុត្ត ហើយក្រុមហ៊ុននីមួយៗ អាចជ្រើសរើសចិរវេលារបស់ខ្លួនតាមពេលវេលាមួយជាក់លាក់នៃប្រភេទរបស់ក្រុមហ៊ុន។ ការសម្រេចជ្រើសរើសចិរវេលានេះ គឺជាសិទ្ធិសេរីភាពរបស់ក្រុមហ៊ុន ព្រោះបើកដំណើរការប្រព្រឹត្តទៅនៃអាជីវកម្មរបស់ក្រុមហ៊ុនទទួលជោគជ័យ និងគ្រប់ពេលវេលា ក្រុមហ៊ុននឹងមិនសម្រេចបានជោគជ័យរយៈពេលខ្លីឡើយ។ នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មិនមានចែងពីចិរវេលាពិតប្រាកដនោះទេ។ ប៉ុន្តែដោយយោងតាមប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម បានកំណត់អំពីសុពលភាពនៃការចុះបញ្ជីពាណិជ្ជកម្មត្រឹមរយៈពេល៩៩ឆ្នាំតែប៉ុណ្ណោះ។

### ២.១.៣.៤. សញ្ជាតិរបស់ក្រុមហ៊ុន

តាមគោលការណ៍ ក្រុមហ៊ុនត្រូវតែមានសញ្ជាតិមួយច្បាស់លាស់ដែលជាការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងក្រុមហ៊ុន។ ការកំណត់ផ្តល់សញ្ជាតិរបស់ក្រុមហ៊ុន គឺជាសិទ្ធិរបស់រដ្ឋដោយក្រុមហ៊ុននោះមានទីស្នាក់ការចុះបញ្ជីក្នុងប្រទេសនោះ ។ ក្រុមហ៊ុនដែលត្រូវចាត់ថា ជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាតែ ៖

[12] ប្រការ ៣ នៃប្រកាសស្តីពីការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន ,២០១៦

[13] មាត្រា ៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

- ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ ( ហាសិបមួយ ) ភាគរយត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ។[14]

**២.១.៣.៥. កម្មវត្ថុ**

កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានច្រើនប្រភេទ ប៉ុន្តែត្រូវតែស្របច្បាប់ ជាក់លាក់ អាចធ្វើកើត និងអាចប្រព្រឹត្តទៅបានព្រមទាំងបានកំណត់នៅក្នុងលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**២.១.៣.៦. ទីស្នាក់ការក្រុមហ៊ុន**

ទីស្នាក់ការក្រុមហ៊ុន គឺជាអាសយដ្ឋានការិយាល័យដើមរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងអាសយដ្ឋានរបស់ភ្នាក់ងារជាអចិន្ត្រៃយ៍ចុះបញ្ជីផងដែរ ។ នៅគ្រប់ពេលវេលា ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចបានបញ្ជាក់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវផ្តល់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងនៃក្រសួងពាណិជ្ជកម្ម នូវសេចក្តីជូនដំណឹងអំពីទីស្នាក់ការចុះបញ្ជីជាមួយលក្ខន្តិកៈដែលស្តីពីទីតាំង ឬពីការផ្លាស់ប្តូរទីតាំងស្នាក់ការចុះបញ្ជីនោះ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជីត្រូវបានផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ។[15]

**២.១.៣.៧. ដើមទុនរបស់ក្រុមហ៊ុន**

ដើមទុនរបស់ក្រុមហ៊ុន គឺជាការដាក់បញ្ចូលគ្នានូវភាគហ៊ុនរបស់សមាជិកនីមួយៗ ហើយត្រូវតែប្រកាសជារូបិយវត្ថុជាតិ។[16] ដើមទុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល។[17] ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតការដាក់ភាគទុនអាចជាសាច់ប្រាក់ឬជាវត្ថុប៉ុន្តែសម្រាប់ការដាក់ភាគទុនជាសេវា (ជំនាញឬបទពិសោធន៍) វិញ គឺមិនត្រូវបានអនុញ្ញាតឡើយ។

- **ភាគទុនជាសាច់ប្រាក់**

[14] មាត្រា ៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[15] មាត្រា ១០៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[16] មាត្រា ៩៣ ចំណុច "ឃ" នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[17] មាត្រា ៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ,២០០៧

ភាគទុនជាសាច់ប្រាក់ គឺជាភាគទុនដែលមានលក្ខណៈទូទៅបំផុត ហើយភាគទុននេះអាចបង់ជាដំណាក់កាលៗ ឬបង់ទាំងស្រុងទៅតាមការកំណត់ច្បាស់លាស់មួយ។ ការកំណត់ពីការបង់ការប្រាក់ គឺជាតួនាទីរបស់ក្រុមប្រឹក្សាភិបាល ហើយចំពោះការបង់បង្គ្រប់មិនឱ្យលើសពី៣ឆ្នាំឡើយបន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្ម។

- **ភាគទុនជាវត្ថុ**

ភាគទុនជាវត្ថុ គឺជាការយកនូវវត្ថុអ្វីមួយមកដាក់ជាភាគទុន ដែលត្រូវអភិបាលទាំងឡាយជាអ្នកកំណត់ពីកម្មវត្ថុនៃវត្ថុនោះ ហើយបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ការសម្រេចរបស់អភិបាលទាំងឡាយនោះចាត់ទុកជាបានការ។ តែបើមិនដូច្នោះទេ ភាគទុនជាវត្ថុត្រូវមានការវាយតម្លៃចេញ ជាសាច់ប្រាក់ដោយសវនករ ហើយសវនករត្រូវជ្រើសរើសដោយក្រុមប្រឹក្សាភិបាលនៅក្នុងមហាសន្និបាតដំបូង ឬត្រូវបានជ្រើសរើសដោយតុលាការ។

**២.១.៣.៨. ភាគហ៊ុន**

ភាគហ៊ុន គឺជាប្រភេទនៃមូលបត្រដែលអាចលក់ដូរបានក្នុងទីផ្សារភាគហ៊ុនដែលមានទៅតាមប្រភេទ ឬស៊េរី។ ភាគហ៊ុននីមួយៗត្រូវចុះបញ្ជីទៅតាមបែបបទដែលច្បាប់បានកំណត់។ ភាគហ៊ុននីមួយៗត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណនោះទេសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។[18]

## ២.២. ការគ្រប់គ្រង និងការដឹកនាំរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

### ២.២.១. មហាសន្និបាតរបស់ម្ចាស់ហ៊ុន

មហាសន្និបាតម្ចាស់ហ៊ុន គឺជាអង្គការដឹកនាំកំពូលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ មហាសន្និបាតម្ចាស់ហ៊ុនត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងលក្ខន្តិកៈ ឬ បទបទបញ្ញត្តិក្នុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនបើមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់។[19] មហាសន្និបាតនេះចែកចេញជា ២ ប្រភេទ គឺ មហាសន្និបាតសាមញ្ញ(ប្រចាំឆ្នាំ) និងមហាសន្និបាតវិសាមញ្ញ(ពិសេស)។

ជាទូទៅអភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុនប្រចាំឆ្នាំមិនឱ្យលើសពី ១២(ដប់ពីរ) ខែក្រោយពីក្រុមហ៊ុននោះត្រូវបានបង្កើតជាផ្លូវការ។ អភិបាលក៏អាចកោះប្រជុំមហាសន្និបាតវិសាមញ្ញរបស់ម្ចាស់ហ៊ុននៅពេលណាមួយក៏បានតាមការចាំបាច់។[20]

[18] មាត្រា ១៤៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[19] មាត្រា ២០៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[20] មាត្រា ២០៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

### ២.២.១.១. ការកោះប្រជុំមហាសន្និបាតរបស់ម្ចាស់ហ៊ុន

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានកំណត់ថា ម្ចាស់ហ៊ុនទាំងឡាយ អាចធ្វើសំណូមពរទៅអភិបាលឱ្យកោះប្រជុំមហាសន្និបាតបាន តាមគោលបំណងដែលបញ្ជាក់នៅក្នុងសំណើរនោះ។ ប៉ុន្តែលិខិតស្នើនោះត្រូវធ្វើឡើងដោយម្ចាស់មូលបត្រ ដែលកាន់កាប់បណ្ណភាគហ៊ុនមិនតិចជាង ៥១ (ហាសិបមួយ) ភាគរយនៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានបោះចេញ ហើយដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាត។ លិខិតសំណើនោះ ត្រូវមានចុះហត្ថលេខាដោយម្ចាស់ហ៊ុនម្នាក់ ឬច្រើននាក់ និងត្រូវបញ្ជាក់ផងដែរនូវពាណិជ្ជកិច្ចដែលបានធ្វើហើយត្រូវផ្ញើទៅអភិបាលម្នាក់ៗ និងទៅទីស្នាក់ការចុះបញ្ជីក្រុមហ៊ុន។ ហើយនៅពេលដែលទទួលសំណើរនោះ អភិបាលទាំងឡាយត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនដើម្បីពិភាក្សាកិច្ចការពាណិជ្ជកម្ម ដែលបានកំណត់នៅក្នុងលិខិតស្នើនោះ។ ប៉ុន្តែប្រសិនបើអភិបាលមិនបានកោះប្រជុំក្នុងអំឡុងពេល ២១ (ម្ភៃមួយ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតស្នើសុំនោះទេ ម្ចាស់ហ៊ុនណាមួយដែលបានចុះហត្ថលេខាលើលិខិតស្នើសុំនោះ អាចកោះប្រជុំមហាសន្និបាតបានដោយមិនចាំបាច់រង់ចាំតទៅទៀតទេ។[21]

ក្នុងករណីដែលមិនអាចកោះប្រជុំមហាសន្និបាត ទៅតាមបែបបទដែលបានចែងក្នុងលក្ខន្តិកៈ ឬដោយច្បាប់បាន ឬ ដោយមូលហេតុផ្សេងទៀត អភិបាល ម្ចាស់ហ៊ុន ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចស្នើទៅតុលាការឱ្យចាត់ចែងមហាសន្និបាតបាន ទៅតាមវិធីណាមួយដែលតុលាការពិចារណាយល់ឃើញថាសមស្រប។[22]

ម្យ៉ាងវិញទៀត ក្រុមហ៊ុន ត្រូវរៀបចំបញ្ជីឈ្មោះម្ចាស់ហ៊ុនដែលមានសិទ្ធិទទួលលិខិតជូនដំណឹងអំពីការប្រជុំនេះ។ បញ្ជីឈ្មោះត្រូវចាត់ចែងតាមលំដាប់អក្សរ និងបញ្ជាក់ចំនួនភាគហ៊ុនដែលបានកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ។[23] ដើម្បីធ្វើឱ្យប្រាកដថាខ្លួនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន ឬអត់នោះ ម្ចាស់ហ៊ុនម្នាក់ៗ អាចពិនិត្យបញ្ជីឈ្មោះរបស់ម្ចាស់ហ៊ុនទាំងឡាយបាននៅ ៖

- ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះនៅក្នុងម៉ោងធ្វើការធម្មតា។
- នៅពេលប្រជុំមហាសន្និបាតម្ចាស់ហ៊ុន បញ្ជីឈ្មោះត្រូវបានរៀបចំ។

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរលើរាល់ការប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវផ្តល់ទៅឱ្យម្ចាស់ហ៊ុនទាំងអស់អភិបាលទាំងអស់ និងសវនករផង ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ ទៅ ៥០ (ហាសិប)ថ្ងៃ មុនបរិច្ឆេទ

[21] មាត្រា ២០៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[22] មាត្រា ២០៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥
[23] មាត្រា ២១១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

នៃមហាសន្និបាតនោះ។ លិខិតជូនដំណឹងត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតនោះ។[24]

**២.២.១.២. កូរ៉ុម និងសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុន**

ចំនួនកូរ៉ុមនៃម្ចាស់ហ៊ុនសម្រាប់មហាសន្និបាត គឺវត្តមាននៃអ្នកកាន់កាប់ភាគហ៊ុនភាគច្រើនដែលមានសិទ្ធិបោះឆ្នោតមានវត្តមានដោយផ្ទាល់ ឬដោយតំណាងជាអាណត្តិគាហក: លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈក្រុមហ៊ុន។ ប្រសិនបើចំនួនកូរ៉ុមមានគ្រប់ចំនួននៅពេលបើកមហាសន្និបាត ម្ចាស់ហ៊ុនទាំងឡាយដែលមានវត្តមានអាចពិភាក្សានៅក្នុងអង្គប្រជុំបាន។ ប៉ុន្តែប្រសិនបើចំនួនកូរ៉ុមមិនគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាតទេ ម្ចាស់ហ៊ុនដែលមានវត្តមានអាចលើកការប្រជុំនោះទៅពេលក្រោយទៀតបាន។[25]

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់ម្ចាស់ហ៊ុនទាំងអស់ដែលមានសិទ្ធិបោះឆ្នោតមានសុពលភាពដូចគ្នានឹងសេចក្តីសម្រេចដែលបានអនុម័ត នៅឯមហាសន្និបាតម្ចាស់ហ៊ុនដែរ។

ចំពោះម្ចាស់ហ៊ុនណាដែលមិនបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកិច្ចប្រជុំ ហើយមានតឹកតាងសមហេតុផលផងដែរ ម្ចាស់ហ៊ុននោះមានសិទ្ធិប្តឹងសុំទៅតុលាការ ដើម្បីទាត់ចោលសេចក្តីសម្រេចណាមួយ ដែលធ្វើឡើងឯកិច្ចប្រជុំនោះ។[26]

**២.២.២. ការគ្រប់គ្រងក្រុមហ៊ុន និងការត្រួតពិនិត្យក្រុមហ៊ុន**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដោយយោងទៅតាមច្បាប់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង។

**២.២.២.១. ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល គឺជាបណ្តុំនៃអភិបាលដែលធ្វើសេចក្តីសម្រេចចិត្តអំពីការគ្រប់គ្រងក្រុមហ៊ុន។ រាល់រូបវន្តបុគ្គលដែលមានសមត្ថភាពមានអាយុលើសពី ១៨ឆ្នាំ អាចបម្រើការងារជាអភិបាល ឬជាអ្នកគ្រប់គ្រងក្រុមហ៊ុនបាន។ អភិបាល មិនចាំបាច់ជាម្ចាស់ហ៊ុនទេតម្រូវឱ្យមានលក្ខណសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវ។[27]

**ក. សមាសភាពក្រុមប្រឹក្សាភិបាល**

នៅក្នុងក្រុមហ៊ុន សមាសភាពរបស់ក្រុមប្រឹក្សាភិបាលមានអភិបាលមួយចំនួនដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងប្រធានមួយរូបដែលជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហើយក្រុមប្រឹក្សាភិបាលនេះ ត្រូវដឹកនាំដោយបុគ្គលទៅតាមឋានានុក្រម និងតាមតួនាទី។

---

[24] មាត្រា ១១៧ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

[25] មាត្រា ២១៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម , ២០០៥

[26] មាត្រា ២២២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, ២០០៥

[27] មាត្រា ១២០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ,២០០៥

**ខ.មុខងាររបស់ក្រុមប្រឹក្សាភិបាល**

មុខងារចម្បងរបស់ក្រុមប្រឹក្សាភិបាល រួមមានដូចជា ៖

- ជ្រើសរើស និងតែងតាំងបុគ្គលដែលនៅក្នុង ឬនៅក្រៅសមាសភាពរបស់ខ្លួនឱ្យមកបំពេញមុខងារជាអគ្គនាយក និងអគ្គនាយករងមួយរូប ឬច្រើនរូបជាជំនួយការប្រសិនបើចាំបាច់ ឬដកហូតងារមកវិញតាមការជាក់ស្តែង និងកំហុស។
- កោះអញ្ជើញសវនករ និង បញ្ជប់គណនីប្រចាំឆ្នាំ។
- ពិនិត្យលើការគ្រប់គ្រងប្រចាំថ្ងៃរបស់អគ្គនាយក និង សរសេររបាយការណ៍ជាក្រុម។
- កោះអញ្ជើញ កំណត់របៀបវារៈប្រជុំ ដឹកនាំការប្រជុំមហាសន្និបាតសាមញ្ញ និងវិសាមញ្ញនៅទីស្នាក់ការក្រុមហ៊ុន ឬនៅទីកន្លែងផ្សេង។
- សិក្សាកំណត់ទិសដៅសកម្មភាពក្រុមហ៊ុន និងទទួលយកនូវសំណួរចាំបាច់សម្រាប់ដំណើរការក្រុមហ៊ុនឱ្យបានល្អ ស្របតាមកម្មវត្ថុរបស់ក្រុមហ៊ុន។
- ផ្តល់យោបល់លើរបាយការណ៍អគ្គនាយកជុំវិញលើការជម្រះបញ្ជីប្រចាំឆ្នាំដើម្បីដាក់ជូនមហាសន្និបាតសាមញ្ញ ឬលើរបាយការណ៍ផ្សេងទៀត ជូនមហាសន្និបាតវិសាមញ្ញ។
- លើកសំណើរជូនមហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ ដើម្បីតែងតាំងអគ្គនាយកពិនិត្យមួយរូប ឬច្រើនរូបឱ្យទទួលរ៉ាប់រងការត្រួតពិនិត្យទូទៅប្រចាំឆ្នាំនៅផ្ទៃក្នុងក្រុមហ៊ុន ឬ ស្នើសុំក្រុមហ៊ុន ឬ ស្នើឱ្យដកហូតងារទៅវិញតាមការជាក់ស្តែង។

**គ. ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល ដែលកើតឡើងហើយមិនអាចមានជីវិតជារៀងរហូតនោះទេ តែងតែមានការបញ្ចប់ជីវិតទៅវិញជារឿងធម្មតា។ ការបញ្ចប់តួនាទីរបស់ក្រុមប្រឹក្សាភិបាលនោះមានមូលហេតុជាច្រើន ដូចជា ការមកដល់នូវពេលវេលាដែលបានកំណត់ ការលាលែងរបស់ក្រុមប្រឹក្សាភិបាល ការដកហូត និងតាមករណីផ្សេងៗទៀត។

**២.២.២.២. អភិបាល**

**ក. ការតែងតាំងអភិបាល**

បណ្តាអភិបាល ត្រូវបានជ្រើសរើសតែងតាំងដោយមហាសន្និបាតបង្កើតក្រុមហ៊ុន ឬមហាសន្និបាតសាមញ្ញ។ រូបវន្តបុគ្គលដែលមានអាយុលើសពី ១៨ឆ្នាំ អាចជាម្ចាស់ភាគហ៊ុន ឬតតិយជនពីខាងក្រៅ ឱ្យចូលរួមក្នុងសមាសភាពក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិដែលមានរយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចត្រូវផ្លាស់ប្តូរបានក្នុងចំនួន ១/៣នៃចំនួនសរុបជារៀងរាល់ឆ្នាំតាមរយៈមហាសន្និបាតនៃម្ចាស់ភាគហ៊ុន។ ចំនួនអភិបាលអាចប្រែប្រួលពី ៣.៥.៧.៩ នាក់ ចំនួននេះប្រែប្រួលទៅតាមការរីកចម្រើនរបស់ក្រុមហ៊ុន។ ក្នុងករណីដែលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងមិនបានចែងអំពីអាណត្តិអភិបាលនោះទេ។ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ២ឆ្នាំ ហើយអាចនឹង

ត្រូវបានជ្រើសរើសឡើងវិញបាន ក៏ដូចជាដកហូតមុខងារទៅវិញបានដោយមហាសន្និបាតសាមញ្ញ ឬមហាសន្និបាតវិសាមញ្ញ។[28]

**ខ. តួនាទីរបស់អភិបាល**

អភិបាលមានតួនាទីដូចខាងក្រោម៖

- បង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ចំពោះមហាសន្និបាតប្រចាំឆ្នាំ។
- បង្ហាញរបាយការណ៍របស់សវនករ។
- បង្ហាញការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- ចាត់ចែងការងារប្រចាំថ្ងៃ និងឱ្យស្របទៅនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។

**គ. ការបញ្ចប់តួនាទីរបស់អភិបាល**

អភិបាលអាចត្រូវបានបញ្ចប់តួនាទី ដោយសារ មរណភាព ការសុំលាលែង ការដកហូតងារ ឬការចោទប្រកាន់តាមបណ្ដឹងតុលាការជាដើម។ ក្រុមប្រឹក្សាភិបាលអាចត្រូវចាត់តាំងបង្គ្រប់បណ្ដោះអាសន្ននៅក្នុងខែបន្ទាប់ ឬក្នុងករណី ចំនួនអភិបាលនៅសល់មិនតិចជាង ០៥ រូប។

ប៉ុន្តែការចាត់តាំងនេះ នឹងត្រូវតែទទួលសច្ចាប័នពីមហាសន្និបាតសាមញ្ញលើកក្រោយនេះ។ បើចំនួនអភិបាលថយចុះមកតិចជាង ០៥រូប ក្រុមប្រឹក្សាភិបាលត្រូវកោះអញ្ជើញមហាសន្និបាតសាមញ្ញនៃម្ចាស់ភាគហ៊ុននៅក្នុងខែបន្ទាប់ដូចគ្នា ដើម្បីចាត់តាំងបង្គ្រប់ឡើងវិញ។ អភិបាលម្នាក់ៗ ក៏ដូចជាអ្នកដែលបានចូលរួមដទៃទៀតត្រូវរក្សាការសំងាត់យ៉ាងខ្ពស់ចំពោះព័ត៌មានទិន្នន័យ ឬ ឯកសារសំខាន់ដែលខ្លួនបានដឹង ឬ បានទទួលពីក្រុមប្រឹក្សាភិបាល។

**២.២.២.៣. អគ្គនាយក**

អគ្គនាយក ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាលក្នុងចំណោម ឬក្រៅពីសមាជិករបស់ខ្លួន ប៉ុន្តែជាញឹកញាប់ក្រុមហ៊ុនតែងតែជ្រើសរើសបុគ្គលិកដែលមានសមត្ថភាព មានចំណេះដឹង និងសំបូរបទពិសោធន៍មកពីខាងក្រៅ។ អគ្គនាយកត្រូវទទួលខុសត្រូវលើការគ្រប់គ្រងកិច្ចការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ហើយជានិច្ចជាកាលតំណាងឱ្យក្រុមហ៊ុននៅក្នុងការធ្វើទំនាក់ទំនងជាមួយតតិយជន។ ដោយសារតែច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ផ្សេងៗទៀតមិនបានចែងឱ្យបានច្បាស់ពីតួនាទីរបស់អគ្គនាយក នោះលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាអ្នកធ្វើការកំណត់អំពីបញ្ហានេះ។

## ២.៣ .ការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ការរំលាយក្រុមហ៊ុន គឺជាការបញ្ចប់អត្ថិភាពរបស់ក្រុមហ៊ុនក្នុងនាមជានីតិបុគ្គល។[29] ការរំលាយរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺអាស្រ័យលើស្ថានភាពនៃក្រុមហ៊ុនដែលមានមូលហេតុជាច្រើន

[28] មាត្រា១២០-១២២ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម , ២០០៥

ដូចជា៖

- ការមកដល់នៃពេលវេលា
- ការបញ្ចប់កិច្ចការដែលជាគោលបំណងរបស់ក្រុមហ៊ុន ឬអលទ្ធភាពក្នុងការបំពេញកិច្ចការនោះ
- ការអនុវត្តលក្ខន្តិកៈបានកំណត់ដែលជាមូលហេតុនៃការរំលាយ
- ធនក្ស័យ
- ការរំលាយដោយស្មគ្រ័ចិត្ត ដោយមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន
- ការរំលាយតាមរយៈផ្លូវតុលាការ។

ក្រុមហ៊ុនមិនអាចត្រូវបានរំលាយ ក្នុងករណីដែលមានការកែប្រែស្ថានភាពនៃសមាជិកហ៊ុនឡើយ។ តាមគោលការណ៍នៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គេមានសេរីភាពយ៉ាងពេញលេញក្នុងការផ្ទេរភាគហ៊ុនរបស់គេពោល គឺមិនចាំបាច់ត្រូវមានការអនុញ្ញាតពីសមាជិកផ្សេងៗទៀតឡើយ។ ដូច្នេះមរណភាព ឬអសមត្ថភាពនៃសមាជិកណាម្នាក់ មិនបណ្តាលឱ្យក្រុមហ៊ុនត្រូវរំលាយឡើយ។

### ២.៣.១. ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជី

ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយអាចរំលាយនៅពេលណាក៏បានតាមសេចក្តីសម្រេចរបស់អភិបាលទាំងអស់។ ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិ និងបំណុលអាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះការរំលាយត្រូវធ្វើតាមសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ។ ក្រុមហ៊ុនត្រូវបញ្ជូនសេចក្តីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលបានសេចក្តីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងនៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវចាត់ទុកថា លែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន។ អភិបាល ឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត។ លិខិតជូនដំណឹងស្តីពីការប្រជុំម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬរំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុននោះ។ ក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និង/ឬមានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចពិសេសមួយរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ។

ក្នុងករណីដែលក្រុមហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្តីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មាន

[29] សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់ របស់ក្រសួងពាណិជ្ជកម្ម

សិទ្ធិបោះឆ្នោតទេ ប្រសិនបើៈ

- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុនតាមសេចក្តីសម្រេចពិសេស ឬសេចក្តីសម្រេចសាមញ្ញ។
- ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុនទៅក្រសួងពាណិជ្ជកម្ម។

ក្រោយពីមានការយល់ព្រមលើសេចក្តីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីសម្រេចពីបំណងរំលាយជាទម្រង់លម្អិតទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។

នៅពេលទទួលសេចក្តីសម្រេចប្រកាសពីបំណងរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ។

នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយ ក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្មលើកលែងតែចំពោះការពន្យារចាំបាច់សម្រាប់ការជម្រះបញ្ជី ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុននៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ។

ក្រោយពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវៈ

- ផ្ញើរលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន
- ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់សម្រាប់រយៈពេល០២(ពីរ)សប្តាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀត ដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវៈ

- ប្រមូលទ្រព្យសម្បត្តិ
- រក្សាទុកសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន
- បំពេញកាតព្វកិច្ចទាំងឡាយ
- ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ការជម្រះបញ្ជី

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬជាវត្ថុទៅឱ្យម្ចាស់ហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។ នៅពេលជម្រះបញ្ជីត្រូវបានបញ្ចប់ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន។

សេចក្តីសម្រេចស្តីពីការរំលាយត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន។

បទបញ្ញត្តិពីការរំលាយ និងការជម្រះបញ្ជីខាងលើមិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ។ លិខិតជូនដំណឹង ឬឯកសារផ្សេងៗដែលពាក់ព័ន្ធដល់ការគ្រប់គ្រងក្រុមហ៊ុន ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទទួលយកឯកសារថតចម្លងផ្សេងៗទាំងនោះបាន។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិតដែលមានចែងនៅក្នុងឯកសារស្របច្បាប់។[30]

## ២.៣.២. ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមបញ្ចូលគ្នាជាក្រុមហ៊ុនថ្មីមួយទៀតផ្សេងបាន និងក្រុមហ៊ុនដែលរំលាយហៅថា ក្រុមហ៊ុនដើម ដោយក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថា ក្រុមហ៊ុនថ្មី។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់។ កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី៖

- ចំណុចសំខាន់ៗ និងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម
- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុន ដើមឱ្យទៅជាភាគហ៊ុនមូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម
- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើមមិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ
- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រងព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម។

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ៖

[30] មាត្រា២៥១-២៦២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម,២០០៥

- នៅក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃក្រោយកិច្ចព្រមព្រៀងនេះក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ក្រុមហ៊ុនដើមនីមួយៗ ត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន។

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី(២/៣) នៃក្រុមហ៊ុនដើមនីមួយៗ។

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែកក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬស៊េរីនៃភាគហ៊ុនផ្សេងៗ។ អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ។

នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ៖

- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេត្រូវចូលជាធរមាន
- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលត្រូវបន្តធ្វើអាជីវកម្ម
- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ
- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះនៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម
- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម។

# ជំពូកទី៣

# នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមានពីរប្រភេទគឺ ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា និងការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ប៉ុន្តែដោយយោងតាមអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មាត្រា២នៃអនុក្រឹត្យនេះមានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ មានន័យថា ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតាលែងមានអានុភាពតទៅទៀត ហើយអភិបាលក្រុមហ៊ុនត្រូវចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិញ។ ដោយឡែកយើងខ្ញុំសរសេរខ្លឹមសារត្រង់ចំណុចនៃការចុះបញ្ជីតាមលក្ខខណ្ឌធម្មតានេះឡើង គឺដើម្បីជាសញ្ញាណក្នុងការបកស្រាយនូវប្រភេទនៃនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្ម។

## ៣.១. ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា

ការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា គឺជាការចុះបញ្ជីតាមរយៈក្រសួងពាណិជ្ជកម្មដោយតម្រូវឱ្យអភិបាលក្រុមហ៊ុនដែលបង្កើតអាជីវកម្ម ហើយចង់ឱ្យអាជីវកម្មរបស់ខ្លួនស្របច្បាប់ត្រូវទៅចុះបញ្ជីពាណិជ្ជកម្មនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងករណីដែលមានសាខាចុះបញ្ជីពាណិជ្ជកម្មនៅក្នុងខេត្តរបស់ខ្លួនតាមរយៈការដាក់ពាក្យសុំ។

### ៣.១.១. ការចុះបញ្ជីបង្កើត

រាល់ក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់ ដែលត្រូវបានបង្កើតឡើងហើយបានប្រកបពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។ ដោយយោងទៅតាសៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់ បានកំណត់អំពីនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០៥ ជំហានដូចខាងក្រោម៖ [31]

**ជំហានទី១ នាមករណ៍ក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុនយើងអាចរើសបានតាមការពេញចិត្ត តែមិនត្រូវឱ្យជាន់ឈ្មោះក្រុមហ៊ុនដែលមានរួចហើយនោះទេ អភិបាលត្រូវប្រគល់ឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការស្រាវជ្រាវ និងត្រួតពិនិត្យមើលសិនថា ឈ្មោះនេះមានក្រុមហ៊ុនផ្សេងប្រើប្រាស់ហើយឬនៅ ព្រមទាំងកែប្រែអក្ខរាវិរុទ្ធ ឬសូរស័ព្ទជាភាសាខ្មែរ ទៅតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម។ ប្រសិនបើនាមករណ៍ដែលបានជ្រើសរើសមានច្រើន អ្នកដាក់ពាក្យសុំត្រូវរើសយកនាមករណ៍មួយផ្សេងទៀត។ ប្រការនេះតម្រូវឱ្យធ្វើការពិគ្រោះយោបល់ជាមួយ

[31] សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនិងការប្រកបអាជីវកម្មអនុលោមតាមច្បាប់ របស់ក្រសួងពាណិជ្ជកម្ម

សមាជិកហ៊ុន ឬអភិបាល ប្រសិនបើអ្នកដាក់ពាក្យសុំមិនមានសិទ្ធិក្នុងការជ្រើសរើសនាមករណ៍ផ្សេងនោះទេ។ ដំណើរការនៃការការស្រាវជ្រាវរកនាមករណ៍ប្រើពេលតែ១០នាទី និងចំណាយផ្លូវច្បាប់ត្រឹមតែ ២៥.០០០ (ពីរម៉ឺនប្រាំពាន់)រៀល តែប៉ុណ្ណោះ។[32]

**ជំហានទី២ ឯកសារតម្រូវ និងកម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីក្រុមហ៊ុនមានដូចខាងក្រោម៖**

ឯកសារ៖

| | |
|---|---|
| ១. ពាក្យស្នើសុំគំរូ ក (គំរូមាននៅក្នុងCD ROM) | ៣ ច្បាប់ (២ច្បាប់ដើម ១ច្បាប់ថតចម្លង) |
| ២. អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន ថតចម្លងរបស់ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ | ៣ សន្លឹកសម្រាប់ម្ចាស់ហ៊ុននិងអភិបាលម្នាក់ៗ |
| ៣. រូបថត(៤x៦សម) របស់ម្ចាស់ហ៊ុន និងអភិបាលនីមួយៗ | ៣ សន្លឹក |
| ៤. លិខិតធានាពីធនាគារដែលបញ្ជាក់ថាមានតម្កល់ប្រាក់យ៉ាងតិចស្មើនិងដើមទុនអប្បរមា ៤លានរៀល | ១ ច្បាប់ដើម |
| ៥.លក្ខន្តិកៈ | ៣ ច្បាប់ដើម |

កម្រៃ[33]

| | |
|---|---|
| កម្រៃរដ្ឋបាលចុះបញ្ជីជាផ្លូវការ | ១ ០១០ ០០០រៀល |

**ជំហានទី៣** នៅពេលដែលឯកសារដូចបានរៀបរាប់ខាងលើមានគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី អភិបាល ឬ ម្ចាស់ហ៊ុនណាម្នាក់របស់ក្រុមហ៊ុនត្រូវមកបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើបែបបទនៃ ៣ ក្យសុំមុនពេលចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ ប្រសិនបើពាក្យសុំត្រូវបានធ្វើឡើងនៅសាខាពាណិជ្ជកម្មខេត្ត អភិបាល ឬម្ចាស់ហ៊ុនណាម្នាក់របស់ក្រុមហ៊ុនត្រូវមកបង្ហាញខ្លួននៅសាខាចុះបញ្ជីពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខា លើបែបបទនៃពាក្យសុំមុនពេលចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

**ជំហានទី៤** ដំណើរការនេះចំណាយពេលប្រហែលជា ៥ថ្ងៃនៃថ្ងៃធ្វើការដើម្បីពិនិត្យឯកសារ និងចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មជូនដល់ក្រុមហ៊ុន។ប្រសិនបើពាក្យសុំត្រូវបានធ្វើឡើងនៅសាខាចុះបញ្ជីពាណិជ្ជកម្មខេត្តនោះវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មបណ្ដោះអាសន្ននិងត្រូវចេញជូនក្នុងអំឡុងពេល១០ថ្ងៃ។ វិញ្ញាបន

[32] ប្រកាសលេខ៣៣៣ សហវ-ប្រក ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០២០

[33] លេខរៀងទី១ នៃប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០២០

បត្រចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ននេះមានសុពភាពរយៈពេល ៣០ថ្ងៃ ហើយវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មផ្លូវការនឹងត្រូវចេញជូនក្នុងអំឡុងពេលសុពលភាពនោះ។

**ជំហានទី៥** នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មអាចរៀបចំអោយក្រុមហ៊ុនដែលទើបនឹងចុះបញ្ជីថ្មី ទទួលបានត្រាមួយធ្វើឡើងស្របតាមគំរូដែលបានអនុម័តរបស់ក្រសួងពាណិជ្ជកម្ម។

### ៣.១.២. ការចុះបញ្ជីកែប្រែ

ក្រុមហ៊ុនទទួលមហាខុសត្រូវមានកម្រិត អាចកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬជាស៊េរីដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្តីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង៖[34]

- បន្ថែម កែប្រែ ឬដកហូតនូវសិទ្ធិ បុព្វសិទ្ធិ ការរឹតត្បឹតទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុន
- បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុនតាមប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុននោះ
- បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុនដែលមានសិទ្ធិចំពោះប្រភេទ ឬស៊េរីដែលមានសិទ្ធិ ឬឯកសិទ្ធិស្មើ ឬលើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ
- បង្កើននូវប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬលើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬស៊េរីរបស់អ្នកកាន់កាប់នោះ
- បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬជាឯកសិទ្ធិតូចជាង ឬស្មើ ឬលើសប័ណ្ណភាគហ៊ុន របស់អ្នកកាន់កាប់នោះ ឬ
- បន្ថយគណនីដើមទុនដែលចុះបញ្ជីនៃប្រភេទឬស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ។

(គណនីដើមទុនជាទូទៅ គឺជាផលបូកសរុបនៃតម្លៃចារឹកនៃភាគហ៊ុនទាំងអស់ដែលបានបោះចេញ)

ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថា ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនជាក់លាក់មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយក៏ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុននោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រទេស ឬស៊េរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលកែប្រែដោយផ្ទាល់ ឬដោយប្រយោល ឬប៉ះពាល់ទៅនឹងសិទ្ធិឯកសិទ្ធិ ការរឹតត្បឹត និងលក្ខខណ្ឌទាំងណាដែលភ្ជាប់ទៅនឹងប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់ទាំងនោះ ។ សិទ្ធិក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនេះ មិនត្រូវបានលុបចោល បន្ថយ ឬដាក់កម្រិត ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាមួយផ្សេងទៀតឡើយ។ លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវផ្ញើរជូនទៅម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ២០(ម្ភៃ)ថ្ងៃ មុនពេលបើកមហាសន្និបាត។ លិខិត

[34] លេខរៀងទី១ នៃប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០២០

ជូនដំណឹងនេះ ត្រូវផ្ញើរភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ។ ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ[35] ៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្មឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសារជាថ្មីនូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មីដែលមានលក្ខណៈដាច់ខាត និងលក្ខណៈប្រសើរជាង ឬទាបជាងភាគហ៊ុនដែលមានរួចហើយ
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត។ ដើមទុនចុះបញ្ជីមិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន។ ការបន្ថយដើមទុនមិនត្រូវហួសពី៩០(កៅសិប) ថ្ងៃបន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្នុងក្រសួងពាណិជ្ជកម្ម។ បើក្នុងរយៈពេលនេះមានការតវ៉ាជំទាស់ពីម្ចាស់បំណុលនេះ ត្រូវសងប្រាក់ទាំងស្រុងមុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន។
- ការកែប្រែថិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនកូរ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន

គ្រប់ឯកសារស្តីពីការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេច ព្រមទាំងមានចុះហត្ថលេខារបស់ប្រធានក្រុមប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលណាម្នាក់ដែលទទួលបានសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល។ ឯកសារទាំងនេះត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥(ដប់ប្រាំថ្ងៃ) ក្រោយពីមហាសន្និបាតបានសម្រេច។ពេលទទួលបានឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុនក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបន

[35] មាត្រា២៣៨-២៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម , ២០០៥

បត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ។ ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀតកាលបរិច្ឆេទនោះមិនឱ្យលើសពី៩០(កៅសិប)ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ។

ឯកសារតម្រូវ ដែលត្រូវផ្តល់ជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖[36]

- កំណត់ហេតុ និងសេចក្តីសម្រេចភាពសន្និបាតរបស់ក្រុមហ៊ុន(ច្បាប់ដើម) ០៣ច្បាប់
- ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្តូរ ០៣ច្បាប់
- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ០៣ច្បាប់

(វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណីក្រុមហ៊ុនធ្វើការកែប្រែ នាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន)

- ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ០៣ច្បាប់
- ច្បាប់ចម្លងប្រតិវេទន៍អំពីសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ ០១ច្បាប់
-ច្បាប់ចម្លងប័ណ្ណប៉ាតង់ ០៣ច្បាប់
-ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ ៤x៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ (ក្នុងករណីបន្ថែមសមាជិកភាគហ៊ុនថ្មី)
- ច្បាប់ថតចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ បើសិនជាមាន ០៣ច្បាប់

### ៣.១.៣.ការចុះបញ្ជីរំលាយក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចស្នើដោយស្ម័គ្រចិត្តទៅកាន់ក្រសួងពាណិជ្ជកម្មថា ក្រុមហ៊ុនត្រូវបានរំលាយជាផ្លូវការ មានន័យថាលែងជានីតិបុគ្គលតទៅទៀត។ សេចក្តីស្នើសុំត្រូវដាក់ជូនទៅឱ្យម្ចាស់បំណុល និងម្ចាស់ហ៊ុនសម្រាប់សងបំណុលខ្លះ ឬទាំងអស់របស់ក្រុមហ៊ុនក្នុងរយៈពេលដែលកំណត់ណាមួយ។

ក្នុងដំណាក់កាលនេះ អាចអនុញ្ញាតឱ្យក្រុមហ៊ុនបន្តធ្វើអាជីវកម្មបាន។ ធ្វើដូច្នេះដើម្បីជៀសវាងនូវការបិទក្រុមហ៊ុនតាមរយៈដំណើរការនៃការជម្រះបញ្ជី។

សិទ្ធិរបស់ម្ចាស់បំណុលដែលមានការធានា (ធនាគារជាដើមដែលមានប្រាក់កម្ចីឬប័ណ្ណបំណុល) មិនត្រូវបានប៉ះពាល់ធំដុំនោះទេ។ចំពោះការរំលាយដោយស្មគ្រ័ចិត្ត ក្រុមហ៊ុនត្រូវទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម និងបំពេញបែបបទចាំបាច់មួយចំនួនដើម្បីសុំលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម។

[36] ប្រការ៥ នៃប្រកាសលេខ១២៤ពណ ចបព.-ប្រក ស្តីពីបែបបទនិងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរនិងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ,២០១៥

**ជំហានទី១៖** ប្រសិនបើក្រុមហ៊ុនចង់ដកចេញនូវការចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម តម្រូវឱ្យក្រុមហ៊ុនមានឯកសារមួយចំនួន៖

**ឯកសារតម្រូវ**

| | |
|---|---|
| - ពាក្យស្នើសុំគំរូ ស៊ីឌីរ៉ូម | ០៣ច្បាប់ (២ច្បាប់ដើម,១ច្បាប់ថតចម្លង) |
| - ប័ណ្ណជម្រះបញ្ជីសារពើពន្ធ ចេញដោយនាយកដ្ឋានពន្ធដារ | ០៣ច្បាប់ (១ច្បាប់ដើម,២ច្បាប់ថតចម្លង) |
| - ប្រតិវេទន៍ប្រចាំឆ្នាំស្តីពីសហគ្រាសពាណិជ្ជកម្ម | ០៣ច្បាប់(១ច្បាប់ដើម,២ច្បាប់ថតចម្លង) |
| - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន ឬអភិបាលដែលមានចុះហត្ថលេខា ឬស្នាមមេដៃដែលបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើពាក្យស្នើសុំ | ០៣ច្បាប់ |
| - រូបថតទំហំ (៤x៦cm) របស់ម្ចាស់ហ៊ុន ឬអភិបាលដែលមកបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើពាក្យស្នើសុំ | ០៣សន្លឹក |
| - លក្ខន្តិកៈក្រុមហ៊ុនចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម | ០៣ ច្បាប់ |
| - អាជ្ញាប័ណ្ណអាជីវកម្មចេញដោយក្រសួងពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| - លិខិតស្នើសុំពីក្រុមហ៊ុន | ០១ ច្បាប់ដើម |
| - កំណត់ហេតុរំលាយក្រុមហ៊ុន (របស់ក្រុមប្រឹក្សា និងម្ចាស់ហ៊ុន) | ០១ ច្បាប់ដើម |
| - សេចក្តីសម្រេចរបស់ក្រុមហ៊ុនមេ (ប្រសិនបើពាក់ព័ន្ធ) | ០១ ច្បាប់ដើម |
| សោហ៊ុយ[37] | |
| កម្រៃរដ្ឋបាលផ្លូវការ | ៤៨០ ០០០រៀល |

[37] លេខរៀងទី៣ នៃប្រកាសលេខ ១២១៧ សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០២០

**ជំហានទី២៖** នៅពេលដែលឯកសារទាំងឡាយដូចបានរៀបរាប់ខាងលើត្រូវបានបំពេញគ្រប់គ្រាន់ អភិបាល ឬម្ចាស់ហ៊ុនត្រូវទៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើឯកសារផ្លូវការ មុនពេលចេញវិញ្ញាបនបត្រលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។

**ជំហានទី៣៖** ដំណើរការនេះចំណាយពេល០៥ថ្ងៃនៃថ្ងៃធ្វើការដើម្បីចេញលិខិតអនុញ្ញាត លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។

## ៣.២.ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

យោងតាមអនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលេខ៨៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០ បានកំណត់ថារាល់ការចុះបញ្ជីពាណិជ្ជកម្ម ត្រូវចុះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ហើយការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ អនុវត្តតែចំពោះក្រុមហ៊ុន-សហគ្រាសថ្មីទាំងអស់ដែលទើបតែបង្កើតក្រោយអនុក្រឹត្យនេះបានអនុម័តត្រូវចូលតាមគេហទំព័រថ្មី https://www.registrationservices.gov.kh ដោយយោងទៅតាមសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព៏ត៌មាន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។

ការចុះបញ្ជីអាជីវកម្មមួយអាចពាក់ព័ន្ធជាមួយក្រសួង-ស្ថាប័នច្រើន ប៉ុន្តែជាទូទៅក្រសួង-ស្ថាប័នគោលដែលពាក់ព័ន្ធរួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ដើម្បីដំណើរការអាជីវកម្មបានដោយស្របច្បាប់អ្នកដែលជាម្ចាស់អាជីវកម្មត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម រួចបន្តចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែកអាជីវកម្មមួយចំនួនត្រូវចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថានប័នដទៃបន្ថែមទៀតដែលអាចជាក្រសួងទេសចរណ៍(សម្រាប់ភោជនីយដ្ឋាន) ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (សម្រាប់ក្រុមហ៊ុនសំណង់) និងក្រសួងសុខាភិបាល (សម្រាប់ឱសថស្ថាន ឬមន្ទីរពេទ្យ) ជាដើម។ តាមគោលការណ៍ចាស់ អភិបាលត្រូវទៅចុះបញ្ជីអាជីវកម្មរបស់ខ្លួននៅក្រសួង-ស្ថានប័នផ្សេងៗគ្នា និងតាមនីតិវិធីខុសៗគ្នា។ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំច្រើនដង ទម្រាំក្រសួង-ស្ថាប័ននីមួយៗផ្តល់ការអនុញ្ញាត។ ចំណែកប្រព័ន្ធចុះបញ្ជីរបស់ក្រសួង-ស្ថាប័ននីមួយៗមានលក្ខណៈដាច់ដោយឡែកពីគ្នា និងមិនអាចផ្សារភ្ជាប់ ផ្លាស់ប្តូរទិន្នន័យគ្នាបាន ដែលតម្រូវឱ្យអ្នកបំពេញព័ត៌មានដដែលៗលើពាក្យស្នើសុំផ្សេងគ្នានៅក្រសួង-ស្ថាប័នផ្សេងគ្នា។

សម្រាប់ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានថ្មីនេះ អ្នកអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅថ្នាលបច្ចេកវិទ្យាព័ត៌មានតែមួយ។ ដោយឡែកក្នុងដំណាក់កាលដំបូងនេះ ការចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃ ក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ នឹងតម្រូវឱ្យអ្នកធ្វើ

តាមនីតិវិធីដដែលរបស់ក្រសួង-ស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលយ៉ាងយូរ ០៨ថ្ងៃនៃថ្ងៃធ្វើការនិងត្រូវបង់សេវាតិចជាងមុន។ អភិបាលក៏អាចទូទាត់សងប្រាក់សេវាទាំងអស់ក្នុងការចុះបញ្ជីពាណិជ្ជកម្មតាមអនឡាញដោយប្រើប្រាស់សេវា ABA Pay សម្រាប់អតិថិជនធនាគារឌ្បនៈអាស៊ីចំកាត់ (ABA) និងតាមកាតឥណទាន ឬកាតឥណពន្ធសម្រាប់អតិថិជនធនាគារផ្សេងទៀត។ ក្រោយការចុះបញ្ជីពាណិជ្ជកម្មជោគជ័យអភិបាលនឹងទទួលបានអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។ ការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បី ចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា។[38]

❖ នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន




### ៣.២.១.ការចុះបញ្ជីបង្កើត

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ការចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានតម្រូវឱ្យមានឯកសារដូចជា៖

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម

[38] មាត្រា១ នៃអនុក្រឹត្យលេខ៨៤ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន , ២០២០

- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃក្រោយពណ៌សរបស់អភិបាល ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- ឯកសារអត្តសញ្ញាណប័ណ្ណរបស់អភិបាល ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- លក្ខន្តិកៈក្រុមហ៊ុន
- ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល
    - លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ
    - វិញ្ញាបនបត្រក្រុមហ៊ុនមេ
    - លក្ខន្តិកៈក្រុមហ៊ុនមេ
- លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

រាល់ឯកសារភ្ជាប់ទាំងអស់ត្រូវស្កិតក្នុងទម្រង់ PDF រីឯរូបថតត្រូវស្កិតក្នុងទម្រង់JPG ឬJPEG ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។ សូមបញ្ជាក់ថា ប្រសិនបើអភិបាលមិនផ្តល់ឯកសារ ឬព័ត៌មានមិនគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងពេលអភិបាលចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់យើង អាចនឹងប្រឈមការបដិសេធលើសំណើរចុះបញ្ជី។ ក្នុងករណីនេះ រាល់ការចំណាយដែលបានធ្វើឡើងលើប្រព័ន្ធនេះនឹងមិនមានការធានាចំពោះការប្រគល់ប្រាក់ជូនវិញនោះទេ។

- **ការបម្រុងទុកនាមករណ៍**

អភិបាលក្រុមហ៊ុនអាចបម្រុងនាមករណ៍ក្រុមហ៊ុនតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដោយគ្រាន់តែLog In ចូលទំព័រ Portal រួចចុចប៊ូតុង "បម្រុងទុកនាមករណ៍ក្រុមហ៊ុន" រួចចុចប៊ូតុង "បង្កើតនាមករណ៍បម្រុងទុក" ដើម្បីបំពេញទម្រង់បែបបទជាការស្រេច។ ក្នុងករណីចង់បម្រុងទុកនាមករណ៍ស្រដៀងគ្នាទៅនឹងនាមករណ៍របស់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចអ្នកត្រូវភ្ជាប់លិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ ប្រសិនបើមាន។

ក្នុងករណីដែលនាមករណ៍នោះអាចប្រើប្រាស់បាន អភិបាលក្រុមហ៊ុនត្រូវទូទាត់កម្រៃសេវា នៃការបម្រុងទុកនាមករណ៍ដូចមានចែងនៅក្នុងប្រកាសរួមអន្តរក្រសួងនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីអំពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពណិជ្ជកម្ម ក្នុងឧបសម្ព័ន្ធលេខរៀងទី១៤ ចំណុច "ឆ" ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស ត្រូវបង់កម្រៃសេវាចំនួន ២៥០០០ (ពីរម៉ឺនប្រាំពាន់)រៀល រយៈពេលអតិបរមានៃការផ្តល់សេវាត្រឹមតែ០១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ និងមានសុពលភាពរយៈពេល០៣(បី)ខែ។[39]

[39] លេខរៀងទី១៤"ឆ" នៃប្រកាសលេខ ១២១៧ សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០១៧

ដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានចែកចេញជា ៦ជំហានធំៗ[40]




**ជំហានទី១ ៖** ការបង្កើតគណនី CamDigiKey App

CamDigiKey គឺជាកម្មវិធីទូរស័ព្ទសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ QR Code របស់រាជរដ្ឋាភិបាលកម្ពុជា ដែលភ្ជាប់អ្នកប្រើប្រាស់ទៅសេវាកម្មរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា។

ការបង្កើតគណនី CamDigiKey App មានដំណើរការ ដូចជា៖

- ដោនឡូត CamDigiKey App ពី App Store ឬ PlayStore លើទូរស័ព្ទដៃរបស់អ្នក។
- ចូលទៅកាន់ CamDigiKey App រួចចុចប៊ូតុង "**ចុះឈ្មោះ**"។
- បញ្ចូលលេខទូរស័ព្ទដៃរបស់អ្នកទៅក្នុង App នោះលេខកូដស្វ័យប្រវត្តិនឹងត្រូវបានផ្ញើទៅកាន់លេខទូរស័ព្ទដៃរបស់អ្នក។
- បង្កើតលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់។
- បំពេញព័ត៌មានអត្តសញ្ញាណរបស់អ្នក។
- បំពេញថ្ងៃខែឆ្នាំកំណើត ភេទ និងទីកន្លែងកំណើត។
- បំពេញអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។
- បំពេញព័ត៌មានអត្តសញ្ញាណប័ណ្ណ(សម្រាប់សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន(សម្រាប់សញ្ជាតិបរទេស)។
- វាយលេខកូដមួយផ្សេងទៀតដែលបានផ្ញើទៅកាន់សារអេឡិចត្រូនិចរបស់អ្នកទៅក្នុង App ដើម្បីបញ្ជាក់សារអេឡិចត្រូនិចរបស់អ្នក។
- បញ្ចូលរូបថត អត្តសញ្ញាប័ណ្ណ ឬលិខិតឆ្លងដែនរបស់លោកអ្នក។
- ចុច "**រូបថត**" រួចថតរូបរបស់លោកអ្នក។
- រង់ចាំយ៉ាងយូរ ២៤ម៉ោងសម្រាប់ការត្រួតពិនិត្យ។
- អ្នកបានបង្កើតគណនី CamDigiKey ដោយជោគជ័យ។

[40] សៀវភៅមគ្គុទេសក៍ ស្តីពីដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន , ២០២០

**ជំហានទី២ ៖** ការ Log In ចូល Portal

ចូលទៅតំណ www.registrationservices.gov.kh លើកុំព្យូទ័ររបស់អ្នក រួចចុចលើប៊ូតុង "**ចុះបញ្ជីពាណិជ្ជកម្ម**" នៅជ្រុងខាងស្តាំផ្នែកខាងលើនៃគេហទំព័រ។ ការ Log In ចូល Portal មានដំណើរដូចខាងក្រោម៖

- បន្ទាប់ពីបានចូលទៅក្នុងតំណ www.registrationservices.gov.kh រួចមក អភិបាលត្រូវចុចប៊ូតុង "**ទាញយក QR Code**"។
- ស្កេន QR Code ដែលអ្នកឃើញជាមួយនឹង CamDigiKey App នៅលើទូរស័ព្ទដៃរបស់អ្នក។
- បញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន០៦ខ្ទង់ដែលបានបង្កើតក្នុង CamDigiKey App ទៅក្នុង CamDigiKey App នោះអ្នកនឹងចូលកាន់ទំព័រ Portal ចុះបញ្ជីអាជីវកម្មក្នុងកុំព្យូទ័រដោយស្វ័យប្រវត្តិ។

**ជំហានទី៣ ៖** ដំណើរការចុះបញ្ជីពាណិជ្ជកម្ម

បន្ទាប់ពីបាន Log In ចូល Portal រួចមកអភិបាលក្រុមហ៊ុនអាចចុះបញ្ជីពាណិជ្ជកម្មដូចខាងក្រោម៖

- ចុចប៊ូតុង "**ចុះបញ្ជីអាជីវកម្ម**"។
- ជ្រើសរើសទម្រង់សហគ្រាស "**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**" រួចបំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "**ចុះបញ្ជីពាណិជ្ជកម្ម**" រួចចុច "**បន្ទាប់**"។
- បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "**ចុះបញ្ជីពន្ធដារ**" រួចចុច "**បន្ទាប់**"។
- បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "**សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស**" រួចចុច "**បន្ទាប់**"។
- ពិនិត្យព័ត៌មាន និងឯកសារឡើងវិញរួចចុចប៊ូតុង "**ដាក់ស្នើ**"។

**ជំហានទី៤ ៖** ការទូទាត់សងប្រាក់

ការទូទាត់តម្រៃសេវាចុះបញ្ជីពាណិជ្ជកម្មមានចំនួន ១.០១០.០០០រៀល អតិបរមានៃការផ្តល់សេវាមានរយៈចំនួន ៣-៧ ថ្ងៃនៃថ្ងៃធ្វើការ និងមានសុពលភាពរយៈពេល៩៩ឆ្នាំ។[41] ដំណើការនៃកាទូទាត់សងប្រាក់មានដូចខាងក្រោម៖

- ជ្រើសរើសជម្រើសទូទាត់សងប្រាក់មួយ ដែលក្នុងនោះមាន ABA Pay និងការទូទាត់តាមរយៈកាតឥណទាន ឬកាតឥណពន្ធ។
- ក្នុងករណីទូទាត់ប្រាក់តាម ABA Pay,
  - អ្នកនឹងឃើញ QR Code នៅលើអេក្រង់កុំព្យូទ័រ

[41] ប្រកាសអន្តរក្រសួងលេខ៣៣៣ សហវ-ប្រក ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ,២០២០

- ចូលទៅកាន់ABA Mobile App រួច log in គណនីធនាគារ ABA របស់អ្នកលើទូរស័ព្ទដៃ
- ចុចប៊ូងតុង "**ស្កេន QR**" នៅលើ ABA Mobile App
- ស្កេន QR Code ដែលបង្ហាញនៅលើអេក្រង់កុំព្យូទ័រជាមួយទូរស័ព្ទដៃរបស់អ្នក
- ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។

- ក្នុងករណីទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធ (Visa, Master Card ឬUnion Pay International)
  - បំពេញព័ត៌មានគណនីរបស់អ្នក រួចចុចប៊ូតុង "ដាក់ស្នើ"
  - ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។

**ជំហានទី៥ ៖** ការពិនិត្យស្ថានភាព និង ទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

- ពេល log in ចូលទំព័រ Portal ចុច "**ក្រុមហ៊ុនរបស់ខ្ញុំ**"
- ចុចលើក្រុមហ៊ុនណាមួយដែលអ្នកចង់តាមដានស្ថានភាពសំណើ នោះអ្នកនឹងឃើញមានការបញ្ជាក់ពីស្ថានភាពសំណើលម្អិត។

**ជំហានទី៦ ៖** ការទទួលបានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រឌីជីថល

បន្ទាប់ពីបានឃើញព័ត៌មានលម្អិតរបស់ក្រុមហ៊ុន សូមចុច"**ទាញយក**"នៅក្នុងផ្នែកវិញ្ញាបនបត្រ។

### ៣.២.២. ការចុះបញ្ជីកែប្រែ

ដោយយោងតាមសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០២០បានបញ្ជាក់ថាដោយឡែកចំពោះការតម្កល់ប្រតិវេទន៍ ការចុះបញ្ជីកែប្រែរបស់ក្រសួងពាណិជ្ជកម្មនៅរក្សាប្រើប្រាស់ក្នុងគេហទំព័រ www.businessregistration.moc.gov.kh ដដែល។

ដើម្បីចុះបញ្ជីកែប្រែក្រុមហ៊ុន អភិបាលក្រុមហ៊ុនឬសហគ្រាសត្រូវចូលទៅក្នុងគណនីរបស់ក្រសួងពាណិជ្ជកម្ម www.businessregistration.moc.gov.kh ដដែលរួចចុចពាក្យថា Log On(ចូល) ដើម្បីបំពេញឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់ដើម្បីចូលទៅក្នុងប្រព័ន្ធរបស់ក្រសួងក្នុងគោលបំណងផ្លាស់ប្តូរកែប្រែក្រុមហ៊ុន ឬសហគ្រាស។ ការចុះបញ្ជី កែប្រែក្រុមហ៊ុន ឬសហគ្រាសមានដូចជា៖

- **ការប្តូរនាមករណ៍ក្រុមហ៊ុន**

ចំពោះអភិបាលក្រុមហ៊ុនដែលមានគោលបំណងផ្លាស់ប្តូរ និងកែប្រែក្រុមហ៊ុន ឬសហគ្រាស ក្រោយពេលបាន Log On(ចូល) ចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មរួចហើយមកអភិបាលក្រុមហ៊ុនត្រូវជ្រើសរើសក្រុមហ៊ុន ឬសហគ្រាសដែលខ្លួនមានបំណងផ្លាស់ប្តូរ និងកែប្រែ។ បន្ទាប់មកចុចពាក្យថា "ប្តូរនាម

ករណ៍ក្រុមហ៊ុន" ប្រសិនបើអភិបាលក្រុមហ៊ុនបានបម្រុងទុកនាមករណ៍រួចរាល់ហើយ សូមចុចប្រអប់ពីមុខពាក្យថា "ជ្រើសរើសនាមករណ៍បម្រុងទុក" ប៉ុន្តែប្រសិនបើអភិបាលក្រុមហ៊ុនពុំទាន់បានបម្រុងទុកនាមករណ៍ទេ ត្រូវបំពេញនាមករណ៍ថ្មី។ នាមករណ៍ភាសារអង់គ្លេសត្រូវច្បាស់ថា វាបានបញ្ចប់ដោយពាក្យដែលបញ្ជាក់ពីប្រភេទក្រុមហ៊ុន (ឧទាហរណ៍៖ ACELEDA PLC ) បន្ទាប់មកពាក្យថា "សុពលភាពនាមករណ៍" រួចជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច ហើយចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល" ចំពោះព័ត៌មានបន្ថែមស្តីពីឯកសារភ្ជាប់ សូមអានប្រកាសលេខ១៤២ ព.ណ.ច.ប.ព.ប្រ.ក ស្តីពីបែបបទ និងនិតិវិធីចុះបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។ បន្ទាប់មកចុចពាក្យ "រក្សាទុក និងចាកចេញ" ប្រសិនបើមានចំណុចណាមួយដែលអភិបាលក្រុមហ៊ុនត្រូវធ្វើការពិចារណាហើយប្រព័ន្ធនឹងធ្វើការរក្សាទុកព័ត៌មានកំពុងស្នើសុំនេះរយៈពេល១៥ថ្ងៃ។ ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែ។ តម្លៃសេវាក្នុងការចុះបញ្ជីកែប្រែនាមករណ៍ អភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០.០០០ (ពីររយសែសិបពាន់) រៀល និងរយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។[42]

- **ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន**

អភិបាលក្រុមហ៊ុនត្រូវចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួង រួចចូលទៅក្នុងទំព័រមុខងារបង្ហាញព័ត៌មានលម្អិតក្រុមហ៊ុនក្នុងស្រុករួចបន្តអនុវត្តនិតិវិធីដូចខាងក្រោម៖

- ចុចពាក្យថា "កែប្រែលក្ខន្តិកៈក្រុមហ៊ុន" បន្ទាប់មកចុចពាក្យថា "លុបឯកសារ"
- បន្ទាប់មកចុចពាក្យថា "បញ្ចូល" នៅត្រង់ពាក្យថា "អនុស្សារណៈ/លក្ខន្តិកៈ"
- ជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច រួចចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្តីសម្រេចក្រុមប្រឹក្សាភិបាល"
- សូមចុចប្រអប់ពីមុខពាក្យថា៖ ខ្ញុំសូមប្រកាសថាព័ត៌មានដែលបានបំពេញក្នុងសំណើនេះ និងឯកសារភ្ជាប់ទាំងអស់ពិតជាត្រឹមត្រូវពិតប្រាកដ។ ក្រសួងពាណិជ្ជកម្មអាចនឹងធ្វើការលុបសហគ្រាសពីបញ្ជីពាណិជ្ជកម្ម ប្រសិនបើមានការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ឬក្លែងបន្លំ
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យថា "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម។ តម្លៃសេវាក្នុងការចុះបញ្ជីកែប្រែនាមករណ៍ អភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០.០០០(ពីររយសែសិបពាន់)រៀល និងរយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។[43]

[42] លេខរៀងទី៦ នៃប្រកាសលេខ១២១៧សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០១៧

[43] លេខរៀងទី៦ នៃប្រកាសលេខ១២១៧សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០១៧

❖ **ការកែប្រែសកម្មភាពអាជីវកម្ម**

អភិបាលក្រុមហ៊ុនទាំងឡាយណា ដែលមានគោលបំណងក្នុងការកែប្រែសកម្មភាពអាជីវកម្មនៃក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- បន្ទាប់ពីអភិបាលក្រុមហ៊ុន ឬសហគ្រាសបានចូលទៅក្នុងប្រព័ន្ធរបស់ក្រសួងពាណិជ្ជកម្មរួច ហើយ អភិបាលក្រុមហ៊ុនត្រូវចូលប្រព័ន្ធក្នុងទំព័រសកម្មភាពអាជីវកម្មរួចចុចពាក្យថា "កែប្រែសកម្មភាពអាជីវកម្ម"
- ចុចប្រអប់ពីមុខពាក្យថា "បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ" ប្រសិនបើកម្មវត្ថុអាជីវកម្មដូច ឬ ប្រហាក់ប្រហែលនឹងកម្មវត្ថុអាជីវកម្មលើបណ្ណប៉ាតង់ បន្ទាប់មកចុចពាក្យថា "បញ្ចូល"
- បន្ទាប់មកចុចពាក្យថា "លុបឯកសារ" នៅត្រង់ពាក្យថា "បណ្ណប៉ាតង់" ហើយបញ្ចូលជំនួសវិញនូវបណ្ណប៉ាតង់ថ្មី
- សូមចុចពាក្យថា "ដកចេញ" ប្រសិនបើចង់លុបកម្មវត្ថុអាជីវកម្មមួយចេញ
- សូមចុចពាក្យ "បន្ថែមសកម្មភាពអាជីវកម្មចម្បង" ប្រសិនបើចង់បន្ថែមកម្មវត្ថុអាជីវកម្មមួយទៀត
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្តីសម្រេចម្ចាស់ហ៊ុន"
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ តម្លៃសេវានៃការចុះបញ្ជីកែប្រែសកម្មភាពអាជីវកម្មអភិបាលក្រុមហ៊ុនត្រូវបង់ប្រាក់ចំនួន ២៤០,០០០(ពីរសែនបួនម៉ឺន)រៀល និង រយៈពេលអតិបរមានៃការផ្តល់សេវាមានចាប់ពី៣-៧ថ្ងៃ។[44]

❖ **ការបន្ថយដើមទុន**

ការបន្ថយដើមទុនត្រូវធ្វើឡើងតាមនីតិវិធីដូចខាងក្រោម៖

- សូមចុចពាក្យ "បន្ថយដើមទុន"
- បន្ទាប់មកសូមចុចពាក្យថា"បន្ថយតម្លៃចារឹកលើប័ណ្ណ" ប៉ុន្តែមិនអាចបន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយ
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច
- សូមចុចពាក្យថា "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្តីសម្រេចម្ចាស់ហ៊ុន និងកំណត់ហេតុអង្គប្រជុំ"

[44] លេខរៀងទី៦ ប្រកាសលេខ១២១៧សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម២០១៧,

- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ អភិបាលក្រុមហ៊ុនត្រូវទូទាត់កម្រៃសេវាលើការបន្ថយដើមទុន ចំនួន ៨០០.០០០(ប្រាំបីរយពាន់)រៀល រយៈពេលអតិបរមានៃការផ្ដល់សេវាចាប់ពី៣-៧ថ្ងៃ នៃថ្ងៃធ្វើការ។[45]

❖ **អាសយដ្ឋាន**

ប្រសិនបើអភិបាលក្រុមហ៊ុនមានបំណងចង់ធ្វើការកែប្រែអាសយដ្ឋានរបស់ក្រុមហ៊ុន ឬសហគ្រាស ត្រូវចុចពាក្យដូចខាងក្រោម៖

- សូមចុចពាក្យថា "កែប្រែព័ត៌មានលម្អិតអាសយដ្ឋានទីស្នាក់ការចុះបញ្ជី"
- សូមចុចពាក្យថា "Change(ផ្លាស់ប្ដូរ)" ប្រសិនបើអភិបាលក្រុមហ៊ុនមានបំណងកែប្រែអាសយដ្ឋានទីស្នាក់ការចុះបញ្ជី ឬអាសយដ្ឋានទីស្នាក់ការចុះបញ្ជីតាមប្រៃសណីយ៍
- បន្ទាប់មកបំពេញ "អាសយដ្ឋានទីស្នាក់ការចុះបញ្ជីថ្មី"
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "ឯកសារបញ្ជាក់អាសយដ្ឋាន (ឯកសារទាំងនោះមានដូចជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ កម្មសិទ្ធិដីធ្លី កិច្ចសន្យាជួលផ្ទះ-អាគារ ឬវិក័យបត្រទឹក-ភ្លើង)"
- សូមជ្រើសរើសកាលបរិច្ឆេទចាប់ផ្ដើម
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយចុចពាក្យ "យល់ព្រម"
- សូមបំពេញ "អ៊ីមែល និងលេខទូរស័ព្ទទំនាក់ទំនង" ប្រសិនបើមានបំណងកែប្រែ
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្ដីសម្រេច
- សូមចុចពាក្យបញ្ចូលនៅត្រង់ពាក្យថា "សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល"
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយសូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ ការទូទាត់កម្រៃលើការកែប្រែអាសយដ្ឋានមានចំនួន ២៤០.០០០ (ពីររយសែសិបពាន់)រៀល រយៈពេលអតិបរមានៃការផ្ដល់សេវាចាប់ពី ៣-៧ថ្ងៃនៃថ្ងៃធ្វើការ។[46]

❖ **ការកែប្រែព័ត៌មានលម្អិតអភិបាល**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានគោលបំណងដើម្បីធ្វើការកែប្រែព័ត៌មានលម្អិតអភិបាល ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ដើម្បីបញ្ឈប់អភិបាលណាម្នាក់សូមចុចពាក្យ "បញ្ឈប់អភិបាល"
- សូមជ្រើសរើសកាលបរិច្ឆេទឈប់ដំណើរការរបស់អភិបាល

[45] លេខរៀងទី៥ ប្រកាសលេខ១២១៧សហវ-ប្រក ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម , ២០១៧

[46] លេខរៀងទី៦ ប្រកាសលេខ១២១៧សហវ-ប្រក ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, ២០១៧

- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "យល់ព្រម"
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "យល់ព្រម"
- សូមចុចពាក្យ "កែតម្រូវ" ប្រសិនបើមានបំណងកែប្រែព័ត៌មានលម្អិតអភិបាលឬធ្វើបច្ចុប្បន្នភាពលិខិតបញ្ជាក់អត្តសញ្ញាណ
- ដើម្បីបន្ថែមអភិបាលណាម្នាក់សូមចុចពាក្យ "បន្ថែមអភិបាល"
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្ដីសម្រេច
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្ដីសម្រេចម្ចាស់ហ៊ុន និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល"
- សូមចុចប្រអប់ពីមុខពាក្យថា "ខ្ញុំបាទ/នាងខ្ញុំ" សូមប្រកាសថាពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការក្នុងក្រសួងស្ថាប័នរដ្ឋណាមួយនៃព្រះរាជាណាចក្រកម្ពុជា

  ឡើយ។
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យថា "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។ ការទូទាត់តម្លៃចំពោះការផ្លាស់ប្ដូរព័ត៌មានលម្អិតរបស់អភិបាលមានចំនួន ២៤០.០០០ (ពីររយសែសិបពាន់)រៀល រយៈពេលអតិបរមានៃការផ្ដល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។[47]

❖ **ភាគហ៊ុន និងម្ចាស់ភាគហ៊ុន**

ការផ្លាស់ប្ដូរ ឬការកែប្រែព័ត៌មានទាក់ទងជាមួយនឹងភាគហ៊ុន និងម្ចាស់ភាគហ៊ុនត្រូវបានបែងចែកជា៣ប្រភេទគឺ៖ ការបង្កើនដើមទុន ការកែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន ការផ្ទេរភាគហ៊ុន។

- **ការបង្កើនដើមទុន**

ដើម្បីធ្វើការបង្កើនដើមទុន អភិបាលក្រុមហ៊ុនត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

- សូមចុចពាក្យថា "កែប្រែម្ចាស់ហ៊ុន"
- សូមចុចពាក្យថា "បង្កើនដើមទុន"
- បន្ទាប់មកចុចពាក្យ "កែតម្រូវម្ចាស់ហ៊ុន"
- យើងអាចបន្ថែមចំនួនភាគហ៊ុនថ្មីដើម្បីបង្កើនដើមទុនដោយរក្សាតម្លៃចារឹកលើប័ណ្ណនៅដដែល

ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "រក្សាទុកម្ចាស់ហ៊ុន"

- សូមចុចពាក្យ "បន្ថែមម្ចាស់ហ៊ុន" ប្រសិនបើមានបំណងបន្ថែមម្ចាស់ហ៊ុន ដោយបង្កើនចំនួនភាគហ៊ុន

[47] លេខរៀងទី៦ ប្រកាសលេខ ១២១៧សហវ-ប្រក ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, ២០១៧

- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្ដីសម្រេច
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្ដីសម្រេចម្ចាស់ហ៊ុន និងកំណត់ហេតុអង្គប្រជុំ"
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម។ ការទូទាត់កម្រៃនៃការបង្កើនដើមទុនមានចំនួន៨០០.០០០ (ប្រាំបីរយពាន់) រៀល រយៈពេលអតិបរមានៃការផ្ដល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។

- **ការកែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន**

- សូមចុចពាក្យ "កែប្រែម្ចាស់ហ៊ុន"
- សូមចុចពាក្យ "កែប្រែព័ត៌មានលម្អិតម្ចាស់ហ៊ុន"
- សូមចុចពាក្យ "កែតម្រូវម្ចាស់ហ៊ុន" ប្រសិនបើមានបំណងកែប្រែព័ត៌មានម្ចាស់ហ៊ុន ឬធ្វើបច្ចុប្បន្នភាពលិខិតបញ្ជាក់អត្តសញ្ញាណ
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្ដីសម្រេច
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល"

ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។

- **.ការផ្ទេរភាគហ៊ុន**

- សូមចុចពាក្យ "កែប្រែម្ចាស់ហ៊ុន"
- សូមចុចពាក្យ "ផ្ទេរភាគហ៊ុន"
- សូមជ្រើសរើសកាលបរិច្ឆេទឈប់ដំណើរការ
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "យល់ព្រម"
- សូមចុចពាក្យ "កែតម្រូវម្ចាស់ហ៊ុន" ប្រសិនបើមានបំណងកែប្រែចំនួនភាគហ៊ុនរបស់ម្ចាស់ហ៊ុនណាម្នាក់
- សូមបំពេញចំនួនភាគហ៊ុនថ្មី បន្ទាប់ពីការផ្ទេរភាគហ៊ុនរបស់ម្ចាស់ហ៊ុនណាម្នាក់
- ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "រក្សាទុកម្ចាស់ហ៊ុន"
- សូមចុចពាក្យ "បន្ថែមម្ចាស់ហ៊ុន" ប្រសិនបើមានបំណងបន្ថែមសមាជិកភាគហ៊ុន
- សូមជ្រើសរើសកាលបរិច្ឆេទនៃសេចក្ដីសម្រេច
- សូមចុចពាក្យ "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្ដីសម្រេចម្ចាស់ហ៊ុន"ប្រសិនបើព័ត៌មានទាំងអស់ត្រឹមត្រូវហើយ សូមចុចពាក្យ "ដាក់ស្នើ" ដើម្បីបន្តទៅធ្វើការទូទាត់កម្រៃសេវាចុះបញ្ជីកែប្រែពាណិជ្ជកម្ម។

- ការទូទាត់កម្រៃនៃការផ្ទេរភាគហ៊ុនមានចំនួន ៨០០.០០០(ប្រាំបីរយពាន់)រៀល មានរយៈពេលអតិបរមានៃការផ្តល់សេវាចាប់ពី៣-៧ថ្ងៃនៃថ្ងៃធ្វើការ។[48]

## ៣.៣. អានុភាពនៃការចុះបញ្ជីពាណិជ្ជកម្ម

### ៣.៣.១.ចំពោះការចុះបញ្ជីបង្កើត

ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម។[49] មានន័យថា ក្រុមហ៊ុនត្រូវបានក្លាយជានីតិបុគ្គលស្របច្បាប់ ហើយធ្វើអាជីវកម្មដោយស្របច្បាប់ និងទទួលបានការការពារដោយច្បាប់នៅពេលមានជម្លោះ ឬក៏បញ្ហាណាមួយដែលកើតឡើងជាយថាហេតុ។ ហើយក្រុមហ៊ុននឹងមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ ហើយអាចប្រកបពាណិជ្ជកិច្ចនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[50] ក្រុមហ៊ុនអាចធ្វើពាណិជ្ជកិច្ចក្រៅប្រទេសបាន លុះត្រាតែប្រទេសនោះផ្តល់ការអនុញ្ញាត។

### ៣.៣.២.ចំពោះការចុះបញ្ជីកែប្រែ

ការចុះបញ្ជីកែប្រែនាំឱ្យមានអានុភាពទៅលើ៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសាជាថ្មីនូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើបណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត
- ការកែប្រែចិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនកូរ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលអនុញ្ញាតឱ្យដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន

[48] លេខរៀងទី៥ ប្រកាសលេខ១២១៧ សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម,២០១៧

[49] មាត្រា ៩៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម,២០០៥

[50] មាត្រា ៩៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, ២០០៥

- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់។

**៣.៣.៣.ចំពោះការចុះបញ្ជីរំលាយក្រុមហ៊ុន**

ការចុះបញ្ជីរំលាយក្រុមហ៊ុននាំឱ្យមានអានុភាព ដូចខាងក្រោម ៖

- មានការជម្រះបញ្ជី និងចែកចំណែក ដោយ
- ក្រុមហ៊ុនត្រូវបានក្រសួងពាណិជ្ជកម្មលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម
- ក្រុមហ៊ុនលែងមានអត្ថិភាពជានីតិបុគ្គល
- សិទ្ធិ និងកាតព្វកិច្ចរបស់ ក្រុមហ៊ុនត្រូវបានបញ្ចប់។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ ដែលទាក់ទងនឹងការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះយើងសង្កេតឃើញថា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ជាក្រុមហ៊ុនដែលមានទ្រង់ទ្រាយធំ និងមានសមាជិកចាប់ពី២នាក់ឡើងទៅ។ ចំពោះដើមទុនសម្រាប់បង្កើតវិញ គឺត្រឹមតែ ២០ (ម្ភៃ) លានរៀល ហើយសមាជិកម្នាក់ៗ ត្រូវទទួលខុសត្រូវសងសំណងលើទ្រព្យដែលខ្លួនបានដាក់បញ្ចូលគ្នាតែប៉ុណ្ណោះ នៅពេលចុះបញ្ជីពាណិជ្ជកម្មតែប៉ុណ្ណោះ។ រាល់ក្រុមហ៊ុនពាណិជ្ជកម្មត្រូវតែចុះបញ្ជីជាមុនសិន មុននឹងដំណើរការអាជីវកម្មរបស់ខ្លួនជាដាច់ខាត ដោយយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មមានពីរ គឺការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា(នីតិវិធីចាស់) និងការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(នីតិវិធីថ្មី) ។

ចំពោះនីតិវិធីនៃការចុះបញ្ជីតាមលក្ខខណ្ឌធម្មតា គឺការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ហើយដើម្បីអាចចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានត្រូវមានពាក្យស្នើសុំ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ រូបថតរបស់ម្ចាស់ហ៊ុន និងអភិបាល ជាពិសេសលក្ខន្តិកៈក្រុមហ៊ុនផងដែរ។ ប្រសិនជាអភិបាលបានបំពេញសំណុំបែបបទរួចរាល់អស់ហើយ និងបានបង់កម្រៃសេវាដែលច្បាប់បានកំណត់ ហើយនោះមិនមានអ្វីខុសដែលត្រូវកែទេ ក្រសួងនឹងចេញវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ ហើយប្រសិនបើអភិបាលចង់ធ្វើការចុះបញ្ជីកែប្រែទៅលើចំណុចណាមួយ ដូចជាកម្មវត្ថុពាណិជ្ជកម្ម ដើមទុន ម្ចាស់ភាគហ៊ុនជាដើម គ្រាន់តែដាក់ពាក្យសុំទៅក្រសួងពាណិជ្ជកម្ម រួចហើយបំពេញសំណុំបែបបទ និងបង់កម្រៃសេវាទៅតាមអ្វីដែលក្រសួងបានកំណត់ជាការស្រេចក្រសួងនឹងចេញវិញ្ញាបនបត្របញ្ជាក់ពីការកែប្រែចំពោះក្រុមហ៊ុននោះ។ ហើយប្រសិនបើក្រុមហ៊ុនចង់បញ្ឈប់សកម្មភាពពាណិជ្ជកម្មរបស់ខ្លួនដោយសារក្ស័យធន ឬដល់ពេលកំណត់ដែលបានកំណត់នៅក្នុងលក្ខន្តិកៈជាដើម ក្រុមហ៊ុនអាចដាក់ពាក្យស្នើសុំទៅក្រសួងពាណិជ្ជកម្ម ដើម្បីឱ្យក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុនដោយការបំពេញសំណុំបែបបទ និងបង់កម្រៃសេវា។

ចំពោះនីតិវិធីចុះញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មានទើបតែត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយពន្លឿននីតិវិធីនៃការចុះបញ្ជីអាជីវកម្មត្រឹមតែរយៈពេល៨ ថ្ងៃប៉ុណ្ណោះ។ ហើយដើម្បីចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ មាន៦ ជំហាន គឺ ៖

១.កាបង្កើតគណនីលើ CamDigikey App

២.ការ Log In ចូលទំព័រ Portal

៣.ដំណើរការចុះបញ្ជី

៤.ការទូទាត់

៥.ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

៦.ការទទួលបានអាជ្ញាបណ្ណ / វិញ្ញាបនបត្រឌីជីថល។

បន្ទាប់ពីនេះអភិបាលនឹងទទួលបានការវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ តែដោយឡែកទោះបីជានីតិវិធីចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មានក៏ដោយ ក៏ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្មនៅតែបន្តប្រើដដែល ចំពោះការចុះបញ្ជីផ្លាស់ប្តូរ ឬកែប្រែក្រុមហ៊ុនដោយយោងទៅលើសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម។ ចំពោះការចុះបញ្ជីកែប្រែ ឬផ្លាស់ប្តូរនេះជាការផ្លាស់ប្តូរ នាមករណ៍ក្រុមហ៊ុន លក្ខន្តិកៈក្រុមហ៊ុន សកម្មភាពអាជីវកម្ម ការបន្ថយដើមទុន ជាដើម។

អភិបាលត្រូវចូលទៅកាន់ www.businessre gistration.moc.gov.kh រួចចុច Log On (ចូល)រួមចូលទៅបំពេញបែបបទ តើចង់ប្តូរទៅលើអ្វី។

ឧទាហរណ៍ ប្រសិនបើចង់បន្ថយដើមទុន ត្រូវធ្វើឡើងតាមនីតិវិធីខាងក្រោម៖

ចុចពាក្យ "បន្ថយដើមទុន" បន្ទាប់មកសូមបន្ថយតម្លៃចារឹកលើប័ណ្ណ ប៉ុន្តែមិនអាចបន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនដំបូងចុះបញ្ជីបានឡើយ រួចជ្រើសរើសកាលបរិច្ឆេទនៃសេចក្តីសម្រេច រួចចុចពាក្យថា "បញ្ចូល" នៅត្រង់ពាក្យថា "សេចក្តីសម្រេចម្ចាស់ហ៊ុន និងកំណត់ហេតុអង្គប្រជុំ"។ ប្រសិនបើព័ត៌មានខាងលើត្រឹមត្រូវរួចហើយ ចុចពាក្យ "ដាក់ស្នើ" ដើម្បីទូទាត់កម្រៃសេវាជាការស្រេច។

បន្ទាប់ពីបានសិក្សាប្រធានបទនេះហើយ យើងសង្កេតឃើញថាការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតទទួលផលប្រយោជន៍ជាច្រើន ដើម្បីឱ្យក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈត្រឹមត្រូវតាមច្បាប់។ ពោលគឺ ក្រុមហ៊ុននឹងទទួលបានសិទ្ធិ និងកាតព្វកិច្ច ដូចរូបវន្តបុគ្គលដែរ បន្ទាប់ពីបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ ដែលនេះមានន័យថាក្រុមហ៊ុនអាចធ្វើអាជីវកម្មបានដោយស្របច្បាប់នៅទូទាំងប្រទេសកម្ពុជា។ តែផ្ទុយទៅវិញ ប្រសិនបើក្រុមហ៊ុនមិនបានចុះបញ្ជីទេ ក្រុមហ៊ុនត្រូវបានចាត់ទុកថា មិនបានបង្កើតឡើងត្រឹមត្រូវតាមផ្លូវច្បាប់ និងប្រកបអាជីវកម្មមិនស្របច្បាប់។

តែទោះបីជាច្បាប់តម្រូវឱ្យមានក្រុមហ៊ុនត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មក៏ដោយ នៅតែមានជនខិលខូចមួយចំនួនលួចលាក់បើកដំណើរការអាជីវកម្មដោយមិនមានការចុះបញ្ជីពាណិជ្ជកម្មដែរ។

ទន្ទឹមនឹងដែរ ចំពោះការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យា ឬតាមប្រព័ន្ធអេឡិចត្រូនិចគឺជួបបញ្ហាជាច្រើននៅឡើយ ទាំងមន្ត្រីដែលអនុវត្តច្បាប់ និងប្រជាពលរដ្ឋព្រោះការទទួលបានចំណេះដឹងនៅមានកម្រិតជាពិសេសទាក់ទងនឹងនីតិវិធីចុះបញ្ជីតាមប្រព័ន្ធព័ត៌មានវិទ្យាដោយសារជានីតិវិធីថ្មី ដូច្នេះក្រសួងគួរបង្កើនការផ្សព្វផ្សាយតាមទូរទស្សន៍ ឬតាមគេហទំព័ររបស់ក្រសួងបន្ថែម ហើយបើកឱ្យមានការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធ សាធារណជន និងមានសិក្ខាសាលាផ្សេងៗដែលទាក់ទងនឹងនីតិវិធីថ្មីនេះផងដែរ។

ដូចនេះចំពោះសារណារបស់យើងខ្ញុំទាំងពីរនាក់លើប្រធានបទស្តីពី ការចុះបញ្ជីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត យើងខ្ញុំនឹងរងចាំការរិះគន់ កែលម្អ នៅចំណុចដែលខ្វះខាតពីសំណាក់សាស្ត្រាចារ្យស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិតទាំងអស់ ក្នុងការរិះគន់ដើម្បីស្ថាបនា។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាលគ្រប់អាណត្តិទាំងអស់ គួរគប្បីបង្កើនការយកចិត្តទុកដាក់ចំពោះវិស័យឯកជន ដែលជាវិស័យសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិបានយ៉ាងឆាប់រហ័ស តាមរយៈការធ្វើវិនិយោគ។ ជាពិសេស ជំរុញនូវល្បឿននៃការអនុម័តច្បាប់ដែលពាក់ពន្ធ័នឹងវិស័យពាណិជ្ជកម្មឱ្យបានកាន់តែច្រើនជាងមុន និង ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាដល់ដំណើរការរបស់ក្រុមហ៊ុន ធ្វើយ៉ាងណាឱ្យអ្នកវិនិយោគមានការជឿទុកចិត្តចំពោះការអនុវត្តច្បាប់ក្នុងប្រទេសរបស់យើង នឹងអាចទាក់ទាញអ្នកវិនិយោគទុនមកធ្វើការ បណ្តាក់ទុនឱ្យបានកាន់តែច្រើន ដែលទាំងនេះជាប្រភពចំណូលយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចជាតិ និងធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពកាន់តែប្រសើរឡើងតាមរយៈភាពមានការងារធ្វើ។

# ឯកសារយោង

## ❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. ក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧។

២. ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៧ មិថុនា ឆ្នាំ ២០០៥។

៣. ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥។

៤. ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម លេខនស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨វិច្ឆិកា ១៩៩៩។

៥. អនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រពន្ធ័បច្ចេកវិទ្យាព័ត៌មាន លេខ ៨៤.អនក្រ .បក .ចុះថ្ងៃទី ១០ មិថុនា ឆ្នាំ ២០២០។

៦. ប្រកាសអន្តរក្រសួងលេខ៣៣៣សហវ-ប្រក ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម លេខ ចុះថ្ងៃទី ២៧ មីនា ឆ្នាំ ២០២០។

៧. ប្រកាសអន្តរក្រសួងលេខ១២១៧សហវ-ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧។

៨. ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រពន្ធ័ស្វ័យប្រវត្តកម្ម លេខ ២១៣ ព.ណ ចបព.ប្រក ចុះថ្ងៃទី២៤ មិថុនា ឆ្នាំ២០១៦។

៩. ប្រកាសស្តីពីបែបបទនិងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៥។

១០. ប្រកាសស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧ ។

១១. សេចក្តីជូនដំណឹង ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មានរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី ១៥ មិថុនា ឆ្នាំ ២០២០។

## ❖ សៀវភៅ

១. សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់ របស់ក្រសួងពាណិជ្ជកម្ម។

២. សៀវភៅមគ្គុទេសក៍ សម្រាប់ដំណើរការចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យាពត៌មាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០២០។

# ឧបសម្ព័ន្ធទី១

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

**មាត្រា ១៨.-** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.-** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.-** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថ-ភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.-** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

បំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោម ៖

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីតាំងនៃទីស្នាក់ការកណ្តាល ។

ឃ-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋានដែលត្រូវធានាក្នុងនាមជានីតិបុគ្គល និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍របស់បុគ្គលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណីដែលបុគ្គលណាម្នាក់បានសន្យាថានឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យសម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយដែលចំណាយ ក្នុងការបង្កើតនីតិបុគ្គល ហើយដែលនីតិបុគ្គលត្រូវទទួលបន្ទុក ។

ង-ឆ្នាំអនុវត្តកិច្ចការ ។

ច-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេងទៀត ។

ឆ-បញ្ញត្តិស្តីពីការទទួល និង ការបាត់បង់សមាជិកភាព ។

ជ-ចំណុចស្តីពីគណនេយ្យ ។

ឈ-ចំណុចស្តីពីការរំលាយ ។

ញ-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

ដ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការីទេ ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

**មាត្រា ៨៣.–** ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន

នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។

**មាត្រា ៨៤.–** ការជ្រើសតាំងអភិបាល និង អ្នកត្រួតពិនិត្យ

១-បើពុំបានកំណត់អភិបាល ឬ អ្នកត្រួតពិនិត្យ នៅក្នុងលក្ខន្តិកៈ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃការបង្កើត ត្រូវជ្រើសតាំងអភិបាល ឬ អ្នកត្រួតពិនិត្យ ដោយមហាសន្និបាតសមាជិក មុននឹងបង្កើតនីតិបុគ្គល ។

២-សមាជិកម្នាក់ៗអាចកោះប្រជុំមហាសន្និបាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ៨៥.–** ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍

១-អភិបាលត្រូវអញ្ជើញអ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន បែងចែកចំនួនដែលអ្នកនីមួយៗនោះត្រូវធ្វើវិភាគទាន ហើយទាមទារឱ្យអ្នកទាំងនោះធ្វើវិភាគទានដើម្បីធ្វើឱ្យមានទ្រព្យសម្បត្តិជាមូលដ្ឋានពេញលេញ ។

២-ក្នុងករណីដែលមានការសរសេរនូវចំណុចដែលបានកំណត់នៅវាក្យខណ្ឌទី ២ ចំណុច ឃ កថាខណ្ឌទី ២ នៃមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមនេះ នៅក្នុងលក្ខន្តិកៈ អភិបាលត្រូវទាមទារឱ្យតុលាការជ្រើសតាំងអធិការ ដើម្បីស្រាវជ្រាវនូវចំណុចដែលបានសរសេរនោះ ដោយពុំមានការយឺតយ៉ាវ ។

៣-អធិការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើសេចក្ដីរាយការណ៍ទៅតុលាការ អំពីលទ្ធផលនៃការស្រាវជ្រាវ ។

៤-ក្នុងករណីដែលតុលាការយល់ឃើញថា ការសរសេរនៅក្នុងលក្ខន្តិកៈនោះមិនត្រឹមត្រូវ ដោយយោងតាមលទ្ធផលនៃការស្រាវជ្រាវ តុលាការត្រូវចេញដីកាសម្រេចឱ្យផ្លាស់ប្ដូរចំណុចនោះ ។ ក្នុងករណីនេះ តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេច ទៅសមាជិក អភិបាល ហើយបើមានការផ្លាស់ប្ដូរចំណុចដែលពាក់ព័ន្ធនឹងវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវជូនដំណឹងទៅអ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់នោះ ។

៥-អ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលបានទទួលដំណឹងដូចបានកំណត់

# គន្ថីទី ៩

# អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

៣រល.០៧១២.៦២២ **ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ:៥៧៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

453/453

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្មដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

c1-kram-10

# ច្បាប់

# ស្តីពី

# សហគ្រាសពាណិជ្ជកម្ម

ក្នុងទំនាក់ទំនងទៅនឹងតតិយជន សហកម្មសិទ្ធិករមានកម្រិតដែលបានផ្ទេរអត្ថ-ប្រយោជន៍របស់ខ្លួនរួចមកហើយនោះ នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត ។

**មាត្រា ៧៩.-**

សហកម្មសិទ្ធិករមានកម្រិតមិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ ។

សហកម្មសិទ្ធិករមានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការរីកចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់ជាគំនិតក្នុងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ដំណាក់កាល ។

សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចាក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬ មិនអនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុននោះឡើយ ។

សហកម្មសិទ្ធិករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលកើតឡើងដោយសារការប្រព្រឹត្តទាំងនោះ ។

សហកម្មសិទ្ធិករមានកម្រិត អាចអនុញ្ញាតឱ្យទទួលខុសត្រូវដូចសហកម្មសិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបានរៀបរាប់រួចហើយ ឬ សារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយមានភស្តុតាងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅពិតប្រាកដមែន ។

**មាត្រា ៨០.-**

នៅពេលសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបានទេ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០(មួយរយម្ភៃ)ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវបានរំលាយ ។

**មាត្រា ៨១.–**

តតិយជនដែលជាម្ចាស់បំណុលអាចប្តឹងទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនិងពីសហកម្មសិទ្ធិករទូទៅបានដូចគ្នា ដូចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។

**មាត្រា ៨២.–**

នៅពេលណាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនគ្រប់គ្រាន់ទេ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះតតិយជននូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ សហកម្មសិទ្ធិករមានកម្រិត ត្រូវទទួលខុសត្រូវនូវបំណុលត្រឹមតែចំនួនភាគទុន ដែលខ្លួនបានព្រមព្រៀងដាក់ជាមួយគ្នា ដោយមិនគិតការផ្ទេរអត្ថប្រយោជន៍ណាមួយរបស់ខ្លួនឡើយ ។

**មាត្រា ៨៣.–**

ក្នុងករណីបំណុលកើនលើសពីដើមទុន ឬ ក្នុងករណីក្ស័យធននៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗដែលជាម្ចាស់បំណុល មិនអាចទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ រហូតដល់ម្ចាស់បំណុលដទៃទៀតនៃក្រុមហ៊ុនមានកម្រិតនេះ ត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

**មាត្រា ៨៤.–**

វិធាននៃការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ ។

សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន ។ ក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន ។

គ-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬ ច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់ ។

ឃ-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៨៧.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន ។

**មាត្រា ៨៨.-**

នៅក្នុងជំពូកនេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-លក្ខន្តិកៈ មានន័យថាលក្ខន្តិកៈដើម ឬ លក្ខន្តិកៈធ្វើការកែប្រែ ។

២-សវនករ មានន័យថាគណនេយ្យករជំនាញម្នាក់ដែលធ្វើកិច្ចការក្នុងលក្ខណៈជាបុគ្គល ឬ ធ្វើកិច្ចការក្នុងក្រុមហ៊ុនគណនេយ្យណាមួយ ។

៣-កាតព្វកិច្ចបំណុលគឺជាសញ្ញាប័ណ្ណ ឬ ជាលិខិតបញ្ជាក់បំណុលផ្សេងៗ ឬ លិខិតស្នាមរបស់ក្រុមហ៊ុនដែលអាចធានា ឬ មិនអាចធានាបាន ។

៤-មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមានន័យថាមន្ត្រីដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីអនុវត្តការងារនៃច្បាប់នេះ ។

៥-អភិបាលមានន័យថាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

៦-ស្ថាបនិកក្រុមហ៊ុនមានន័យថារូបវន្តបុគ្គលដែលចុះហត្ថលេខាលើ

លក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៧-សេចក្តីសម្រេចសាមញ្ញមានន័យថាជាសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើនដាច់ខាត ដែលបានចូលរួមក្នុងការបោះឆ្នោត ។

៨-ភាគហ៊ុនអាចរំលោះបានមានន័យថាជាភាគហ៊ុនដែលត្រូវបានចេញដោយក្រុមហ៊ុនណាមួយ :

-ក្រុមហ៊ុននោះអាចទិញ ឬ រំលោះបានទៅតាមតម្រូវការរបស់ក្រុមហ៊ុន

-ក្រុមហ៊ុននោះត្រូវបានតម្រូវឱ្យដោយលក្ខន្តិកៈរបស់ខ្លួនដើម្បីទិញ ឬរំលោះនៅពេលកំណត់ណាមួយ ឬ ក៏ទៅតាមតម្រូវការរបស់ម្ចាស់ហ៊ុនណាម្នាក់ ។

៩-ស៊េរីនៅក្នុងទំនាក់ទំនងទៅនឹងភាគហ៊ុនមានន័យថាជាការបែងចែកចំណាត់ថ្នាក់ភាគហ៊ុនឱ្យទៅជាប្រភេទភាគហ៊ុននីមួយៗ ។

១០-សេចក្តីសម្រេចពិសេសមានន័យថាជាសេចក្តីសម្រេចមួយត្រូវធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើន ២/៣ (ពីរភាគបី) ដែលបានចូលរួមក្នុងការបោះឆ្នោត ឬ ពីការចុះហត្ថលេខារបស់សមាជិកភាគហ៊ុនទាំងឡាយ ដែលមានសិទ្ធិក្នុងការបោះឆ្នោតធ្វើសេចក្តីសម្រេចនោះ ។

១១-មូលបត្រមានន័យថា :

ក-ជាភាគហ៊ុននៅក្នុងស៊េរីនៃភាគហ៊ុនណាមួយ ឬ ជាភាគហ៊ុននៅក្នុងប្រភេទនៃភាគហ៊ុនណាមួយ ។

ខ-សញ្ញាប័ណ្ណ ។

គ-រួមបញ្ចូលទាំងវិញ្ញាបនបត្របញ្ជាក់ដែលផ្តល់ភស្តុតាងអំពីមូលបត្រទាំងឡាយ ។



៧០

ហ៊ុន តែងតាំងអ្នកគ្រប់គ្រងក្រុមហ៊ុន កំណត់តួនាទីភារកិច្ចនិងសិទ្ធិរបស់អ្នកទាំងនោះឱ្យបានច្បាស់លាស់ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។

ខ-អភិបាលអាចត្រូវបានតែងតាំងឱ្យគ្រប់គ្រងការិយាល័យណាមួយរបស់ក្រុមហ៊ុន ។

គ-បុគ្គលម្នាក់អាចរៀបចំគ្រប់គ្រងការិយាល័យមួយ ឬ ច្រើនរបស់ក្រុមហ៊ុនបាន ។

**មាត្រា ១៣៩.-**

បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឱ្យក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព ឬ បុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ ។

ក្រោយពីកិច្ចសន្យាមួយ បានបង្កើតឡើងក្នុងពេលវេលាមួយសមស្រប ក្រុមហ៊ុនអាចទទួលយកបាននូវកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះ ដែលបានធ្វើឡើងមុនពេលក្រុមហ៊ុនមានអត្ថិភាព និងមុនការទទួលយល់ព្រមនៅក្នុងក្រុមហ៊ុន ។ ការទទួលនេះផ្អែកលើសកម្មភាព ឬ ការប្រព្រឹត្តដែលផ្តោតទៅលើគោលបំណងដ៏សំខាន់នៃកិច្ចសន្យាដែលបានជាប់កាតព្វកិច្ចរួចមកហើយនោះ ។

ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចដោយកិច្ចសន្យា ហើយមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ដូចពេលដែលក្រុមហ៊ុនមានអត្ថិភាព ចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា និងដូចពេលដែលក្រុមហ៊ុននោះជាចំណែកមួយនៃកិច្ចសន្យា ។

បុគ្គលម្នាក់ដែលប្តឹងទាមទារថាបានអនុវត្តក្នុងនាម ឬ តំណាងឱ្យក្រុមហ៊ុនមានកាតព្វកិច្ច ឬ មានសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យាបាន លុះត្រាតែមានដីកាសម្រេចរបស់តុលាការ ។

**មាត្រា ១៤០.-**

អភិបាលដែលបោះឆ្នោតឱ្យ ឬ យល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឱ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេត្រូវ

ទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសម-ម្ងូលដែលបានទទួល ដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួល ប្រសិនបើប័ណ្ណភាគហ៊ុនដែលបានបោះចេញនោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច ។

អភិបាលមិនទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលបោះចេញសម្រាប់តម្លៃសមម្ងូល ដែលតិចជាងសាច់ប្រាក់ ដែលក្រុមហ៊ុនអាចនឹងទទួលប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបានបោះចេញសម្រាប់លក់យកជាប្រាក់ ។

សកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់នេះមិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ)ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤១.-**

អភិបាលដែលបានបោះឆ្នោតឱ្យ ឬ យល់ព្រមចំពោះសេចក្តីសម្រេចដែលអនុ-ញ្ញាតឱ្យមានការទិញមកវិញនូវភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬ ធ្វើការចែកភាគលាភដែលផ្ទុយពីបទប្បញ្ញត្តិនៃជំពូកនេះត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់ចំនួនដែលបានបែងចែក ឬ បានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ ។

សកម្មភាពដើម្បីអនុវត្តការទទួលខុសត្រូវដែលតម្រូវដោយមាត្រានេះ មិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤២.-**

អភិបាលម្នាក់ ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬ សកម្មភាពដែលបានធ្វើឡើងនៅក្នុងមហាសន្និបាតលើកលែងតែ :

**មាត្រា ២០១.-**

ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវបានតែងតាំងដោយតុលាការ ឬ ដោយលិខិតណាមួយរបស់ក្រុមហ៊ុន សិទ្ធិរបស់អភិបាលទាំងឡាយត្រូវអស់តម្លៃរហូតដល់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះត្រូវបានបញ្ចប់ ។

**មាត្រា ២០២.-**

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងដោយតុលាការត្រូវអនុវត្តទៅតាមការណែនាំរបស់តុលាការ ។

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងតាមសេចក្តីសម្រេចណាមួយផ្សេង ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចនេះនិងតាមការណែនាំរបស់តុលាការ ។

**មាត្រា ២០៣.-**

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិត្រូវ :

១-ប្រតិបត្តិដោយស្មោះត្រង់ និងដោយបំណងល្អហើយរក្សាទុកដាក់ទ្រព្យសម្បត្តិដែលស្ថិតក្នុងការកាន់កាប់របស់ខ្លួន ឬ ធ្វើការត្រួតពិនិត្យត្រឹមត្រូវតាមរបៀបពាណិជ្ជកម្ម ។

២-ជូនដំណឹងជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអំពីការតែងតាំង និងការបំពេញសិទ្ធិរបស់ខ្លួន ។

៣-ថែរក្សា និងត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្របទៅតាមបញ្ជារបស់តុលាការ ឬ តាមលិខិតស្នាមដែលខ្លួនត្រូវបានតែងតាំង ។

៤-បើក និងរក្សាទុកគណនីធនាគារក្នុងនាមរបស់ខ្លួនជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសម្រាប់ទឹកប្រាក់ក្រុមហ៊ុនដែលបានមកដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

៥-រក្សាទុកគណនីពិស្តារពីកិច្ចការជំនួញទាំងអស់ ដែលបានសំរេចឡើង ដោយខ្លួនឯងដែលជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៦-រក្សាទុកគណនីទាំងឡាយនៃការគ្រប់គ្រង និងសម្រាប់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រួតពិនិត្យក្នុងពេលម៉ោងធ្វើអាជីវកម្ម ។

៧-រៀបចំយ៉ាងហោចណាស់ម្តងក្នុងមួយឆមាសនូវរបាយការណ៍ហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនត្រូវបានតែងតាំង ។

៨-ផ្តល់នូវគណនីចុងក្រោយនៃការគ្រប់គ្រង ដើម្បីបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួន ។

**មាត្រា ២០៤.—**

តាមការស្នើសុំដោយអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ការស្នើសុំដោយបុគ្គលដែលមានផលប្រយោជន៍ តុលាការត្រូវចេញបញ្ជាដោយយល់ថាគួរបញ្ចូលបន្ថែមដោយគ្មានកម្រិតនូវ :

ក-ដីកាតែងតាំង ដីកាតែងតាំងជំនួស ឬ ដីកាបញ្ចប់សិទ្ធិអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ និងដីកាដែលឱ្យសច្ចានុម័តលើគណនីរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

ខ-ដីកាកំណត់សេចក្តីជូនដំណឹង ដែលត្រូវផ្តល់ដល់បុគ្គលណាម្នាក់ ឬដីកាបញ្ជូនសេចក្តីជូនដំណឹងដល់បុគ្គលណាម្នាក់ ។

គ-ដីកាកំណត់ប្រាក់ឧបត្ថម្ភដល់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

ឃ-ដីកាកំណត់ទិសដៅដល់រាល់បញ្ហាទាក់ទងទៅនឹងភារកិច្ចរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

ឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

របាយការណ៍ និងឯកសារទាំងឡាយ ត្រូវផ្ញើទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬ ផ្ញើជាបន្ទាន់ បន្ទាប់ពីការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ ។

**មាត្រា ២២៩.-**

ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូប ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ ។

សវនករ ត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃឆ្នាំបន្ទាប់ ។

ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់តំណែង ត្រូវបន្តរហូតដល់សវនករថ្មីត្រូវបានតែងតាំង ។

**មាត្រា ២៣០.-**

ម្ចាស់ហ៊ុននៃក្រុមហ៊ុនដែលមិនបានចេញមូលបត្រប្រភេទណាមួយទៅឱ្យសាធារណជន ឬ ដោយគ្មានមូលបត្រដែលកាន់ដោយបុគ្គលលើសពីម្នាក់ អាចធ្វើសេចក្តីសម្រេចមិនតែងតាំងសវនករបាន ។

**មាត្រា ២៣១.-**

សោហ៊ុយចំណាយសម្រាប់សវនករ អាចត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចសាមញ្ញរបស់ម្ចាស់ហ៊ុន ឬ បើមិនដូច្នេះទេ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ។

**មាត្រា ២៣២.-**

ម្ចាស់ហ៊ុនទាំងឡាយអាចដកហូតសវនករពីមុខតំណែងបាន លើកលែងតែសវនករត្រូវបានតែងតាំងដោយតុលាការ ឬ ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុង

មហាសន្និបាតពិសេស ។ នៅក្នុងអង្គប្រជុំដូចគ្នានោះ ម្ចាស់ហ៊ុនអាចតែងតាំងសវនករជំនួសបាន ។

នៅពេលណា ដែលមានភាពទំនេរនៃតំណែងសវនករ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំមហាសន្និបាតពិសេសនៃម្ចាស់ហ៊ុន ដើម្បីបំពេញភាពនៅទំនេរនោះ ដោយត្រូវធ្វើឡើងក្នុងរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីមានភាពទំនេរនោះ ។

សវនករដែលត្រូវតែងតាំងដើម្បីបំពេញភាពទំនេរនោះ ត្រូវកាន់កាប់តំណែងបន្តជំនួសអាណត្តិដែលមិនទាន់ផុតកំណត់របស់សវនករមុន ។

**មាត្រា ២៣៣.–**

ប្រសិនបើក្រុមហ៊ុនមិនទាន់មានសវនករ តាមការស្នើសុំរបស់ម្ចាស់ហ៊ុន ឬ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម តុលាការអាចតែងតាំង និងដាក់កំណត់ដោះស្រាយចំណាយសម្រាប់សវនករ ដែលបានកាន់តំណែងរហូតដល់សវនករថ្មីត្រូវបានតែងតាំងដោយម្ចាស់ហ៊ុនទាំងឡាយ ។

**មាត្រា ២៣៤.–**

សវនករត្រូវធ្វើការត្រួតពិនិត្យ លើចំណុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុនទាំងឡាយ លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុន ឬ អភិបាលបច្ចុប្បន្នអ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានការបកស្រាយបំភ្លឺ និងសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ ។

សវនកររបស់ក្រុមហ៊ុន មានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាត ម្ចាស់ហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុ ដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន ។

ប្រសិនបើអភិបាល ឬ ម្ចាស់ហ៊ុន ទោះបីជាម្ចាស់ហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្ន ឬ ពីមុនក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ មុនមហាសន្និបាត សវនករបច្ចុប្បន្ន ឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ ។

## ៧- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

**មាត្រា ២៣៥.-**

ក្រុមហ៊ុនមូលធន អាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន ។

**មាត្រា ២៣៦.-**

ក្រុមហ៊ុនមូលធនត្រូវធ្វើការកែប្រែលក្ខន្តិកៈតាមសេចក្ដីសម្រេចពិសេស។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬ ជាស៊េរី ដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្ដីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង :

១- បន្ថែម កែប្រែ ឬ ដកហូតនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុន ។

២- បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុននោះ ។

៣- បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន ដែលមានសិទ្ធិចំពោះប្រភេទ ឬ ស៊េរីដែលមានសិទ្ធិ ឬ ឯកសិទ្ធិស្មើ ឬ ក៏លើសពីប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៤- បង្កើតប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬ លើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬ ស៊េរីរបស់អ្នកកាន់កាប់នោះ ។

៥- បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬ ឯកសិទ្ធិតូចជាង ឬ ស្មើ ឬ លើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៦- បន្ថយគណនីដើមទុនចុះបញ្ជីនៃប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថាប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនជាក់លាក់មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុន នោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រភេទ ឬ សេរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬ ដោយប្រយោល ឬ ប៉ះពាល់ទៅនឹង សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

សិទ្ធិក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងមាត្រានេះ មិនត្រូវបានលុបចោល បន្ថយ ឬ ដាក់កម្រិតដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬ តាមរបៀបណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២៣៧.-**

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវផ្ញើជូនទៅម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត យ៉ាងតិច ២០(ម្ភៃ)ថ្ងៃ មុនពេលបើកមហាសន្និបាត ។ លិខិតជូនដំណឹងនេះត្រូវផ្ញើភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ ។

**មាត្រា ២៣៨.-**

ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ :

ក- ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ។

ខ- ការបន្ថែម ការបន្ថយ ឬ ការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬ សកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

គ- ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និង លក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ ។

ឃ- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ ។

ង- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ ។

ច- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត ។ ដើមទុនចុះបញ្ជីមិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្ដាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម ។ បើក្នុងរយៈពេលនេះមានការតវ៉ាជំទាស់ពីម្ចាស់បំណុល ដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុង មុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន ។

ឆ- ការកែប្រែថិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន ។

ជ- ការផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជី ។

ឈ- ការកែប្រែចំនួនកូរ៉ុម ។

ញ- បន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់នេះអនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ២៣៩.–**

គ្រប់ឯកសារស្ដីពីការធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេច ព្រមទាំងមានចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ អភិបាលណាម្នាក់ដែលទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល ។

ឯកសារទាំងនេះត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីមហាសន្និបាតបានសម្រេច ។

**មាត្រា ២៤០.-**

ពេលបានទទួលឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ ។

ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀត កាលបរិច្ឆេទនោះមិនឱ្យលើសពី ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ ។

## ៥.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

**មាត្រា ២៤១.-**

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

**មាត្រា ២៤២.-**

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

**មាត្រា ២៤៣.-**

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

ក- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម ។

គ- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬ មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

ឃ- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬ កម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួល ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ ។

ង- ព័ត៌មានមានផទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹង ដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ច- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

**មាត្រា ២៤៤.-**

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :

ក- នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

គ- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន ។

**មាត្រា ២៤៥.-**

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។

**មាត្រា ២៤៦.-**

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬ ស៊េរីនៃភាគហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ ។

**មាត្រា ២៤៧.-**

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមានជាអាទិ៍ :

ក- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ ។

គ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

ឃ- សេចក្ដីប្រកាសរបស់អភិបាលឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ សេចក្ដីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

១- ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ។

២- ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ។

៣- គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។

៤- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។

**មាត្រា ២៤៨.-**

នៅពេលទទួលលក្ខន្តិកៈស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

ក- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន ។

ខ- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

គ- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ ។

ឃ- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

ង- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

**មាត្រា ២៤៩.-**

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មានសិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃ ម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

ក- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ ។

ខ- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ ។

គ- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ឃ- នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួន ទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

**មាត្រា ២៥០.-**

នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុនដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួល

រកតម្លៃសមរម្យមួយក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ដើម្បីឱ្យ មានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។

តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយ នៅក្នុងកិច្ចសន្យាវិលាយក្រុមហ៊ុនបញ្ចូលគ្នា ។

លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រមព្រៀងនៃការវិលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្តកម្ម ។ មុននឹងមជ្ឈត្តករចេញសេចក្ដីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្ដឹងទាមទាររបស់ខ្លួន ក្នុងការវាយតម្លៃនៅពេលណាមួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តនូវតម្លៃសមមូល ដែលក្រុមហ៊ុនបានកំណត់ពីមុន ។

ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេ ភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយ ហើយម្ចាស់ហ៊ុនដែលទាមទារត្រូវទទួលទៅតាមចំនួននោះ ។

## ៥- ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី

**មាត្រា ២៥១.-**

ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្ដីសម្រេចរបស់អភិបាលទាំងអស់ ។

ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្ដីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្ដីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។

ក្រុមហ៊ុនត្រូវបញ្ជូនសេចក្តីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

នៅពេលបានទទួលសេចក្តីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបានចាត់ទុកថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន ។

**មាត្រា ២៥២.-**

អភិបាលឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

លិខិតជូនដំណឹងស្តីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬ រំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុននោះ ។

ក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និង/ឬ មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ។ ក្នុងករណីដែលក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតទេ ប្រសិនបើ :

១- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុន តាមសេចក្តីសម្រេចពិសេសឬ សេចក្តីសម្រេចសាមញ្ញ ។

២- ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុន ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៣០២.-**

ក្រសួងពាណិជ្ជកម្មត្រូវរៀបចំគំរូលក្ខន្តិកៈនិងបែបបទកែលក្ខន្តិកៈស្របតាមច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនដល់ក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ ហើយដែលមានបំណងធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣០៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣០៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម-០៥០៦/២៩៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

ព្រះ ... ២៥៥ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

# ច្បាប់

# ស្តីពី

# វិសោធនកម្ម
# នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម
# និងបញ្ជីពាណិជ្ជកម្ម

លេខ ១៤៣៨

០៣ ១២ [illegible] ៣៧,៣០

ស/រកម/១១៩៩/១២

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# ប្រកាសអោយប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម ទំរង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី ២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី ៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

មួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនដល់អ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ"។

**មាត្រា ១៦.-ថ្មី**

ការចុះនិទ្ទេសដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែចំពោះករណីដែលមានចែងនៅក្នុងចំណុច ២, ៤ និង ៦ នៃមាត្រា ១៥ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចចុះសេចក្តីនោះដោយបញ្ញត្តិក្នុងបញ្ជីពាណិជ្ជកម្មដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

**មាត្រា ១៧.-ថ្មី**

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើតនិងចិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការឬអភិបាលនៃសាមីក្រុមហ៊ុន នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃ(១៥ថ្ងៃ)មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពី :

១-នាមត្រកូលនិងនាមខ្លួន រហស្សនាមរបស់សមាជិកក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារនិងសញ្ជាតិ ។

២-ផ្លាកសញ្ញារបស់ក្រុមហ៊ុន ។

៣-កម្មវត្ថុនៃក្រុមហ៊ុន ។

៤-ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើមមានសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ។

៥-នាមនៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតអោយគ្រប់គ្រងចាត់ចែង ចុះចាត់ចែងនិងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ ។

៦-ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុននិងចំនួនទឹកប្រាក់ ឬវត្ថុមានតម្លៃដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនៈដោយភាគហ៊ុន ។

៧-ថ្ងៃ-ខែ-ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើមនិងបញ្ចប់ ។

៨-ទ្រង់ទ្រាយក្រុមហ៊ុន ។

៩-ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជនដូចមានចែងនៅចំណុចលេខ ៥ នៃមាត្រានេះ និងស្លាកត្រាគំរូរបស់ក្រុមហ៊ុន ។

១០-លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

១១-សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណីឬព្រហ្មទណ្ឌ ។

**មាត្រា ២១.-ថ្មី**

ប្រតិវេទន៍ធ្វើឡើងជាបីច្បាប់ត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬដោយអាណត្តិគាហករបស់សាមីជននោះ ក្នុងករណីនេះ អាណត្តិគាហកត្រូវមានលិខិតប្រគល់សិទ្ធិអំណាចដែលត្រូវតម្កល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

**មាត្រា ២២.-ថ្មី**

បើប្រតិវេទន៍ត្រូវបានយកទៅដាក់ផ្ទាល់ដោយអ្នកស្នើសុំនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវពិនិត្យពិច័យអត្តសញ្ញាណរបស់សាមីខ្លួនអោយបានច្បាស់លាស់ ។ បើសិនប្រតិវេទន៍នេះត្រូវបានយកទៅតម្កល់ទុកដោយអាណត្តិគាហក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវ

មាត្រា ៥៨.-ថ្មី (មាត្រា ៥៩ ចាស់)

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥៩.-ថ្មី (មាត្រា ៦០ ចាស់)

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធិ

លេខ : ២១៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈ្លាឌី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៤ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដែលក្នុងនោះមាន៖

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ការពិនិត្យនិងទទួលសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម និង ការពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាន និងឯកសារភ្ជាប់

**មាត្រា ៥.-**

បុគ្គលស្នើសុំ ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ ក្នុងទម្រង់អេឡិចត្រូនិក ដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://www.registrationservices.gov.kh។

បុគ្គលស្នើសុំ អាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងចុះបញ្ជី ដើម្បីធ្វើការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះក្នុងនាមបុគ្គលស្នើសុំ ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ ឬ/និង ឯកសារពាក់ព័ន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ព័ត៌មាននិងឯកសារភ្ជាប់ស្នើសុំចុះបញ្ជីអាជីវកម្ម ដែលបានបំពេញដោយបុគ្គលស្នើសុំ សម្រាប់តម្កល់តាមក្រសួង-ស្ថាប័នមានសមត្ថកិច្ចជាទម្រង់អេឡិចត្រូនិក ត្រូវបញ្ជូនដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងសម្រេចផ្ដល់ការអនុញ្ញាតការចុះបញ្ជីអាជីវកម្ម។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារភ្ជាប់ តាមសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយអនុលោមតាមអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីព័ត៌មាន និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬ/និងមិនគ្រប់គ្រាន់ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវជូនដំណឹងដល់បុគ្គលស្នើសុំ ដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់វិញ្ញាបនបត្រឬលិខិតបញ្ជាក់ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែម។

**មាត្រា ៧.-**

កម្រៃសេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ កម្រៃសេវានេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

## ជំពូកទី៣

## ការផ្តល់ ព្យួរ និងដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈគេហទំព័រចុះបញ្ជី

### ផ្នែកទី១

### ការផ្តល់វិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ៨.-**

ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបាន សម្រាប់ប្រើប្រាស់ជាផ្លូវការ តាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ៩.-**

ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវលើព័ត៌មាននិងឯកសារភ្ជាប់ និងត្រូវផ្តល់ការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជី សម្រាប់ប្រើប្រាស់ជាផ្លូវការ រួមមាន ប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និងលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

ក្នុងគោលបំណងលើកទឹកចិត្តនិងជំរុញការចុះបញ្ជីពន្ធដារ អ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវបង់ពន្ធប៉ាតង់ត្រឹមតែ ៥០ (ហាសិប) ភាគរយនៃប្រាក់ពន្ធប៉ាតង់ដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានប៉ុណ្ណោះ សម្រាប់ឆ្នាំដែលធ្វើការចុះបញ្ជីអាជីវកម្ម។ ប្រាក់ពន្ធប៉ាតង់នេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល បុគ្គលស្នើសុំត្រូវផ្តល់ព័ត៌មានអំពីគណនីធនាគារជូនអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបានដកហូតដោយស្វ័យប្រវត្តិ។

**មាត្រា ១០.-**

បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីពន្ធដារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ តាមគេហទំព័រចុះបញ្ជីក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ករណីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនបានពិនិត្យនិងផ្តល់នូវការចុះលេខរដ្ឋបាលនៃការទទួលសេចក្តីប្រកាសនេះ ក្នុងរយៈពេល ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការទេ សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ត្រូវបានចាត់ទុកថា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនេះ ដោយស្វ័យប្រវត្តិ។

ការទទួលយកសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសរបស់បុគ្គលស្នើសុំ តាមទម្រង់ឌីជីថលនេះ អាចបោះពុម្ពបានដោយបុគ្គលស្នើសុំ សម្រាប់ប្រើប្រាស់ជាផ្លូវការ បន្ទាប់ពីបានបំពេញលក្ខខណ្ឌពេញលេញនិងត្រឹមត្រូវតាមគេហទំព័រចុះបញ្ជី ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១១.-**

ក្នុងរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ និងប្រសិនបើគម្រោងដែលស្នើសុំនេះមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមានទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាននិងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីគម្រោងតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើប្រាស់ជាផ្លូវការ ជូនបុគ្គលស្នើសុំតាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ១២.-**

វិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ ក្នុងទម្រង់ឌីជីថល ត្រូវបានបង្កើតឡើងដោយអាចរកប្រភព និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវបានតាមលេខអត្តសញ្ញាណសហគ្រាស តាមគេហទំព័រចុះបញ្ជី ឬនៅតាមក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា ១៣.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចចេញប្រកាស ឬគោលការណ៍ណែនាំ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ផ្នែកទី២

## ការព្យួរ ឬការដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ១៤.-**

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចព្យួរឬដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ក្នុងករណីបុគ្គលស្នើសុំ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- មិនគោរព ឬមិនបន្តគោរពតាមលក្ខខណ្ឌតម្រូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ ដូចកំណត់ក្នុងអនុក្រឹត្យនេះ

២- បានផ្ដល់ព័ត៌មានមិនពិត ឬប្រើឯកសារក្លែងក្លាយ

៣- ប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីព្យួរ ដកហូតឬលុបចោលនូវវិញ្ញាបនបត្រ និងលិខិតបញ្ជាក់នានា ត្រូវអនុលោមតាមអនុក្រឹត្យនេះ និងតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៤

## ការអះអាងភាពត្រឹមត្រូវនៃព័ត៌មានចុះបញ្ជី ក្រមសីលធម៌វិជ្ជាជីវៈ និងការរក្សាការសម្ងាត់

**មាត្រា ១៥.-**

បុគ្គលស្នើសុំ ត្រូវធានាអះអាង តាមទម្រង់អេឡិចត្រូនិក ថាព័ត៌មានស្នើសុំចុះបញ្ជីអាជីវកម្ម និងឯកសារភ្ជាប់ដែលខ្លួនបានបំពេញ និងបញ្ចូលទៅក្នុងគេហទំព័រចុះបញ្ជី ពិតជាព័ត៌មាននិងឯកសារត្រឹមត្រូវនិងមិនក្លែងបន្លំ។ ក្នុងករណីព័ត៌មាននិងឯកសារទាំងនោះ មិនត្រឹមត្រូវឬមានការក្លែងបន្លំ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១៦.-**

អ្នកតំណាងចុះបញ្ជី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដូចខាងក្រោម÷

១-មានភាពសុចរិត និងភាពស្មោះត្រង់ក្នុងការប្រកបអាជីវកម្ម

២-ផ្តល់សេវាប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់

៣-បំពេញភារកិច្ចដោយគិតដល់ប្រយោជន៍របស់អតិថិជនជាចម្បង

៤-ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជន

៥-ត្រូវជៀសវាងមិនឱ្យមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន ឬមានវិធានការសមស្រប ដើម្បីការពារដល់ផលប្រយោជន៍អតិថិជន និងត្រូវជូនដំណឹងជាមុនដល់អតិថិជន ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍។

អ្នកតំណាងចុះបញ្ជី ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់សម្រាប់ចុះបញ្ជីអាជីវកម្មដែលតម្រូវដោយអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន។

**មាត្រា ១៧.-**

មន្ត្រីអនុវត្តការងារពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈដែលកំណត់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត។ មន្ត្រីពាក់ព័ន្ធទាំងនេះ ត្រូវរក្សាការសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានឬឯកសារភ្ជាប់ដែលតម្រូវក្នុងអនុក្រឹត្យនេះ ដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ច ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គលស្នើសុំ ឬអ្នកតំណាងចុះបញ្ជី។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវមាននីតិវិធី មធ្យោបាយ និងយន្តការផ្ទៃក្នុង ដើម្បីរក្សាការសម្ងាត់នូវរាល់ព័ត៌មាននិងឯកសាររបស់បុគ្គលស្នើសុំ។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច អាចរៀបចំប្រកាសអន្តរក្រសួង ដើម្បីគ្រប់គ្រងព័ត៌មាន និងឯកសារភ្ជាប់ដែលតម្រូវដោយអនុក្រឹត្យនេះ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

## នៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០

## សទ្ទានុក្រម

**១.បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**២.អ្នកតំណាងចុះបញ្ជី** សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងទទួលបានការផ្ទេរសិទ្ធិពីបុគ្គលស្នើសុំ ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ ដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទនិងលក្ខខណ្ឌតម្រូវព័ត៌មានដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៣.ការចុះបញ្ជីអាជីវកម្ម** សំដៅដល់ការចុះបញ្ជីអាជីវកម្ម តាមគេហទំព័រចុះបញ្ជី តាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីទទួលបាន ក្នុងទម្រង់ឌីជីថលនូវ÷

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការពិនិត្យនិងទទួលសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**៤.គេហទំព័រចុះបញ្ជី** សំដៅដល់គេហទំព័ររួមមួយ សម្រាប់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងទម្រង់អេឡិចត្រូនិក ដូចមានចែងក្នុងអនុក្រឹត្យនេះ។

**៥.លេខអត្តសញ្ញាណសហគ្រាស** សំដៅដល់លេខបញ្ជាក់អត្តសញ្ញាណសហគ្រាស ដែលផ្តល់ឱ្យដោយប្រព័ន្ធស្វ័យប្រវត្តិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៦.ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (Cambodia Data Exchange - CamDX) សំដៅដល់ថ្នាលបច្ចេក-វិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានាដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ក្នុងគោលដៅតភ្ជាប់ជាប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល។

**៧.ទម្រង់អេឡិចត្រូនិក** សំដៅដល់ព័ត៌មាន ឬទិន្នន័យ ដែលអាចយកមកដំណើការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងចែករំលែក រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**៨.ឯកសារទម្រង់ឌីជីថល** សំដៅដល់ឯកសារដែលមានទម្រង់ជា Portable Document Format (PDF) ឬរូបភាព សម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ដែលបានស្កែន ឬថតចេញពីឯកសាររូបី ឬឯកសារដែលមានទម្រង់ជា PDF ឬរូបភាព ដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

**៩.លិខិតបញ្ជាក់** សំដៅដល់ការបញ្ជាក់ក្នុងទម្រង់ឌីជីថល ដូចខាងក្រោម÷

- ប័ណ្ណពន្ធប៉ាតង់ ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការទទួលនូវសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...............សហវ.....ប្រក

# ប្រកាសអន្តរក្រសួង

## ស្ដីពី

## ការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ    រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ត្រូវបានកែសម្រួលតម្លៃសេវាសាធារណៈលើប្រភេទសេវាចំនួនបី នៃកម្រងសេវាសាធារណៈដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម÷

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវាចាស់ | តម្លៃសេវាកែសម្រួលថ្មី |
|---|---|---|---|
| | I. **អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម** | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០៛ | ១ ០១០ ០០០៛ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០៛ | ១៨០ ០០០៛ |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០៛ | ២៥ ០០០៛ |

**ប្រការ២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible]..សហវ..[illegible]

# ប្រកាសរួម

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.ប្រក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ស្ទួននៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មអនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសរួមនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្ដឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្ដល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្ដឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៤ .–**

ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្ម ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្ដល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្ដល់សេវាសាធារណៈរបស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្ដុំសេវាឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៥ .–**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្ដល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .–**

រដ្ឋបាលកណ្ដាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមសមត្ថកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្ដាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្ដីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .–**

ក្រសួងពាណិជ្ជកម្មត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ .-**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ .-**

ត្រូវបាននិរាករណ៍ប្រកាសរួម ដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ [illegible]... សហវ.ប្រក ចុះថ្ងៃទី២៣... ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

| លេខរៀង ចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| | ខ. ការសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | |
| ៣ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៤ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១៥០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| | គ. ការសុំចុះបញ្ជីកែប្រែ | | | |
| | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | | | |
| ៥ | - ការកែប្រែផ្លាស់ប្តូរភាគហ៊ុន ការបន្ថយដើមទុន ការបង្កើនដើមទុន | ៨០០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៦ | - ការកែប្រែផ្សេងៗ(អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ តម្កល់លក្ខន្តិកៈ ទីស្នាក់ការ ។ល។) | ២៤០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៧ | - ពិន័យករណីមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរ កែប្រែផ្សេងៗ នៅក្រសួងពាណិជ្ជកម្ម | ១ ០០០ ០០០ ៛ | | ១ ដង |
| ៨ | - ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ៩ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឃ. ការតម្កល់ប្រតិវេទីប្រចាំឆ្នាំ | | | |
| ១០ | ១ សេវាតម្កល់ប្រតិវេទ៍ប្រចាំឆ្នាំ | ៨០ ០០០ ៛ | ១ ថ្ងៃ | ១ ឆ្នាំ |
| ១១ | ២ ការពិន័យចំពោះការមិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំ | ២ ០០០ ០០០ ៛ | | |
| ១២ | ង. ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | ៨០ ០០០ ៛ | ៣ ថ្ងៃ | |
| ១៣ | ច. ទទួលពាក្យស្នើសុំអនុវត្តដីការរក្សាការពារ និងទទួលពាក្យសម្របសម្រួលដោះស្រាយវិវាទ | ១ ០០០ ០០០ ៛ | ១ ថ្ងៃ | |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០ ៛ | ១ ថ្ងៃ | ៣ ខែ |
| ១៥ | ជ. លិខិតបញ្ជាក់ផ្សេងៗ ផ្ទេរសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធ (តាមការស្នើសុំ) | ១៦០ ០០០ ៛ | ៣-៥ ថ្ងៃ | ១ ដង |
| ១៦ | ឈ. ការទាញយកវិញ្ញាបនបត្រ ឬ ការទាញយកសម្រង់ព័ត៌មាន ជាថ្មីទៀតពីប្រព័ន្ធស្វ័យប្រវត្តកម្ម | ៨០ ០០០ ៛ | | ១ ដង |
| ១៧ | ញ. ការផាកពិន័យលើការក្លែងបន្លំឯកសារតម្រូវសម្រាប់ការចុះបញ្ជី | ១ ០០០ ០០០ ៛ | | ១ ដង |
| | ដ. ការងារពិគ្រោះយោបល់ផ្នែកច្បាប់ (តាមការស្នើសុំ) | | | |
| ១៨ | ១ សេវាពិគ្រោះយោបល់ចុះបញ្ជីពាណិជ្ជកម្ម ÷ | ៤០០ ០០០ ៛ | ១ ថ្ងៃ | |
| | - ពិនិត្យ និងបញ្ជាក់លើភាពស្របច្បាប់នៃឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យា ឬ លក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យ និងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈ ក្រុមហ៊ុនដែលមានការចាំបាច់ | | | |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៩ | ២ សេវាពិគ្រោះយោបល់ផ្នែកច្បាប់ទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ÷ | ២០០ ០០០ ៛ | ១ ថ្ងៃ | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យាឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់បកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់ | | | |
| ២០ | ៣ សេវារៀបចំលក្ខន្តិកៈក្រុមហ៊ុន(ចុះបញ្ជីពាណិជ្ជកម្មថ្មី និងការកែប្រែលក្ខន្តិកៈ) | ៤០០ ០០០ ៛ | ២ ថ្ងៃ | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៦ ព.ណ.ឧ.ឃ.ព - ប្រក

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣/ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់ឲ្យពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះ - ការអនុវត្តន៍នូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់។


ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

**ប្រការ ៥.-**

ឯកសារតម្រូវ ដែលត្រូវផ្តល់ជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

- កំណត់ហេតុ និងសេចក្តីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន (ច្បាប់ដើម) ចំនួន ០៣ ច្បាប់
- ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្តូរ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
  (វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណី ក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន)
- ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងរូបថតទំហំ ៤ x ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ ( ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី )
- ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង - ស្ថាប័នពាក់ព័ន្ធ " បើសិនជាមាន " ចំនួន ០៣ ច្បាប់

**ប្រការ ៦.-**

ប្រកាសលេខ ០៩៩MOC/SM2008 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម ស្តីពី បែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ុន ចាន់ថុល

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ក្រសួង-ស្ថាប័ន
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម**
Law on Commercial Rules and Register
**មាត្រា ៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី**
Articles : 12, 13, 17 new, 18, 42 new, 44 new
**ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម**
Company Registration

**គំរូ ក**
Form A

## បង្កាន់ដៃទទួលតម្កល់ទុក
Receipt For Filing

**នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** Commercial Registration Department
**ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម** Commercial Registration Office
បានទទួលតម្កល់ទុកនូវសំណុំលិខិតស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
Have received the documents for commercial registration

នាមករណ៍របស់ក្រុមហ៊ុន (Name of company) : ..........................................................................................
ទ្រង់ទ្រាយ (Form of company) : ..........................................................................................
ទីស្នាក់ការក្រុមហ៊ុន (Registered office) : ..........................................................................................

ឈ្មោះរបស់ស្ថាបនិក ☐ Name of Promoter
អភិបាល ☐ Director
អាណត្តិគាហក ☐ Proxy

**ប្រភេទនិងចំនួនឯកសារតម្កល់**
Documentation

- ១- ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម Registration Application Form ☐
- ២- លក្ខន្តិកៈក្រុមហ៊ុន Memorandum and Articles of Association ☐
- ៣- ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម Application Form for Publication in the Bulletin ☐
- ៤- សេចក្តីប្រកាសពុំមែនជាមន្ត្រីរាជការនិងពុំមានជាប់ទោសពៃរ៍ Declaration of non-civil servants and non-guilty ☐
- ៥- ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន Copy of Identity card or Passport ☐
- ៦- រូបថត ៤x៦ Photos 4x6 cm ☐
- ៧- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ Bank certificate of registered capital depositing ☐

សាម៉ីជនអ្នកស្នើសុំត្រូវបំពេញសំណុំលិខិតដែលមិនទាន់គ្រប់គ្រាន់ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយឺតចាប់ពីថ្ងៃចេញបង្កាន់ដៃនេះ។
This applicant must submit all the above documents within 15 days after the date of issuance of this receipt.

សាម៉ីជនអ្នកស្នើសុំតម្កល់ទុក សូមធានាអះអាងថា រាល់ឯកសារដែលបានយកមកតម្កល់ទុក ពិតជាត្រឹមត្រូវ មិនមានក្លែងបន្លំលើប្រការណាមួយឡើយ និងបានទទួលវិញ មួយច្បាប់ដើម តម្កល់ទុកនៅក្រុមហ៊ុន ។
The applicant hereby confirm that all documents to be filed are correct complete and no false representation, and has received one copy of submitted documents for filing at the company.

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០
បានទទួលបង្កាន់ដៃ Having received the Receipt

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០
ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម
Chief of Commercial Registration Office

ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

Law on Commercial Rules and Register

មាត្រា ៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី

Articles : 12, 13, 17 new, 18, 42 new, 44 new

ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

Company Registration

គំរូ ក.១

Form A.1

# ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម

## Application for Company Registration

តម្កល់ទុកនៅថ្ងៃទី .......... ខែ ........... ឆ្នាំ ........... នៅម៉ោង ..........................................................................

Filed on at

លេខចុះក្នុងបញ្ជីកាលប្បវត្តិ ៖ ..........................................................................................................

Order in chronological registration number

លេខចុះក្នុងបញ្ជីវិភាគ ៖ ...................................................................................................................

Order in analytical registration number

នាមត្រកូលនិងនាមខ្លួន ៖ .........................................................................................................................

Name and Surname

សញ្ជាតិ ៖ .........................................................................................................................

Nationality

អាស័យដ្ឋានបច្ចុប្បន្ន ៖ .........................................................................................................................

Current address

អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនលេខ ៖ ........................................ ចុះថ្ងៃទី ............... ខែ ...................... ឆ្នាំ ......................

Identity Card/Passport number Issued on

ធ្វើក្នុងនាមជា ៖ ស្ថាបនិក ☐ អភិបាល ☐ អាណត្តិគាហក ☐

In the name of Promoter Director Proxy

នៃក្រុមហ៊ុន ៖ .........................................................................................................................

of the company

លិខិតប្រគល់សិទ្ធិចុះថ្ងៃទី ខែ ឆ្នាំ (បើជាអាណត្តិគាហក) ៖ ..........................................................................

Date of issuing Power of Attorney (If Proxy)

សុំចុះឈ្មោះក្រុមហ៊ុនដូចបានពោលខាងលើនៅក្នុងបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយធ្វើសេចក្តីបញ្ជាក់

Request for registering the above company in the commercial Register of the Ministry of Commerce with following

ដែលជានាអះអាងថាត្រឹមត្រូវ ដូចតទៅ ៖

due declarations :

១- នាមករណ៍ក្រុមហ៊ុន ៖ .........................................................................................................................

Company's Name

សញ្ជាតិក្រុមហ៊ុន ៖ .........................................................................................................................

Company's Nationality

គំរូហត្ថលេខារបស់អ្នកស្នើសុំ ៖ .........................................................................................................................

Specimen Signature of the applicant

គំរូត្រារបស់ក្រុមហ៊ុន ៖ .........................................................................................................................

Specimen Seal of the company

២- អភិបាល ☐

Director

| ល.រ No. | នាមត្រកូល និង នាមខ្លួន Name and Surname | សញ្ជាតិ Nationality | លេខ និង កាលបរិច្ឆេទនៃ អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន Identity card or passport number Issued and expiry date | អាសយដ្ឋាន Address | ហត្ថលេខាគំរូ Sample of Signature |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| **តតិយជនមានអំណាចចុះហត្ថលេខាទទួលខុសត្រូវជូនក្រុមហ៊ុន** Third person authorized to sign on behalf of the company | | | | | |
| ១ | | | | | |
| ២ | | | | | |

៣- **កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន ៖**

Business Objective

សកម្មភាពធ្វើអាជីវកម្មចម្បង ៖ ..........................................................................................................

Main activities

..........................................................................................................

សកម្មភាពបន្ទាប់បន្សំ ៖ អាហរណកម្ម នីហរណកម្ម ☐ ទិញ-លក់ក្នុងប្រទេស ☐ ហាង ☐ ឃ្លាំងទុក ☐

Secondary Objective : Import Export | Domestic Sell-Purchase | Shop | Warehouse

សេវាកម្ម ☐ អាជីវកម្មកសិកម្ម ☐ រ៉ែ ☐ រោងចក្រ ☐ សិប្បកម្ម ☐ ការដំឡើង ☐ ការជួសជុល ☐ សំណង់ ☐

Service | Agriculture | Mine | Factory | Handicraft | Installation | Repairing | Construction

ដឹកជញ្ជូន ☐ ទេសចរណ៍ ☐ សណ្ឋាគារ ☐ ភោជនីយដ្ឋាន ☐ ក្លឹបកម្សាន្ត ☐

Transportation | Tourism | Hotel | Restaurant | Resort

ដទៃទៀត ៖ (បញ្ជាក់) ..........................................................................................................

Others (List)

៤- ទម្រង់ក្រុមហ៊ុន (Form of Company)

- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ☐ មានកម្រិត ☐
  General Partnership Limited
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ☐
  Private Limited Company
- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ☐
  Single Member Private Limited Company
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ☐
  Public Limited Company
- គ្រឹះស្ថានសាធារណៈ ☐
  Public Institute
- ក្រុមហ៊ុនរដ្ឋ ☐
  State Enterprise
- ក្រុមហ៊ុនចម្រុះ ☐
  Joint Venture

កាលបរិច្ឆេទចុះបញ្ជី ៖
Date of registration

កាលបរិច្ឆេទរំលាយ ៖
Date of dissolution

៥- អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ៖ លេខ.................... ផ្លូវ.................... ឃុំ/សង្កាត់ ....................
Address of Registered Office No. Street Commune
ស្រុក/ខណ្ឌ.................................... ខេត្ត/ក្រុង ....................................
District Province/City
ទូរស័ព្ទ (Tel).................................... ទូរសារ (Fax)....................................

៦- សាខានៅកម្ពុជា ៖ មាន ☐ គ្មាន ☐
Branches in Cambodia Yes No
អាសយដ្ឋានសាខា (Address) ៖ .................................................... ទូរស័ព្ទ (Tel)....................................

៧- សាខាឬទីភ្នាក់ងារនៅបរទេស ៖ មាន ☐ គ្មាន ☐
Foreign branch or agent Yes No
អាសយដ្ឋានសាខា (Address) ៖ .................................................... ទូរស័ព្ទ (Tel)....................................

៨- ចំនួនទឹកប្រាក់នៃដើមទុនចុះបញ្ជី ៖ ....................................................................................
Amount of registered capital
ជាអក្សរ (In words) ៖ ....................................................................................

៩- ប្រភពដើមនៃដើមទុនចុះបញ្ជី ៖
Source of registered capital

ភាគទុនជាសាច់ប្រាក់ ៖ មាន ☐ គ្មាន ☐ តម្លៃ ៖ ....................................
Contribution in Cash Yes No Amount

ភាគទុនជាវត្ថុ ៖ មាន ☐ គ្មាន ☐ តម្លៃ ៖ ....................................
Contribution in Kind Yes No Amount

ភាគទុនខាងជំនាញ ៖ មាន ☐ គ្មាន ☐ តម្លៃ ៖ ....................................
Contribution in Expertise Yes No Amount

១០- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជី ៖ លេខ.................... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ ............
Bank Certificate of Registered Capital Depositing No. Date
តម្កល់នៅធនាគារ ៖ ....................................................................................
Deposited at the Bank

១១- ភាគទុនរបស់សមាជិក ☐ សហកម្មសិទ្ធិករ ☐ ហត្ថលេខា
Contribution of members Partners Signature

១- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
២- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៣- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៤- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៥- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៦- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៧- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៨- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
៩- លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution
១០-លោក-លោកស្រី........................................ដាក់ភាគទុនចំនួន ..............................
Mr./Mrs. Contribution

១២- ប្រកាសនីយបត្រតក្កកម្មដែលធ្វើអាជីវកម្ម (Patent) ៖ មាន Yes ☐ គ្មាន No ☐ ..............................
(បញ្ជាក់) List : ..............................................................................

១៣- សញ្ញាសម្គាល់ពាណិជ្ជកម្ម ឬសញ្ញាផលិតកម្ម ដែលបានតម្កល់ទុកនិងប្រើប្រាស់ ៖ មាន Yes ☐ គ្មាន No ☐
Trade mark or Production mark filled and used
(បញ្ជាក់) ៖ លេខតម្កល់ទុក Filing Number : .................... ថ្ងៃទី (Date) ........... ខែ .............. ឆ្នាំ ២០
ទីកន្លែងតម្កល់ទុក Place of Filing : ..............................................................
ធ្វើនៅភ្នំពេញ (Phnom Penh) ថ្ងៃទី (Date)............ ខែ.............. ឆ្នាំ ២០
ហត្ថលេខា
Signature

ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ដែលចុះហត្ថលេខាខាងក្រោម
The Chief of Commercial Registration Office with the signature below
បញ្ជាក់ថា៖សេចក្តីដែលមានចែងក្នុងពាក្យសុំនេះត្រូវបានចុះបញ្ជីពាណិជ្ជកម្ម
certify that the statement in this application is registered in the analytical
..............................................
company registration under this number of
ចុះថ្ងៃទី (Date) ..............................................................
ធ្វើនៅភ្នំពេញ (Phnom Penh) ថ្ងៃទី (Date) ខែ ឆ្នាំ ២០
ប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម
Chief of Commercial Registration Office

ច្បាប់ស្តីពី វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
Law on the Commercial Rules and Registration
មាត្រា ៖ ១២, ១៣, ១៧, ១៨, ៤២, ៤៤
Article: 12, 13, 17, 18, 42, 44
ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
COMPANY REGISTRATION

គំរូ ក.២
Form A.2

ក្រុមហ៊ុន Company....................................................................................................

**ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម**
Application for Publication in the Bulletin

អភិបាលក្រុមហ៊ុន The Director of..............................................................

សូមជម្រាបមក Hereby inform

លោកប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម

សូមលោកនាយកមេត្តាចាត់ចែងចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម
We would like you to organize publication in The Weekly Business Roundup

នូវសេចក្តីប្រកាសផ្សាយស្តីពីការបង្កើតក្រុមហ៊ុន.......................................................................
of the setting up of company

D/STI

អត្ថបទនៃសេចក្តីប្រកាសមានដូចខាងក្រោម The publication will be as follow

**សេចក្តីប្រកាសស្តីពីការបង្កើតក្រុមហ៊ុន** Publication of Setting up of Company

នាមករណ៍ក្រុមហ៊ុន :.........................................................................................

Name of Company: .........................................................................................

ទម្រង់ច្បាប់ (Form of Company): .........................................................................................

ទីស្នាក់ការលេខ (Address): ....................ផ្លូវ....................ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ....................

ខេត្ត/ក្រុង....................លេខទូរស័ព្ទ....................អ៊ីម៉ែល....................

កម្មវត្ថុអាជីវកម្មសង្ខេប :.........................................................................................

Objective of Business in brief: .........................................................................................

ថេរវេលា (Duration): គិតចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម (From the date of registration) ចំនួន....................ឆ្នាំ

ចំនួនដើមទុនចុះបញ្ជី (Registered Capital): ....................បែងចែកជា (Divided into)....................ភាគហ៊ុន (Shares)

ភាគហ៊ុននិមួយៗមានតម្លៃ (Value of Share): .........................................................................................

ឈ្មោះរបស់អភិបាល (Name of Director): ....................មុខរបរ (Occupation)....................សញ្ជាតិ (Nationality)........

អាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ....................ផ្លូវ....................ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ....................

Current Address ខេត្ត/ក្រុង ....................លេខទូរស័ព្ទ....................អ៊ីម៉ែល....................

ក្រុមហ៊ុននឹងត្រូវបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។
The Company will be registered in the commercial registration at the Ministry of Commerce.

លោក/លោកស្រី (Mr. /Mrs.)....................................................................................

សូមលោកនាយកទទួលនូវការគោរពនិងរាប់អានអំពីខ្ញុំ
Please, Dear Director, Accept my highest consideration

អភិបាលក្រុមហ៊ុន
Director of Company

បានទទួលនិងយល់ព្រមចុះផ្សាយ (Received and Agreed to publish)

ក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម លេខ No....................................

ចេញផ្សាយ ថ្ងៃទី....................ខែ ....................ឆ្នាំ....................

រាជធានីភ្នំពេញ. ថ្ងៃទី....................ខែ....................ឆ្នាំ.........

**ប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម**

ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
Law on Commercial Rules and Register
មាត្រា ៖ ១២, ១៣, ១៧ ថ្មី, ១៨, ៤២ ថ្មី, ៤៤ ថ្មី
Articles : 12, 13, 17 new, 18, 42 new, 44 new
ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
Company Registration

គំរូ ក.៣
Form A.3

# សេចក្តីប្រកាសពុំមែនជាមន្ត្រីរាជការ និងពុំមានជាប់ទោសពៃរ៍
Declaration of non-civil servant and non-guilty

ខ្ញុំបាទ-នាងខ្ញុំ ជាអភិបាលនៃក្រុមហ៊ុន ................................................................
We, as the directors of the Company
ដែលមានឈ្មោះដូចខាងក្រោម ៖
which name below

| ល.រ No. | ឈ្មោះ Name | ល.រ No. | ឈ្មោះ Name |
|---|---|---|---|
| ១ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on | ៤ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on |
| ២ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on | ៥ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on |
| ៣ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on | ៦ | លោក-លោកស្រី.................................... Mr./Mrs.<br>អាយុ............ឆ្នាំ មុខរបរ.................................... Age Occupation<br>អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន Identity Card/Passport<br>លេខ........................ចុះថ្ងៃទី........................ Number Issued on |

## សូមប្រកាស និងអះអាងចំពោះមុខច្បាប់ថា៖

Hereby have the honor to declare that :

ខ្ញុំបាទ-នាងខ្ញុំ ពុំមែនជាមន្ត្រីរាជការបម្រើក្នុងក្រសួង ឬស្ថាប័នរដ្ឋណាមួយឡើយ ហើយមិនដែលត្រូវបានជាប់ទោសពៃរ៍ណាមួយទោះបីទោសព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាលក្តី ដែលទាក់ទងដល់ការហាមឃាត់សកម្មភាពវិស័យពាណិជ្ជកម្មរបស់ខ្ញុំបាទ-នាងខ្ញុំឬហាមឃាត់ខ្ញុំបាទ-នាងខ្ញុំ ក្នុងនាទីជាអ្នកចាត់ចែងគ្រប់គ្រងសហគ្រាសពាណិជ្ជកម្មណាមួយឡើយ ។

We are not the civil servant in any State Ministry or Institution and have never been convicted for criminal, civil or administration liabilities related to our business activities or prohibited by law from doing business or being the manager of any commercial enterprise.

ក្នុងករណី ដែលសេចក្តីប្រកាសនេះមិនត្រឹមត្រូវតាមការពិត ខ្ញុំបាទ-នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងនៅចំពោះមុខច្បាប់ជាធរមាន ។

In the case there is any falsification we will be responsible infront of the applicable laws.

ធ្វើឡើងចំនួន .......... ច្បាប់ដើម នៅ........................... ថ្ងៃទី............ ខែ................ ឆ្នាំ ២០

ហត្ថលេខា

**ពាក្យស្នើសុំចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម**
Application for Publication in the Bulletin
អភិបាលក្រុមហ៊ុន The Director of.............................................

ស្ទូមជម្រាបមក Hereby inform

លោកប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម

សូមលោកនាយកមេត្តាចាត់ចែងចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម
We would like you to organize publication in The Weekly Business Roundup

| គំរូ ក ៣ |
|---|
| Form B.3 |

**D/STI**

**សេចក្តីប្រកាស**
**ស្តីពី**
**ការរំលាយក្រុមហ៊ុន**

ក្រុមហ៊ុន :.............................................................................(ស្ថិតក្នុងការជំរះបញ្ជី)
:...............................................................................................

ទ្រង់ទ្រាយ :...............................................................................................

ដើមទុន :...............................................................................................

ទីស្នាក់ការ :ផ្ទះលេខ..........ផ្លូវ.........ឃុំ/សង្កាត់.............ស្រុក/ខណ្ឌ............ខេត្ត/ក្រុង.............

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម:..........................................ចុះថ្ងៃទី...............ខែ....................ឆ្នាំ............

ប្រកាសរំលាយមុនកាលកំណត់: ចាប់ពីថ្ងៃទី............ខែ............ឆ្នាំ.............................................

សេចក្តីរំលាយ :អង្គប្រជុំថ្ងៃទី.........ខែ....................ឆ្នាំ...........................................

អ្នកជំរះបញ្ជី :លោក/លោកស្រី...............................................................................

:អាសយដ្ឋានផ្ទះលេខ.......ផ្លូវ......ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ..............ខេត្ត/ក្រុង.........

ទីកន្លែងជំរះបញ្ជី :ទីស្នាក់ការក្រុមហ៊ុន...........................................................................

អាសយដ្ឋានផ្ទះលេខ........ផ្លូវ.....ឃុំ/សង្កាត់.........ស្រុក/ខណ្ឌ.........ខេត្ត/ក្រុង...........

ទីកន្លែងទាក់ទងព័ត៌មាន :ទីស្នាក់ការក្រុមហ៊ុន.....................................................................

អាសយដ្ឋានផ្ទះលេខ........ផ្លូវ........ឃុំ/សង្កាត់........ស្រុក/ខណ្ឌ..........ខេត្ត/ក្រុង..........

លេខទូរស័ព្ទ.....................អ៊ីម៉ែល.................................................................

រាល់សំណុំលិខិតដែលទាក់ទងនឹងការរំលាយក្រុមហ៊ុននិងការជំរះបញ្ជីនឹងត្រូវយកទៅតំកល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ធ្វើនៅ................ថ្ងៃទី ខែ ឆ្នាំ ២០

**អ្នកជំរះបញ្ជី**

សូមលោកនាយកទទួលនូវការគោរពនិងរាប់អានអំពីខ្ញុំ ។
Please, Dear Director, Accept my highest consideration

អភិបាលក្រុមហ៊ុន
Director of Company

បានទទួលនិងយល់ព្រមចុះផ្សាយ(Received and Agreed to publish)
ក្នុងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម លេខ No..............................
ចេញផ្សាយ ថ្ងៃទី.................ខែ ................ឆ្នាំ.....................

រាជធានីភ្នំពេញ. ថ្ងៃទី..............ខែ..............ឆ្នាំ.............

**ប្រធាននាយកដ្ឋានស្ថិតិ និង ព័ត៌មានពាណិជ្ជកម្ម**

ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៤

# រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ជំរាបមក

លោក ជា សុខ ជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា ភីអិលស៊ី

អាស័យដ្ឋាន : លេខ 28 មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ** : ករណីស្នើសុំតំកល់ទុកលក្ខន្តិកៈថ្មី និងចេញវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA Bank Plc.

**យោង** :
- សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 22 / 12 / 2002
- លិខិតអនុញ្ញាតិ លេខ 2961 ពណ. ឧតក ចុះថ្ងៃទី 21 / 08 / 2000 របស់ក្រសួងពាណិជ្ជកម្ម
- លក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា លីមីធីតចាស់តំកល់លេខ 529/00 ចុះថ្ងៃទី 05 / 06 / 2000
- អាជ្ញាបណ្ណធ្វើប្រតិបត្តិការលេខ 01 BIS ចុះថ្ងៃទី 01 / 12 / 2003 របស់ធនាគារជាតិ
- វិញ្ញាបនប័ត្របញ្ជាក់លេខ ធ៧-០៣-០៨០ ល.ប ចុះថ្ងៃទី 19 / 12 / 2003 របស់ធនាគារជាតិ
- លក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ីថ្មី ចុះថ្ងៃទី 25 / 11 / 2003 ដែលទទួលស្គាល់ដោយធនាគារជាតិ
- សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្ម លេខ 258 ចេញផ្សាយថ្ងៃទី 31-12 - 2003
- សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងសារពត៌មាន មហាបុរសខ្មែរ លេខ 45 ចេញផ្សាយថ្ងៃទី 25-12- 2003

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការទទួលតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន ធនាគារ អេស៊ីលីដា លីមីធីត ACLEDA BANK LIMITED ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោម លេខ Co. 5185 / 00P ចុះថ្ងៃទី 05 - 06 - 2000 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើនិងយោងខាងលើគឺ :

- នាមករណ៍ចាស់ គឺ ធនាគារ អេស៊ីលីដា លីមីធីត ACLEDA BANK LIMITED មានទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត បានប្តូរ មកនាមករណ៍ថ្មី គឺ ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA Bank Plc.
- ការបញ្ចូលសមាជិកថ្មី ០១ រូប ជានីតិបុគ្គល គឺ ក្រុមហ៊ុន TRIODOS CUSTODY B.V. តំណាងដោយ អ្នកស្រី MARIELOE VAN GOLSTEIN BROUWERS
- ការបង្កើនដើមទុនពី ៤.០០០.០០០ ដុល្លារអាមេរិក មក ១៣.០០០.០០០ ដុល្លារអាមេរិក និងធ្វើការបែងចែកភាគហ៊ុនថ្មី ដូចមាននៅក្នុងលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន ។

-ការតែងតាំងអភិបាលថ្មី ៖

-លោក ខាំ សុខ / " តតីយជន " ប្រធានក្រុមប្រឹក្សាភិបាល

-លោក JOHN BRINSDEN / " តតីយជន " អភិបាល

-លោក PETER KOOI / " តតីយជន " អភិបាល

-អ្នកស្រី JUTTA ELISABETH WAGENSEIL / " តតីយជន " អភិបាល

-លោក EMILE HUBERT JOSEPH GROOT / " តតីយជន " អភិបាល

- លោក DEEPAK CHAND KHANNA / " តតីយជន " អភិបាល

- អ្នកស្រី FEMKE BOS / " តតីយជន " អភិបាល

- លោក ឡុញ ថុល / " តតីយជន " អភិបាល

- អ្នកស្រី សុខ វណ្ណនី / " តតីយជន " អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងក្រុមហ៊ុន ដែលអាចកើតមានឡើងក្រោយការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។

ជ.រដ្ឋមន្ត្រី
អនុរដ្ឋលេខាធិការ

គីម ស៊ីថន

ចំលងជូន ៖

-ក្រសួងមហាផ្ទៃ ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ធនាគារជាតិនៃកម្ពុជា
-សាលាក្រុងភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ.............................ពណ.ធពក

# វិញ្ញាបនប័ត្រ

## បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

នាមករណ៍ : ធនាគារ អេស៊ីលីដា ភីអិលស៊ី
: ACLEDA Bank Plc.
:
:

ចុះបញ្ជីក្រោមលេខ : Co. ៥១៩៥/00P ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០

ត្រូវបានទទួលស្គាល់ថាជា : ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ស្ថិតក្រោម បទបញ្ញត្តិ នៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

ភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ ២០០៥

# លក្ខន្តិកៈរបស់ធនាគារ

# អេស៊ីលីដា ភីអិលស៊ី

# ( ACLEDA Bank.PLc )

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ACLEDA Bank Plc.

# លក្ខន្តិកៈ

# Articles of Association

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
ដើមទុនចុះបញ្ជី ១៣លានដុល្លារអាមេរិក

អាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ
ថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣

# លក្ខន្តិកៈធនាគារអេស៊ីលីដា ភីអិលស៊ី

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជ

## ជំពូកទី១ ប្រការទូទៅ

**មាត្រាទី ១-** នាម :

ធនាគារនេះ មាននាមជាភាសាខ្មែរថា ធនាគារអេស៊ីលីដា ភីអិលស៊ី និងជាភាសា អង់គ្លេសថា ACLEDA Bank Public Limited Company (ACLEDA Bank Plc ចាប់ពីនេះតទៅហៅថា ធនាគារ ។

**មាត្រាទី ២-** លក្ខណៈច្បាប់ :

ធនាគារ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមច្បាប់ និងការអនុវត្តនៃព្រះរាជាណាចក្រកម្ពុជា ។ បំណុលរបស់ភាគទុនិកៈនិមួយៗត្រូវបាន កំណត់ ត្រឹមមូលធនភាគហ៊ុនរបស់ខ្លួនដែលបានចុះបញ្ជីរួចហើយ និង ពុំទាន់បានបង់ប្រាក់ ចូលធនាគារ លើកលែងតែករណី ដូចមានចែងក្នុងមាត្រាទី៤៥ ខាងក្រោម ។

**មាត្រាទី ៣-** គោលដៅ :

ធនាគារ ត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោមបទប្បញ្ញត្តិរបស់ ធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជាធនាគារពាណិជ្ជកម្ម តាមរយៈការិយាល័យកណ្ដាល នៅភ្នំពេញ និងសាខានានានៅតាមបណ្ដាខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្ដោត យកចិត្តទុកដាក់ជាពិសេសលើការផ្ដល់សេវាកម្មឥណទាន និង សេវាកម្មផ្សេងទៀតរបស់ធនាគារ ជូនស្រទាប់ទីផ្សារជាន់ទាប ព្រមទាំងចូលរួម ក្នុងសកម្មភាពដទៃទៀតដែល ក្រុមប្រឹក្សាភិបាល យល់ឃើញថាស្របនឹងគោលដៅ ។

**មាត្រាទី ៤.** **ការិយាល័យដែលចុះបញ្ជី :**

ការិយាល័យ ធនាគារ ចុះបញ្ជីនៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអាច បើកការិយាល័យបន្ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅក្នុងប្រទេសដទៃទៀត ហើយអាចផ្លាស់ប្ដូរការិយាល័យដែលបានចុះបញ្ជី បន្ទាប់ពីបានចុះបញ្ជី ក្រសួងពាណិជ្ជកម្ម និងបានទទួលការយល់ព្រមពីធនាគារជាតិនៃកម្ពុជា អោយផ្លាស់ប្ដូរផងដែរ ។

**មាត្រាទី ៥.** **ត្រានិងផ្លាកសញ្ញា :**

ក) ធនាគារ ត្រូវបង្កើតត្រាកាលណាតម្រូវអោយមាន ។

ខ) ផ្លាកសញ្ញានៃធនាគារ គឺរូបហង្សពណ៌មាសឈរនៅចំកណ្ដាលរង្វង់មូលពណ៌ខៀវ។

## ជំពូកទី ២ ភាគហ៊ុន និងមូលធនភាគហ៊ុន

**មាត្រាទី ៦.** **ភាគហ៊ុន និងមូលធនភាគហ៊ុនដែលចុះបញ្ជី :**

មូលធនសរុបរបស់ធនាគារ ដែលចុះបញ្ជី មានចំនួន ១៣.០០០.០០០ដុល្លារអាមេរិក (ដប់បីលានដុល្លារអាមេរិក) ចែកជា ១៣.០០០.០០០ (ដប់បីលាន) ភាគហ៊ុន តំលៃភាគហ៊ុននិមួយៗ គឺស្មើនឹង ១.០០ដុល្លារ (មួយដុល្លារអាមេរិក) ។ ភាគហ៊ុននិមួយៗ មានសម្លេងឆ្នោតមួយ (១) សំលេង ហើយនឹងបានទទួលភាគលាភ និងរាល់ការបែងចែកផ្សេងៗទៀតរបស់ធនាគារស្មើភាពគ្នា ។ ការបែងចែងនៃភាគហ៊ុន មិនត្រូវបោះផ្សាយទេ ។

**មាត្រាទី ៧.** **ភាគទុនិក :**

៧.១ ACLEDA NGO ជាអង្គការក្រៅរដ្ឋាភិបាល ដែលមានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ព្រះរាជាណាចក្រកម្ពុជា ក្នុងអាសយដ្ឋាន នៅផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីពេលនេះទៅហៅថា "ACLEDA NGO") ។

៧.២ អេ អេស អេ អ៊ីន្ស ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និង ចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាស័យដ្ឋាន ផ្ទះលេខ ២៨ មហាវិថីម៉ៅសេទុង សង្កាត់ បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ចាប់ពីនេះតទៅហៅថា "ASA, Inc") ។

៧.៣ DEG: Deutsche Investitions-und Entwicklungsgesellschaft mbH ដែលជាក្រុមហ៊ុនទទួល ខុសត្រូវមានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងអាស័យដ្ឋាន Belvederestr. 40, D-50933, Cologne, German (ចាប់ពីនេះតទៅហៅថា "DEG") ។

៧.៤ Nederlandse Financierings-Maatschappij voor Ontwikkelingslande N.V. ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសហូឡ ដែលបានចុះបញ្ជីក្នុងអាស័យដ្ឋាន Anna Van Saksenlaan 71, 2593 HW, The Hague, the Netherlands (ចាប់ពីនេះតទៅហៅថា "FMO") ។

៧.៥ International Finance Corporation បង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀងដែល ចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ ដែលមាន អាស័យដ្ឋាន ការិយាល័យកណ្តាលនៅ 2121 Pennsylvania Avenue, N.W Washington D.C. 20433, U.S.A (ចាប់ពីនេះតទៅហៅថា "IFC") ។

៧.៦ Stichting Triodos Doen ជាមូលនិធិមួយដែលបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់ ដែលមាន ការិយាល័យធំនៅ Utrechtseweg 60, P.O Box 55, 3700 AB Zeist the Netherlands (ចាប់ពីនេះតទៅហៅថា "TRIODOS") និង

៧.៧ Triodos Custody B.V ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ដែលបានបង្កើតឡើង ក្រោមច្បាប់នៃប្រទេសហូឡង់ ក្នុងនាមជាក្រុមហ៊ុន Triodos Fair Share Fund ជាមូលនិធិដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូឡង់ ដែលមាន ការិយាល័យធំ Utrechtseweg 60, P.O Box 55, 3700 AB Zeist, the Netherlands (ចាប់ពីនេះតទៅហៅថា "TC") ។

**មាត្រាទី ៨- ការទិញភាគហ៊ុន :**

ភាគទុនិកៈទាំងអស់ នឹងទិញភាគហ៊ុន តាមចំនួនដូចខាងក្រោមនេះ :

| ភាគទុនិកៈ | ភាគរយនៃកម្មសិទ្ធិ | មូលធនភាគហ៊ុន (US$) | ចំនួនភាគហ៊ុន |
|---|---|---|---|
| ACLEDA NGO | 40.07% | $5,208,457 | 5,208,457 |
| ASA, Inc | 10.93% | $1,421,543 | 1,421,543 |
| DEG | 12.25% | $1,592,500 | 1,592,500 |
| FMO | 12.25% | $1,592,500 | 1,592,500 |
| IFC | 12.25% | $1,592,500 | 1,592,500 |
| TRIODOS | 10.33% | $1,342,500 | 1,342,500 |
| TC | 1.92% | $250,000 | 250,000 |
| <u>TOTAL</u> | 100.00% | $13,000,000 | 13,000,000 |

**មាត្រាទី ៩- មូលបត្រភាគហ៊ុន :**

ភាគទុនិកៈនិមួយៗ មានសិទ្ធិទទួលពីធនាគារនូវមូលបត្រភាគហ៊ុនមួយឬច្រើន ដែលបញ្ជាក់ភាគហ៊ុនរបស់ខ្លួននៅក្នុងធនាគារ ។ មូលបត្រភាគហ៊ុននេះ ត្រូវបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំ ឬក្រុមប្រឹក្សាភិបាលនៃធនាគារចំនួនពីររូប ដោយបញ្ជាក់នាម និងអាស័យដ្ឋានរបស់ធនាគារ បោះត្រាធនាគារ មានចុះលេខរៀង និងចុះកាលបរិច្ឆេទចេញមូលបត្រភាគហ៊ុន មូលបត្រភាគហ៊ុននីមួយៗ ត្រូវសរសេរការហាមឃាត់រាល់ការផ្លាស់ប្តូរ ដែលមានចែងក្នុង មាត្រាទី១៣ទាំងស្រុង ។ ធនាគារនឹងថែរក្សាបញ្ជីផ្ទេរស្តុកដែល កត់ត្រាការបញ្ចេញ, ការបញ្ជូនត្រឡប់មកវិញ, ការលុបចោល ឬកិច្ចការផ្សេងៗទៀតអំពីមូលបត្រភាគហ៊ុន។

**មាត្រាទី ១០- ហត្ថលេខីដែលបានទទួលការអនុញ្ញាត :**

មានតែអ្នកដែលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាភិបាលទេ ដែលមានសិទ្ធិចុះហត្ថលេខាលើឯកសារធនាគារ ដើម្បីដាក់កាតព្វកិច្ចលើធនាគារ។ ហត្ថលេខាដែលគ្មានការអនុញ្ញាត ត្រូវចាត់ទុកជាមោឃៈ ។ ក្រុមប្រឹក្សាភិបាលអាចប្រគល់សិទ្ធិជូនអគ្គនាយកធនាគារ ដែលបានតែងតាំងក្រោមមាត្រាទី ៤២ ។

**មាត្រាទី ១១.** **ការបង្កើនមូលធនដែលបានចុះបញ្ជី :**

ធនាគារ អាចបង្កើនមូលធនដែលបានចុះបញ្ជីរួចហើយ ដោយបញ្ចេញភាគហ៊ុននៅក្នុងធនាគារ បន្ថែមទៀត ដោយមានការយល់ព្រមជាមុនដោយសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១២.** **ការទិញភាគហ៊ុនវិញ :**

តាមច្បាប់ដែលបានអនុញ្ញាត ធនាគារ អាចទិញភាគហ៊ុនរបស់ខ្លួនវិញ ដោយត្រូវមានការយល់ ព្រមជាមុន ដោយមានសំលេងឆ្នោតគាំទ្រយ៉ាងតិចចំនួន ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែល កំពុងបំពេញការងារ និងពីភាគទុនិកៈដែលកាន់កាប់ភាគហ៊ុន៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុន ដែលនៅសល់ក្នុងធនាគារ ។

**មាត្រាទី ១៣.** **ការហាមឃាត់លើការផ្ទេរភាគហ៊ុន :** ភាគហ៊ុននៃធនាគារ ត្រូវស្ថិតក្រោមការហាម ឃាត់លើការផ្ទេរភាគហ៊ុន ដូចតទៅ :

១៣.១ ភាគទុនិកៈ *អង្គការអេស៊ីលីដា* មិនអាចបន្ថយភាគរយនៃភាគហ៊ុនរបស់ខ្លួនតិចជាង ២៨ ភាគរយ នៃមូលធនភាគហ៊ុនធនាគារដែលបានចុះបញ្ជីរួចហើយ ។

១៣.២ ប្រសិនភាគទុនិកៈ *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ភាគហ៊ុនណាមួយរបស់ខ្លួន ទៅអោយនរណាម្នាក់ "ក្នុងនេះហៅថាអ្នកទិញ" តាមការទូទាត់ម្តង ឬច្រើនដង ភាគទុនិកៈផ្សេងៗទៀតទាំងអស់ ក៏មានសិទ្ធិលក់ភាគហ៊ុនរបស់ខ្លួនទៅអ្នកទិញនោះក្នុងតម្លៃ និង លក្ខខ័ណ្ឌដូចគ្នា ដែល *អង្គការអេស៊ីលីដា* លក់ ឬ ប្រកាសលក់ដែរ ។ កិច្ចព្រមព្រៀងទាំង ឡាយណាដែលភាគទុនិក *អង្គការអេស៊ីលីដា* ធ្វើឡើង ដើម្បីលក់ភាគហ៊ុនរបស់ខ្លួនដែលផ្ទុយ ពីមាត្រា១៣.២នេះ គឺចាត់ទុកជាមោឃភាព ។ មាត្រាទី១៣.២នេះ មិនត្រូវអនុវត្តលើការផ្ទេរ ភាគហ៊ុនពី *អង្គការអេស៊ីលីដា* ទៅ ASA, Inc. ទេ ដរាបណា *អង្គការអេស៊ីលីដា* នៅតែកាន់កាប់ភាគហ៊ុន ២៨ ភាគរយ ឬច្រើនជាងនេះនៃមូលនិធិភាគហ៊ុនដែលបានចុះបញ្ជី របស់ធនាគារ ។

## ជំពូកទី ៣ សន្និបាតភាគទុនិកៈ

**មាត្រាទី ១៤-** **សន្និបាតភាគទុនិកៈប្រចាំឆ្នាំ និងសន្និបាតផ្សេងៗ :**

ភាគទុនិកៈ ត្រូវកោះសន្និបាតប្រចាំឆ្នាំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ តែមិនឱ្យលើសពី១៥ថ្ងៃ ក្រោយពីសន្និបាតលើកមុនឡើយ ។ ក្រុមប្រឹក្សាភិបាល ត្រូវកំណត់កាលបរិច្ឆេទ និង ពេលវេលា សន្និបាត ។ សន្និបាតភាគទុនិកវិសាមញ្ញ អាចប្រព្រឹត្តិទៅបានក្នុងករណី :

ក- មានការសំរេចពីក្រុមប្រឹក្សាភិបាល ឬ

ខ- មានការស្នើសុំជាលាយលក្ខណ៍អក្សរពីភាគទុនិកៈទាំងឡាយដែលមានភាគហ៊ុនសរុប មិនតិចជាង ភាគរយនៃភាគហ៊ុនដែលនៅសល់ក្នុងធនាគារ ។ ក្រុមប្រឹក្សាភិបាល "ឬ ភាគទុនិកៈ ណាដែល ជាអ្នកកោះសន្និបាត " នឹងកំណត់របៀបវារៈសន្និបាត ។ សមាជិកក្រុមប្រឹក្សា ២រូប ភាគទុនិកៈណាដែលកាន់កាប់ភាគហ៊ុនចាប់ពី ២០ភាគរយឡើងទៅនៃភាគហ៊ុន ដែលនៅសល់ ធនាគារ អាចស្នើបន្ថែមរបៀបវារៈទៅក្នុងសន្និបាតបាន ។

**មាត្រាទី ១៥-** **ការសំរេចរបស់ភាគទុនិកៈដោយគ្មានការធ្វើសន្និបាត :**

ការសំរេចណាមួយដែលតម្រូវឱ្យសន្និបាតរបស់ភាគទុនិកៈសំរេច អាចអនុវត្តបានដោយគ្មានការ សន្និបាត ក្នុងករណីមានការយល់ព្រមជាលាយលក្ខណ៍អក្សរអោយអនុវត្ត ដោយភាគទុនិកៈទាំង ឡាយដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានេះ ។ ឯកសារចម្លងច្រើនច្បាប់នៃសេចក្តីសំរេចដូចគ្នា ទាំងទូរសារថតចម្លង ដែលសមាជិកមួយរូប ឬច្រើនរូបបានចុះហត្ថលេខា ត្រូវចាត់ទុកថា សេចក្តីជាលាយលក្ខណ៍អក្សរនេះ ត្រូវរក្សាទុកក្នុងសៀវភៅកំណត់ហេតុ ដោយចាត់ទុកជាកំណត់ ហេតុសន្និបាតរបស់ភាគទុនិកៈ ។

**មាត្រាទី ១៦-** **ទីកន្លែងសន្និបាតភាគទុនិកៈ :**

រាល់សន្និបាតភាគទុនិកៈ ត្រូវតែរៀបចំឡើងនៅការិយាល័យធនាគារដែលបានចុះបញ្ជី ឬនៅកន្លែង ផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬដោយភាគទុនិកៈដែលជាអ្នកកោះអង្គប្រជុំ នោះ ។

**មាត្រាទី ២១-** **ការដឹកនាំនៃសន្និបាតភាគទុនិកៈ :**

សន្និបាតនៃភាគទុនិកៈនីមួយៗ ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីអវត្តមានប្រធានក្រុមប្រឹក្សាភិបាល ភាគទុនិកៈដែលមាន ឬដែលបានទទួលសិទ្ធិប្រទានត្រូវបោះឆ្នោតជ្រើសរើសតាំងប្រធានក្រុមប្រឹក្សាភិបាលស្តីទី ដើម្បីដឹកនាំសន្និបាតភាគទុនិកៈដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ។ រាល់សេចក្តីសំរេចរបស់ភាគទុនិកៈ ត្រូវតែកត់ត្រាជាលាយលក្ខណ៍អក្សរក្នុងកំណត់ហេតុនៃសន្និបាត ដែលសេចក្តីសំរេច ត្រូវបានធ្វើឡើងក្នុងសន្និបាតនោះ ហើយកំណត់ហេតុនោះត្រូវបានផ្តល់ការយល់ព្រមដោយភាគទុនិកទាំងអស់ ។ ការបោះឆ្នោតក្នុងសន្និបាតភាគទុនិកៈត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែករណីដែលមានការណែនាំពីប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ២២-** **ការបោះឆ្នោតដោយភាគទុនិក, ករណីពិសេស :**

ភាគហ៊ុនដែលនៅសល់នីមួយៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្តីសំរេចរបស់ភាគទុនិ
ដែលធ្វើឡើងអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវតែធ្វើឡើងដោយការបោះឆ្នោ
ដោយមានសំលេងគាំទ្រយ៉ាងតិច ហាសិបមួយភាគរយ (៥១ភាគរយ) នៃភាគហ៊ុនដែលនៅ
សល់ រៀងរាល់សន្និបាតដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែករណីដូចខាងក្រោមនេះ ដែ
តម្រូវអោយមានសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ ឬច្រើនជាងនេះ នៃភាគហ៊ុនដែលនៅដែលៈ

២២.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

២២.២ ការផ្លាស់ប្តូរគោលដៅ ឬកិច្ចការជំនួញរបស់ធនាគារ

២២.៣ ការផ្លាស់ប្តូរអាជ្ញាប័ណ្ណរបស់ធនាគារ

២២.៤ ការផ្លាស់ប្តូរមូលធនជាភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជី

២២.៥ ការចូលរួមគ្នា, ការដាក់បញ្ចូលគ្នា, ការរៀបចំឡើងវិញ ឬតាមនីតិវិធីណាក៏ដោយ ដែលតម្រូវអោយផ្ទេរទ្រព្យសម្បត្តិធនាគារភាគខ្លះ ឬក៏ទាំងអស់ ទៅអោយអង្គភាពផ្សេងទៀត ។

២២.៦ ការអនុម័តលើគោលនយោបាយទូទៅរបស់ធនាគារ ទាក់ទិននឹងការធ្វើប្រតិបត្តិ និងការទូទាត់ភាគលាភ និងការផ្លាស់ប្តូរទាំងនេះ ។

២២.៧ ការរំលាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជីធនាគារ ក្រោមមាត្រាទី ៥៤

២២.៨ ការកែប្រែរបៀបវារៈសន្និបាតភាគទុនិក ក្រោមមាត្រាទី ១៨

២២.៩ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២ និង

២២.១០ ការអនុមតិលើការតែងតាំង ឬការផ្លាស់ប្តូរឥស្សរជនគណនីរបស់ធនាគារ ។

មាត្រាទី ២៣-   **ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិកៈម្នាក់ៗ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលដោយខ្លួនឯង ឬដោយសិទ្ធិប្រទានបានមួយសំលេងក្នុងមួយភាគហ៊ុនដែលភាគទុនិកៈនោះកាន់កាប់ហើយ ក៏អាចបោះឆ្នោតទាំងអស់ឱ្យសមាជិកក្រុមប្រឹក្សាណាម្នាក់ ឬច្រើននាក់ដែលឈរឈ្មោះបោះឆ្នោត ។

## ជំពូកទី ៤ ក្រុមប្រឹក្សាភិបាល

មាត្រាទី ២៤-   **សិទ្ធិអំណាច និងភារកិច្ច ប្រធាន :**

ក- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្រនៃធនាគារ និងត្រួតពិនិត្យដំណើរការកិច្ចការជំនួញ ។ សមាជិកក្រុមប្រឹក្សាត្រូវធ្វើកិច្ចការណា ដែលផ្តល់ផលប្រយោជន៍ដល់ធនាគារ ។

ខ- អំណាចរបស់ក្រុមប្រឹក្សាភិបាល ត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ធនាគារ ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ធនាគារ លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល។

គ- សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកំរិត នូវបញ្ជី ឬរបាយការណ៍របស់ធនាគារនៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ឃ- ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិករបស់ខ្លួនមួយរូប ដើម្បីធ្វើជាប្រធានដោយសំលេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។ សំលេងឆ្នោតគាំទ្រភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាលដែលកំពុង (៣៧) ការងារនៅការិយាល័យអាចផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីសមាជិកក្រុមប្រឹក្សាបានឡើយ ។

មាត្រាទី ២៥-   **សមាជិកក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល មានសមាជិក ៥រូប ។

**មាត្រាទី ២៦.** **សមាសភាពក្រុមប្រឹក្សាភិបាលលើកដំបូង:**

ក្រុមប្រឹក្សាភិបាលដំបូង រួមមានសមាជិកដូចតទៅនេះ សមាជិកមួយរូបៗ ត្រូវបានតែងតាំងសំរាប់ អាណត្តិ ៣ឆ្នាំ :

១ លោក ជា សុខ
២ Mr. John Brinsden
៣ Mr. Peter Kooi
៤ Ms. Jutta Wagenseil
៥ Mr. Emile Hubert Joseph Groot
៦ Mr. Deepak C. Khanna
៧ Ms. Femke Bos
៨ លោក ឡុញ ថុល
៩ អ្នកស្រី សុខ វណ្ណានី

**មាត្រាទី ២៧.** **ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល :**

ភាគទុនិក: ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល សំរាប់អាណត្តិ ៣ ឆ្នាំ ដូចមានចែង ក្នុងមាត្រាទី២៣ ខាងលើ ។

**មាត្រាទី ២៨.** **អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំចន្លោះពីអង្គប្រជុំមួយ ទៅអង្គប្រជុំមួយមិនលើសពី៤ខែឡើយ ។ យ៉ាងហោចណាស់ អង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២ លើកក្នុងចំណោមអង្គប្រជុំក្រុមប្រឹក្សាភិបាលទាំង៤លើក ត្រូវតែមានមនុស្សចូលរួមប្រជុំពេញអង្គ អង្គប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល អាចធ្វើឡើងនៅពេលណាក៏បាន ដោយតែមានសំណូមពរ សមាជិកក្រុមប្រឹក្សាភិបាលចំនួន ៣រូប ។

**មាត្រាទី ២៩.** **កិច្ចប្រជុំតាមអ៊ីមែល ឬ តាមទូរស័ព្ទ :**

លើកលែងតែអង្គប្រជុំក្រុមប្រឹក្សាភិបាលចំនួន២លើក ដូចដែលបានរៀបរាប់ក្នុងមាត្រាទី ២៨ ចំណុច ទី២ អង្គប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាលអាចប្រជុំពិភាក្សា

តាមអ៊ីមែល ឬតាមទូរសព្ទ ។ ចំពោះការប្រជុំតាមទូរសព្ទ មានប្រសិទ្ធិភាព ក្នុងករណីដែលអ្នកចូលរួមប្រជុំទាំងអស់បញ្ជាក់ថាអាចស្តាប់ឮទៅវិញទៅមកទាំងអស់គ្នាបាន ។ ការប្រជុំដែលធ្វើឡើងតាម អ៊ីម៉ែល មានប្រសិទ្ធិភាព ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានបញ្ជាក់អំពីគោលបំណងនៃអង្គប្រជុំនោះ ដោយផ្តល់ត្រឡប់នូវការទទួលស្គាល់ តាម អ៊ីម៉ែល និងមានពេលវេលាពិនិត្យពិចារណាដែលបានផ្តល់ដោយសមាជិកក្រុមប្រឹក្សាភិបាលណាមួយ ហើយកំណត់ហេតុនៃរាល់អង្គប្រជុំ ត្រូវបញ្ជាក់ថា អង្គប្រជុំធ្វើឡើងដោយ អ៊ីម៉ែល និង សង្ខេបអ៊ីម៉ែល ដែលពិចារណាផ្តល់ដោយក្រុមប្រឹក្សាភិបាល ។

**មាត្រាទី ៣០.** **សេចក្តីជូនដំណឹងពីអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល :**

សេចក្តីជូនដំណឹងអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីផ្ញើជូនទៅសមាជិកក្រុមប្រឹក្សាទាំងអស់ចូលរួមប្រជុំយ៉ាងហោចណាស់៣០ថ្ងៃមុនកាលបរិច្ឆេទប្រជុំចាប់ផ្តើម

លិខិតជូនដំណឹង ត្រូវចុះកាលបរិច្ឆេទ, ពេលវេលា, និងទីកន្លែងប្រជុំ ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសំរេចផងដែរ ។

**មាត្រាទី ៣១.** **របៀបវារៈ :**

សមាជិកក្រុមប្រឹក្សា ដែលមានចំនួន៣រូប អាចស្នើបន្ថែម របៀបវារៈអង្គប្រជុំក្រុមប្រឹក្សាភិបាលណាមួយក៏បាន ដោយគ្រាន់តែជូនដំណឹងអំពីរបៀបវារៈនោះដល់ប្រធាន និងសមាជិកក្រុមប្រឹក្សាដទៃទៀត អោយបានយ៉ាងហោចណាស់ ១៥ថ្ងៃមុនពេលអង្គប្រជុំចាប់ផ្តើម។ ប្រសិនបើសមាជិកក្រុមប្រឹក្សាទាំងអស់ ដែលកំពុងបំពេញការងារ វត្តមានក្នុងអង្គប្រជុំ ឬដោយសិទ្ធិប្រទាន សមាជិកក្រុមប្រឹក្សាទាំងអស់នោះ អាចយល់ព្រមជាឯកច្ឆន្ទដើម្បីបន្ថែមរបៀបវារៈ ។

**មាត្រាទី ៣២.** **ទីកន្លែងប្រជុំ :**

គ្រប់អង្គប្រជុំដោយផ្ទាល់ ត្រូវរៀបចំឡើងនៅការិយាល័យកណ្តាលនៃធនាគារ ដែលបានចុះដូចបានចែងក្នុងមាត្រាទី៤ ឬនៅកន្លែងណាមួយផ្សេងទៀត ដែលក្រុមប្រឹក្សាភិបាលបានសំរេច

មាត្រាទី ៣៣- កូរ៉ុម :

កូរ៉ុមនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលជាចំនួនភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំពេញការងារ លើកលែងតែកិច្ចប្រជុំតាមអ៊ីម៉ែល ដែលសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវតែបំពេញកូរ៉ុម ។ សិទ្ធិប្រទានដែលចូលរួមប្រជុំ អាចរាប់បញ្ចូលជាវត្តមាននៃកូរ៉ុម ។

មាត្រាទី ៣៤- ការបោះឆ្នោតដោយក្រុមប្រឹក្សាភិបាល, ករណីពិសេស :

សមាជិកក្រុមប្រឹក្សាមួយរូបៗ មានសំលេងឆ្នោតមួយសំលេង ។ រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងដោយអនុលោមទៅតាមមាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ត្រូវមានសំលេងឆ្នោតគាំទ្រយ៉ាងហោចណាស់ ៥១ភាគរយ នៃក្រុមប្រឹក្សាភិបាលចូលរួម រាល់អង្គប្រជុំដែលមានកូរ៉ុមគ្រប់ចំនួន លើកលែងតែ ការសំរេចដែលទាក់ទងករណីដូចខាងក្រោមនេះ ដែលតម្រូវការសំលេង ឆ្នោតគាំទ្រយ៉ាងហោចណាស់ ៧៥ភាគរយ នៃសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការ :

៣៤.១ ការកែប្រែមាត្រាទាំងឡាយនៃលក្ខន្តិកៈ

៣៤.២ ការអនុម័តលើ ថវិកាប្រចាំឆ្នាំ ឬការផ្លាស់ប្តូរថវិកាប្រចាំឆ្នាំ ដែលអគ្គនាយកបានដាក់ជូន ក្នុងនោះរាប់បញ្ចូលទាំងថវិកា ដែលចំណាយលើមូលធន

៣៤.៣ ការចំណាយលើមូលធនលើសពីថវិកា ដែលត្រូវបានអនុម័តពីដំបូងរួចមកហើយ សំរាប់សារពើពន្ធនោះ

៣៤.៤ ការតែងតាំង ឬ ដកតំណែងអគ្គនាយកធនាគារ ក្រោមមាត្រាទី ៤២

៣៤.៥ ការធ្វើប្រតិផទ ឬការទូទាត់ភាគលាភ ឬការបែងចែកទ្រព្យសកម្មផ្សេងៗទៀតទៅអោយភាគហ៊ុននៃធនាគារ ។

៣៤.៦ ការរំលាយដោយស្ម័គ្រចិត្ត ឬ ការជំរះបញ្ជីធនាគារ ក្រោមមាត្រា ៤៤

៣៤.៧ ការអនុម័តលើការទូទាត់ភាគលាភរបស់ធនាគារ ត្រូវធ្វើទៅតាមគោលនយោបាយទាក់ទិននឹងការប្រតិផទ និងការទូទាត់ភាគលាភរបស់ធនាគារ ។

៣៤.៨ ការទិញភាគហ៊ុនវិញ ដោយអនុលោមទៅតាមមាត្រាទី ១២

**មាត្រាទី ៣៥-** **សេចក្តីសំរេច និង កំណត់ហេតុ :**

រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែបង្ហាញអោយឃើញច្បាស់ ដោយការកត់ត្រាសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលជាលាយល័ក្ខអក្សរ ឬដោយកំណត់ហេតុនៃអង្គប្រជុំ ដែលសេចក្តីសំរេចបានធ្វើឡើង កំណត់ហេតុនោះ នឹងត្រូវបានអោយសច្ចានុម័តដោយអង្គប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតនៅរៀងរាល់អង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយការលើកដៃ ឬដោយវិធីផ្សេងៗទៀត ដែលអធិបតីក្រុមប្រឹក្សាជាអ្នកសំរេច ។

**មាត្រាទី ៣៦-** **ការសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរ :**

សមាជិកក្រុមប្រឹក្សាភិបាល អាចធ្វើសកម្មភាពនៅចន្លោះកិច្ចប្រជុំក្រុមប្រឹក្សាភិបាលតាមរយសេចក្តីសំរេចជាឯកច្ឆន្ទជាលាយល័ក្ខអក្សរដែលមានចុះហត្ថលេខា ដោយសមាជិកក្រុមប្រឹក្សាទាំងអស់ដែលមានសិទ្ធិបោះឆ្នោតលើបញ្ហានោះ។ ឯកសារថតចំលងច្រើនច្បាប់នៃសេចក្តីសំរេចនោះរួមទាំងទូរសារថតចម្លងដែលសមាជិកក្រុមប្រឹក្សាមួយរូបឬច្រើនរូបបានចុះហត្ថលេខានឹងត្រូវចាត់ទុកថាជាផ្នែកនៃសេចក្តីសំរេចមួយជាលាយល័ក្ខអក្សរតាមគោលបំណងនៃមាត្រានេះ ។

**មាត្រាទី ៣៧-** **ការបោះឆ្នោតដោយសិទ្ធិប្រទាន :**

សមាជិកក្រុមប្រឹក្សាម្នាក់ ដែលមិនអាចចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាភិបាលបាន អាចតែងតាំងអ្នកទទួលសិទ្ធិប្រទានម្នាក់ ដើម្បីធ្វើការបោះឆ្នោត ក្នុងអង្គប្រជុំនោះជំនួសខ្លួនអោយតែ :

១- សិទ្ធិប្រទានដែលបានតែងតាំងនោះ គឺជាសមាជិកក្រុមប្រឹក្សាដទៃទៀត និង

២- សិទ្ធិប្រទាននោះ ត្រូវបានតែងតាំងសំរាប់តែអង្គប្រជុំមួយនោះទេ ។ សិទ្ធិប្រទានត្រូវរាប់បញ្ចូលបង្គ្រប់ កូរ៉ុម។ សិទ្ធិប្រទាន ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ហើយប្រគល់ជូនប្រធានក្រុមប្រឹក្សាភិបាល អោយបានមុនពេលប្រជុំចាប់ផ្តើម ហើយត្រូវបញ្ជាក់ពីព្រំដែននៃសមត្ថកិច្ច ឬក៏សិទ្ធិអំណាច។ សិទ្ធិប្រទានលែងមានសិទ្ធិ ឬក៏ចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលតទៅទៀតហើយនៅពេលណាសមាជិកក្រុមប្រឹក្សា ដែលបានផ្តល់សិទ្ធិប្រទានមានវត្តមានជាក់ស្តែងក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដោយខ្លួនឯងផ្ទាល់ ។

**មាត្រាទី ៣៨.** **សមាជិកក្រុមប្រឹក្សាដែលមានផលប្រយោជន៍ផ្ទាល់ខ្លួន :**

សមាជិកក្រុមប្រឹក្សាណាម្នាក់ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុ ទោះផ្ទាល់ ឬដោយប្រយោលក៏ដោយ (ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ) មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសំរេច លើសំណើណាក៏ដោយសមាជិកក្រុមប្រឹក្សារូបនោះត្រូវតែជំរាបសមាជិកក្រុមប្រឹក្សាដទៃទៀតពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិកក្រុមប្រឹក្សាទាំងអស់ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែគាំទ្រ អោយចូលរួមពិភាក្សាដោយមានសំលេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិកក្រុមប្រឹក្សាដទៃទៀតដែលចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិកក្រុមប្រឹក្សានោះ មិនត្រូវបោះឆ្នោតលើករណីបែបនោះ ទេ ប៉ុន្តែវត្តមានរបស់សមាជិកក្រុមប្រឹក្សាទាំងអស់ នឹងត្រូវបានរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

**មាត្រាទី ៣៩.** **ការដកតំណែងសមាជិកក្រុមប្រឹក្សា :**

មានតែភាគទុនិកៈដែលបានជ្រើសរើស ឬតែងតាំងសមាជិកក្រុមប្រឹក្សាទេ ដែលអាចដកសមាជិកក្រុមប្រឹក្សាបាន ។ ការដកតំណែងនេះ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាដោយគ្រាន់តែមានការជូនដំណឹងសមស្របដល់ប្រធានក្រុមប្រឹក្សាប៉ុណ្ណោះ ។

**មាត្រាទី ៤០.** **ការបំពេញកន្លែងទំនេរក្នុងក្រុមប្រឹក្សាភិបាល :**

បើអាសនៈណាមួយទំនេរក្នុងក្រុមប្រឹក្សាភិបាល មុនពេលផុតអាណត្តិធម្មតារបស់សមាជិកក្រុមប្រឹក្សា ដោយមូលហេតុមរណភាព សុំលាឈប់ ចូលនិវត្តន៍ ឬត្រូវបានដកចេញពីសមាជិកក្រុមប្រឹក្សាភិបាលភាគទុនិកៈ ដែលជ្រើសតាំង ឬតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលថ្មី ដើម្បីបំពេញអាណត្តិ ដែលនៅសល់របស់អតីតសមាជិកក្រុមប្រឹក្សាភិបាលមុននោះ ។

**មាត្រាទី ៤១.** **គណៈកម្មាធិការនានានៃក្រុមប្រឹក្សាភិបាល :**

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតគណៈកម្មាធិការសវនកម្ម, គណៈកម្មាធិការឥណទាន, គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តច្បាប់ និងគណៈកម្មាធិការត្រួតពិនិត្យទ្រព្យសម្បត្តិ និងបំណុល ហើយអាចបង្កើត គណៈកម្មាធិការដទៃផ្សេងៗទៀត ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ធនាគារ ។ គណៈកម្មាធិការទាំងនេះបង្កើតឡើង តាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ហើយសមាជិកទាំងអស់នៃគណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៥ ថ្នាក់ដឹកនាំ

**មាត្រាទី ៤២.** **អគ្គនាយក :**

ក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងអគ្គនាយកមួយរូបសំរាប់ដឹកនាំកិច្ចការធនាគារ ហើយអាចដក ដំណែងអគ្គនាយក ដោយអនុលោមទៅតាមមាត្រាទី៣៤.៤។ អគ្គនាយក ត្រូវទទួលខុសត្រូវ ក្នុងការអនុវត្ត និង ប្រកាន់យកយុទ្ធសាស្ត្រ និងការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវម ភារៈកិច្ចទទួលខុសត្រូវផ្សេងៗទៀត ដូចដែលក្រុមប្រឹក្សាភិបាលកំណត់អោយនៅពេលណាមួយ អគ្គនាយកត្រូវផ្តល់របាយការណ៍តាមពេលកំណត់ ជូនដល់ក្រុមប្រឹក្សាភិបាល រាប់ទាំងរបាយការណ៍ ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ។

**មាត្រាទី ៤៣.** **ថ្នាក់ដឹកនាំផ្សេងៗទៀត :**

អគ្គនាយក ត្រូវតែងតាំងនាយក នាយកដ្ឋាននានារបស់ធនាគារ និងថ្នាក់ដឹកនាំមន្ត្រីដទៃផ្សេ ទៀត ដែលអគ្គនាយកគិតថា វាជាតំរូវការចាំបាច់ សំរាប់ធនាគារ ។ អគ្គនាយក ត្រូវរៀប តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំទាំងនោះ។ អគ្គនាយក ឬក្រុមប្រឹក្សា ភិបាល អាចដកហូតថ្នាក់ដឹកនាំទាំងនោះបាន។

## ជំពូកទី ៦ ប្រការសំខាន់ៗដទៃទៀត

**មាត្រាទី ៤៤.** **ការរំសាយដោយស្ម័គ្រចិត្ត និងការជំរះបញ្ជី :**

ធនាគារ អាចត្រូវរំសាយ ហើយចំណូលពីការលក់ (បន្ទាប់ពីបានដោះបំណុលរបស់ធនាគាររួចរាល់ ហើយ) ត្រូវបែងចែកអោយភាគទុនិកៈតាមសមាមាត្រនៃចំនួនភាគហ៊ុន ដែលភាគទុនិកៈម្នាក់ៗ នៅក្នុងស្តុក នៅពេលធ្វើការរំសាយធនាគារនោះ។ ជាបឋមការរំសាយ ត្រូវបានស្នើឡើងដោយ សំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាដែលកំពុងបំពេញការ ហើយបានទទួលសច្ចានុម័តយល់ព្រមពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រ៧៥ភាគរយ ឬច្រើន នេះ នៃភាគហ៊ុនដែលនៅសល់ ។ ប្រសិនបើការរំសាយ មានសំលេងឆ្នោតគាំទ្រពីភាគទុនិក ៥៥ភាគរយនៃភាគហ៊ុនដែលនៅសល់ ដោយមិន គ្រប់តាមសំលេងឆ្នោតគាំទ្រ ៧៥ភាគរយ

តំរូវដោយឃ្លាខាងលើ ការសំរេចរំសាយ ឬមិនរំសាយធនាគារ ត្រូវតែបញ្ជូនទៅដោះស្រាយ តាមរយៈមជ្ឈត្តិវិនិច្ឆ័យ ដោយយោងទៅតាមច្បាប់មជ្ឈត្តិវិនិច្ឆ័យរបស់ សភាពាណិជ្ជកម្មអន្តរជាតិ (ICC) ដែលប្រតិបត្តិដោយមជ្ឈត្តករមួយ ឬច្រើនរូប ដែលបានតែងតាំងទៅតាមច្បាប់ ទីកន្លែងធ្វើមជ្ឈត្តិវិនិច្ឆ័យនោះ គឺនៅប្រទេសសិង្ហបុរី។ សមាសភាពតុលាការមជ្ឈត្តកម្ម មាន មជ្ឈត្តករបីរូប ដែលជ្រើសតាំងដោយសភាពាណិជ្ជកម្មអន្តរជាតិ។ ភាសាអង់គ្លេសគឺជាភាសា ដែលប្រើប្រាស់ជាផ្លូវការក្នុងដំណើរការមជ្ឈត្តិវិនិច្ឆ័យ។ ប្រសិនបើតុលាការមជ្ឈត្តកម្មយល់ព្រមអោយ រំសាយធនាគារនោះ ត្រូវដាក់ក្នុងការរំសាយដោយមិនស្ម័គ្រចិត្ត ហើយតែងតាំងនាយក មួយរូប ឬច្រើនរូប ឬអ្នកជំរះបញ្ជីដើម្បីត្រួតពិនិត្យការរំសាយ និងការជំរះបញ្ជីនោះ ។

**មាត្រាទី ៤៥-** **ភាគទុនិកមានឥទ្ធិពល :**

*អង្គការអេស៊ីលីដា* គឺជាភាគទុនិកដែលមានឥទ្ធិពលតែមួយគត់នៃធនាគារ ក្រោមច្បាប់របស់ ធនាគារ និងបញ្ញត្តិនានា ដែលមានស្រាប់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលចុះបញ្ជីធនាគារ ឬដែលត្រូវអនុ ម័ត និងមានប្រសិទ្ធភាពក្នុងពេលអនាគត ហើយគ្មានភាគទុនិកណាផ្សេង នៃធនាគារ ដែលអាច ចាត់ទុកថាជាភាគទុនិកដែលមានឥទ្ធិពល ឬ មានស្ថានភាពដែលអាច បង្ខំអោយ *អង្គការអេស៊ីលីដា* ទទួលខុសត្រូវបន្ថែមលើសពីមូលធនដែលបានចុះបញ្ជីហើយមិនទាន់បាន បង់ឡើយ ។ *អង្គការអេស៊ីលីដា* ត្រូវបានទទួលស្គាល់ថាជាភាគទុនិកដែលមានឥទ្ធិពលតាមច្បាប់ បទបញ្ញត្តិ និងការអនុវត្តជាក់ស្តែង នៅកម្ពុជា ហើយម្យ៉ាងវិញទៀត មិនអាចទទួលខុសត្រូវ លើសពីចំនួនមូលធនចុះបញ្ជី មិនទាន់បានបង់នោះឡើយ ។

**មាត្រាទី ៤៦-** **គោលនយោបាយដឹកនាំទូទៅ :**

ធនាគារត្រូវដឹកនាំ និងចាត់ចែងកិច្ចការជំនួញ និងអាជីវកម្មរបស់ខ្លួនទៅតាមគោលនយោបាយ ដឹកនាំទូទៅដើម្បីធ្វើប្រតិបត្តិការធនាគារ ដែលបានអនុម័តយល់ព្រមដោយមានសំលេងឆ្នោតតិច ៧៥ភាគរយ ឬច្រើនជាងនេះ ពីសមាជិកក្រុមប្រឹក្សាភិបាល ដែលកំពុងបំពេញការងារ ។

**មាត្រាទី ៤៧.** **ការទូទាត់ភាគលាភ ក្រោមគោលនយោបាយទូទៅនៃភាគលាភ :**

ធនាគារ នឹងមិនទូទាត់ភាគលាភទៅអោយភាគទុនិកៈទាំងអស់របស់ខ្លួន លើកលែងតែអនុលោម ទៅតាមគោលនយោបាយទូទៅដែលពាក់ព័ន្ធទៅនឹងការធ្វើប្រតិវេទ និងការទូទាត់ភាគលាភ ហើយមានការអនុម័តពីភាគទុនិកដែលកំពុងកាន់កាប់ភាគហ៊ុន ដោយសំលេងឆ្នោតគាំទ្រមិនតិចជាង ៧៥ ភាគរយ នៃភាគទុនិកដែលនៅសល់ ។

**មាត្រាទី ៤៨.** **សវនករខាងក្រៅ :**

ធនាគារ ត្រូវតែងតាំងសវនករខាងក្រៅមួយ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងមានសច្ចានុមតិយល់ព្រមដោយភាគទុនិក ។

**មាត្រាទី ៤៩.** **ឆ្នាំសារពើពន្ធ :**

ក្រុមប្រឹក្សាភិបាល ត្រូវតែកំណត់ឆ្នាំសារពើពន្ធនៃធនាគារទៅតាមសេចក្តីសំរេច ។

**មាត្រាទី ៥០.** **ការកំណត់ការទទួលខុសត្រូវ :**

គ្មានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ជាប់ជំពាក់ផ្ទាល់ខ្លួន ដោយសារការបំពេញការង ឬការកើតមានការខកខានមិនបានសំរេចជាមួយធនាគារឡើយ លើកលែងតែការបំពេញភារកិច្ច ឬការខកខានមិនបំពេញភារកិច្ច បណ្តាលអោយមានកំហុសដែលពាក់ព័ន្ធទៅនឹងការកេងបន្លំ ឬ រំលោភច្បាប់ ប្រព្រឹត្តខុសដោយចេតនា ឬកិច្ចការជំនួញដែលសមាជិកក្រុមប្រឹក្សារូបនោះបានទទួល ផលប្រយោជន៍ជាទ្រព្យសម្បត្តិមិនសមស្រប ឬសេវាកម្មដែលសមាជិកក្រុមប្រឹក្សារូបនោះ គ្មាន នឹងទទួលដោយស្របច្បាប់ ។

**មាត្រាទី ៥១.** **ការធានាសំណង :**

យោងតាមមាត្រាទី៥០ បានចែងថាក្រុមប្រឹក្សាភិបាល ដែលបានបំពេញការងារដោយស្មោះត្រ និងសច្ចភាពល្អ, ធនាគារ នឹងធានាទទួលខុសត្រូវជួសសមាជិកក្រុមប្រឹក្សាភិបាលរូបនេះ នូវរាល់ការចំណាយ (រួមទាំងថ្លៃមេធាវី) ការវិនិច្ឆ័យ (លើបណ្តឹង)ណាមួយ និងការពិន ជាប្រាក់ដែលកើតឡើង និងចំនួនទឹកប្រាក់ដែលបង់ ក្នុងការដោះស្រាយដែលក្រុមប្រឹក្សាភិបាល រូបនោះជាប់ពាក់ព័ន្ធជាមួយនឹង ឬក្នុងដំណើរការ រួមបញ្ចូលទាំង អំពើតំរាមកំហែ ទោះជារឿងរដ្ឋប្បវេណី, ព្រហ្មទណ្ឌ, រដ្ឋបាល ឬការស៊ើបអង្កេត តាមហេតុផលជាក់ស្តែ ដែលក្រុមប្រឹក្សារូបនោះ កំពុងបំពេញ ភារកិច្ចជាសមាជិកក្រុមប្រឹក្សាភិបាល ។

## មាត្រាទី ៥២- វិសោធនកម្ម :

### ៥២.១ អ្នកមានសិទ្ធិលើកសំណើរធ្វើវិសោធនកម្ម :

ការធ្វើវិសោធនកម្មទៅលើមាត្រាទាំងឡាយនៃលក្ខន្តិកៈ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល និង ភាគទុនិកៈ ដើម្បីធ្វើការសំរេច ប្រសិនបើសំណើនោះត្រូវបានធ្វើឡើងដោយ សមាជិកក្រុមប្រឹក្សាភិបាលដែលកំពុងបំពេញការងារយ៉ាងតិចចំនួន ១/៣ ឬពីភាគទុនិកៈដោយសំលេងឆ្នោតគាំទ្រ ចំនួន ៣៣-១/៣% ឬច្រើន ជាងនេះ នៃភាគហ៊ុនដែលនៅសល់ ។

### ៥២.២ សំលេងឆ្នោតចាំបាច់ :

រាល់ការធ្វើវិសោធនកម្មរបស់មាត្រាទាំងឡាយនៃលក្ខន្តិកៈ តម្រូវអោយមាន :

ក- សំលេងឆ្នោតគាំទ្រយ៉ាងតិច ៧៥ភាគរយនៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលកំពុងបំពេញការងារ ដោយមានភ្ជាប់ជាមួយនូវ

ខ- សំលេងឆ្នោតគាំទ្ររបស់ភាគទុនិកយ៉ាងតិច ៧៥ភាគរយ ឬច្រើនជាងនេះនៃភាគហ៊ុនដែលនៅសល់ ។

<u>**ភាគនុនិក**</u>

សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលហៅកាត់ថា *អង្គការអេស៊ីលីដា* ជាអង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក អ៊ិន ចាន់នី

ក្រុមហ៊ុន អេ អេស អេ អ៊ីន្ស ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើង និងចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

លោក រ័ត្ន យូម៉េង

**Deutsche Investitions- und Entwicklungsgesellschaft mbH,** ក្រុមហ៊ុនទទួលខុសត្រូវ មានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

តំណាងដោយ ______________________

**Ms. Jutta Wagenseil**

**Nederlandse Financierings-Maatschappij voor Ontwikkelingslanden N.V,** ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានបង្កើតឡើងក្រោមច្បាប់នៃប្រទេសហូល្លង់

តំណាងដោយ ______________________

**Ms. Els Boerhof**

**International Finance Corporation,** ជាអង្គការអន្តរជាតិ បានបង្កើតឡើងក្រោមមាត្រានៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងប្រទេសជាសមាជិក រួមទាំងព្រះរាជាណាចក្រកម្ពុជា

តំណាងដោយ ______________________

EDWARD NICHOLAS

~~**Mr. Deepak Khanna**~~

**Stichting Triodos Doen,** ជាមូលនិធិមួយ បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូល្លង់

តំណាងដោយ ______________________

**Ms. Femke Bos**

**Triodos Custody B.V,** ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានកសាងឡើងក្រោមច្បាប់នៃប្រទេសហូល្លង់ ក្នុងនាមជាក្រុមហ៊ុន **Triodos Fair Share Fund** ដែលជាមូលនិធិបានកសាងឡើងក្រោមច្បាប់នៃប្រទេសហូឡង់

តំណាងដោយ ______________________

**Ms. Femke Bos**

ក្រសួងពាណិជ្ជកម្ម
ការិយាល័យចុះបញ្ជី ពាណិជ្ជកម្ម
[illegible]

# ក្រុមប្រឹក្សាភិបាល

១- លោក ជា សុខ (តតិយជន) ____________

២- Mr. John Brinsden (តតិយជន) ____________

៣- Mr. Peter Kooi (តតិយជន) ____________

៤- Ms. Jutta Wagenseil (តតិយជន) ____________

៥- Mr. Emile Hubert Joseph Groot (តតិយជន) by proxy ____________

៦- Mr. Deepak C. Khenna (តតិយជន) by proxy ____________

៧- Ms. Femke Bos (តតិយជន) ____________

៨- លោក ឡុញ ថុល (តតិយជន) ____________

៩- អ្នកស្រី សុខ ទណ្ណនី (តតិយជន) ____________

បានឃើញនិងទទួលទុកជាឯកសារ
រាជធានីភ្នំពេញ, ថ្ងៃទី......ខែ......ឆ្នាំ....
ធនាគារជាតិ នៃ កម្ពុជា
ទេសាភិបាល